**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃសុំកូន

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **នាង ឆារី**

កញ្ញា **ឡៀង ម៉ារីកា**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ម៉ួយ ធីតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **នាង ឆារី** និង **ឡៅង ម៉ារីកា** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ក្រុមL4A11 ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២១-២០២២។

នាងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណ និងការកត្តញ្ញូធម៌ការដឹងគុណចំពោះ លោកឪពុក អ្នកម្តាយ ទាំងពីរដែលលោកមានគុណយ៉ាងធំធេង ដែលមានព្រហ្មវិហារធម៌ទាំងបួន ដល់កូនៗពុំអាចកាត់ថ្លៃបាន ព្រោះលោកទាំងពីរបានផ្តល់កំណើត និងការចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ដាស់តឿនកូនៗឲ្យប្រព្រឹត្តតែអំពើល្អ សេពគប់មិត្តភក្តិល្អៗជាដើម។ ការលះបង់ទាំងកម្លាំងកាយចិត្ត និងថវិការដល់កូនបានរៀនសូត្រចំណេះដឹងរហូតចប់បរិញ្ញាបត្រដោយជោគជ័យ។

នាងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរអរគុណចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំបង្ហាត់បង្រៀន ការយកចិត្តទុកដាក់ដោយទំនួលខុសត្រូវខ្ពស់ ក្នុងការអប់រំទូន្មាន នឹងផ្តល់នូវចំណេះដឹង ការដាស់តឿនឲ្យនិស្សិតខិតខំសិក្សា ស្វែងរកចំណេះដឹងដាក់ខ្លួន។

ជាពិសេសនោះយើងខ្ញុំទាំងពីរនាក់ ក៏សូមធ្វើការថ្លែងអំណរគុណ និងការដឹងគុណយ៉ាងជ្រាលជ្រៅទៅកាន់ **លោកជំទាវ សាស្ត្រាចារ្យ ម៉ុយ ធីតា** ដែលជាព្រឹទ្ធបុរសរង មហាវិទ្យាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាទីប្រឹក្សាអមក្រសួងយុត្តិធម៌ លោកជំទាវជាសាស្ត្រាចារ្យណែនាំលើប្រធានបទរបស់នាងខ្ញុំទាំងពីរនាក់ ទោះបីជាមានការនឿយហត់ និងលំបាកខ្លះ លោកជំទាវនៅតែជួយជ្រោមជ្រែង ផ្តល់នូវគន្លឹះ ទ្រឹស្តី របៀបនៃការសិក្សាស្រាវជ្រាវ បទពិសោធន៍ល្អៗ ការផ្តល់ដំបូន្មាន យោបល់ និងជួយកែសម្រួលខ្លឹមដែលពួកយើងខ្ញុំសរសេរឲ្យក្លាយជាសៀវភៅមួយក្បាលប្រកបដោយអត្ថន័យនិងខ្លឹមសារអាចទទួលយកបាន។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមជូនពរឲ្យ លោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តនិស្សិត និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបម្រើការងារនៅក្នុង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់មានតែសុខភាពល្អ សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងសូមឲ្យសមប្រកប និងជួបប្រទះនៅពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លាតឡើយ។

# អារម្ភកថា

សាលកវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជាសាកលវិទ្យាល័យមួយដែលបានផ្តល់នូវចំណេះដឹងដល់នាងខ្ញុំ **នាច ធារី** និង **ឡៅខ ម៉ារីកា** ក្នុងរយៈពេលបួនឆ្នាំនៃការសិក្សាផ្នែកថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ក្រៅពីខិតខំបង្ហាត់បង្រៀន អប់រំទូន្មាន ដល់និស្សិតលោកគ្រូអ្នកគ្រូតែងតែផ្តល់បទពិសោធន៍បង្ហាញនូវល្អៗ ដើម្បីបង្ហាញផ្លូវឲ្យដល់និស្សិតមានភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ។ នាងខ្ញុំទាំងពីនាក់ពិតជាមានក្តីសោមនស្ស នឹងរីករាយក្រៃលែងបានបោះជំហ៊ានចូលមកសិក្សានៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ពីព្រោះ សាកលវិទ្យាល័យនេះពិតជាបានផ្តល់នូវចំណេះដឹង និងបទពិសោធន៍ល្អៗហើយក៏ប្រៀបបានដូចជាផ្ទះទី២របស់យើងផងដែរ។

ក្រោយពីបានសិក្សាស្រាវជ្រាវរៀនសូត្រអស់រយៈពេលជាច្រើនខែកន្លងមក យើងខ្ញុំទាំងពីរនាក់ក៏មានមានការចាប់អារម្មណ៍ ទៅលើប្រធានបទដែលផ្សារភ្ជាប់ទៅលើកិច្ចការក្នុងការពារដល់កុមារ ស្ថិតនៅក្នុងក្របខ័ណ្ឌទំនាក់ទំនងផ្នែកឯកជន ដែលប្រធានបទនិយាយពី "**របបគតិយុត្តនៃសុំកូន** " ដែលជាប្រធានបទមួយគួរជាទីចាប់អារម្មណ៍របស់មនុស្សជាច្រើន ពីព្រោះការសុំកូននេះកើតមាននៅក្នុងប្រទេសជាច្រើននៅក្នុងសកលលោក រួមទាំងប្រទេសកម្ពុជាយើងដែរ។ សម្រាប់កាសុំកូននេះអាចជួយដល់កុមារកំព្រាដែលគ្មានជម្រកគ្មានទីពឹង កុមារក្រីក្រ ជាច្រើនលាននាក់ឲ្យមានអនាគតល្អ ជួយដល់អ្នកដែលពុំមានកូន ហើយចង់បានកូនទៅចិញ្ចឹម ដើម្បីឲ្យមានភាពពេញលេញនៅក្នុងគ្រួសារ និងមានសុភមង្គល និងជួយកាត់បន្ថយនៅចំនួនក្មេងកំព្រានៅក្នុងប្រទេសកម្ពុជាយើងផងដែរ។ ម្យ៉ាងវិញទៀតធ្វើឲ្យប្រទេសជាតិសម្បូរទៅដោយធនធានមនុស្សដែលមានមនុស្សមានចំណេះដឹង ដែលធ្វើឲ្យប្រទេសជាតិមានភាពរីកចម្រើន និងអភិវឌ្ឍ និងជួយសម្រួលដល់បញ្ហាដែលប្រទេសយើងប្រឈម ដូចជាការយកក្មេងទៅចិញ្ចឹមខុសច្បាប់ ការប្រើអំពើហិង្សាលើកុមារ ការជួញដូរលើកម្លាំងពលកម្មកុមារជាដើម ទាំងនេះវាគឺជាការរំលោភលើសិទ្ធកុមារយ៉ាងធ្ងន់ធ្ងរ ។

ហេតុនេះហើយទើបបានជាយើងខ្ញុំទាំងពីរនាក់សម្រេចចិត្ត ជ្រើសរើសយកប្រធានបទ "**របបគតិយុត្តនៃសុំកូន**"មកធ្វើជាប្រធានបទនៃការសិក្សាស្រាវជ្រាវដើម្បីទុកជាឯកសារ ដល់សិស្សនិស្សិតជំនាន់ក្រោយ ក៏ដូចជាសិស្សានុសិស្សផ្សេងទៀត និងសម្រាប់អ្នកមានបំណងចង់ស្វែងយលនីតិវិធីសុំកូននៅក្នុងប្រទេសកម្ពុជា។

ដោយឡែកនៅក្នុងកិច្ចការស្រាវជ្រាវ រៀបរៀងសារណាមួយនេះ ក៏អាចកើតមាននៅកំហុសឆ្គងដែលមានដោយអចេតនា ដោយប្រការណាមួយ។ ហេតុនេះយើងសូមអភ័យទោសទុកជាមុន និងរីករាយព្រមទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាកែលំអរ ពីសំណាក់ សាស្រ្តាចារ្យ រៀមច្បង និងមិត្តនិស្សិតអ្នកអានទាំងអស់ដើមឲ្យកិច្ចការនេះទទួលបានលទ្ធផលកាន់តែប្រសើរ និងសមបំណងថែមទៀត។

**មាតិកា**

**ទំព័រ**


**សេចក្តីផ្តើម** ........................................................ **១**

**ជំពូកទី១ សញ្ញាណទូទៅនៃសុំកូន**

**១.១.បទដ្ឋានគតិយុត្ត** ........................................................ **៥**

១.១.១. និយមន័យ ........................................................ ៦

១.១.២. ការបែងចែកប្រភេទនៃសុំកូន ........................................................ ៧

១.១.២.១. សុំកូនពេញលេញ ........................................................ ៧

១.១.២.២. សុំកូនធម្មតា ........................................................ ៧

១.១.២.៣. សុំកូនអន្តរប្រទេស ........................................................ ៧

១.១.២.៤. សុំកូនស្ថិតក្រោមអានុភាពនៃច្បាប់ស្តីពីសញ្ជាតិ ........................................................ ៨

**១.២. លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ** ........................................................ **៨**

១.២.១. លក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម ........................................................ ៩

១.២.២. អាយុរបស់ឪពុកម្តាយចិញ្ចឹម ........................................................ ៩

១.២.៣.ស្ថានភាពគ្រួសាររបស់ឪពុក ឬម្តាយចិញ្ចឹម ........................................................ ៩

**១.៣. លក្ខខណ្ឌចំពោះកូនសុំពេញលេញ** ........................................................ **១០**

១.៣.១. អាយុរបស់កូនសុំ ........................................................ ១០

១.៣.២. ស្ថានភាពរបស់កូនសុំ ........................................................ ១១

**១.៤. លក្ខខណ្ឌពាក់ពន្ធ័ចំពោះឪពុកម្តាយបង្កើត** ........................................................ **១១**

១.៤.១ ផលប្រយោជន៍របស់កូនសុំ និងលក្ខខណ្ឌផ្សេងៗមួយចំនួនទៀត ........................................................ ១២

**១.៥. នីតិវិធីនៃការបង្កើតសុំកូនពេញលេញ** ........................................................ **១៣**

១.៥.១. ការដាក់ពាក្យសុំ ........................................................ ១៣

១.៥.១.១. បុគ្គលដែលមានសិទ្ធិដាក់ពាក្យសុំ ........................................................ ១៣

១.៥.១.២. ទម្រង់នៃការដាក់ពាក្យសុំ ........................................................ ១៣

១.៥.១.៣.ទីកន្លែងដាក់ពាក្យសុំ និងពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ ........................................................ ១៤

១.៥.២. ការពិនិត្យពាក្យសុំ ........................................................ ១៤

១.៥.២.១. មូលដ្ឋានវិនិច្ឆ័យដែលតុលាការនឹងពិចារណា ........................................................ ១៤

១.៥.២.២. អំឡុងពេលសាកល្បងចិញ្ចឹម ............ ១៥
១.៥.៣. ការចេញដីកាសម្រេចរបស់តុលាការ ............ ១៥
១.៥.៤. អានុភាពនៃស្មុំកូនពេញលេញក្រោយដីការសម្រេចចូលជាស្ថាពរ ............ ១៦
១.៥.៤.១.ការបង្កើតញាតិភាពជាមួយឪពុកម្ដាយចិញ្ចឹម ............ ១៦
១.៥.៤.២.ការបញ្ចប់ញាតិភាពជាមួយឪពុកម្ដាយបង្កើត ............ ១៦
១.៥.៤.៣. អានុភាពចំពោះទ្រព្យសម្បត្តិ ............ ១៧
១.៥.៤.៤. ការចុះបញ្ជីអត្រានុកូលដ្ឋាន ............ ១៧
១.៥.៤.៥. សិទ្ធិដឹងអំពីកំណើតខ្លួន ............ ១៨
**១.៦. ការកាត់កាលស្មុំកូនពេញលេញ ............ ១៩**
១.៦.១. នីតិវិធីនៃការកាត់កាល ............ ១៩
១.៦.២. អានុភានៃការកាត់កាលស្មុំកូនពេញលេញ ............ ២០
១.៦.២.១ អានុភាពចំពោះឪពុកម្ដាយចិញ្ចឹម ............ ២០
១.៦.២.២. អានុភាពចំពោះឪពុកម្ដាយបង្កើត ............ ២០

**ជំពូកទី២ ស្មុំកូនធម្មតា**

**២.១.លក្ខខណ្ឌនៃការបង្កើតស្មុំកូនធម្មតា ............ ២២**
២.១.១. អាយុនិងស្ថានភាពឪពុកម្ដាយចិញ្ចឹម ............ ២២
២.១.២. អាយុ និងស្ថានភាពរបស់កូនសុំ ............ ២៣
**២.២. នីតិវិធីនៃការបង្កើតស្មុំកូនធម្មតា ............ ២៣**
២.២.១. ការដាក់ពាក្យសុំទៅតុលាការ ............ ២៣
២.២.២. ដីកាសម្រេចរបស់តុលាការ ............ ២៤
**២.៣.អានុភាពនៃស្មុំកូនធម្មតា ............ ២៥**
២.៣.១.ការចុះបញ្ជី និងបញ្ជីកំណើត ............ ២៥
២.៣.២. ការបង្កើតញាតិភាពជាមួយឪពុកម្ដាយចិញ្ចឹម ............ ២៥
**២.៤.ការកាត់កាលកូនស្មុំធម្មតា ............ ២៦**
២.៤.១. មូលហេតុនៃការកាត់កាល់ស្មុំកូនធម្មតា ............ ២៦
២.៤.២.ពាក្យសុំកាត់កាល់ស្មុំកូនធម្មតា ............ ២៧
២.៤.៣.អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា ............ ២៨

**ជំពូកទី៣ ស្មុំកូនអន្តរប្រទេស**

**៣.១. គោលការទូទៅនៃស្មុំកូនអន្តរប្រទេស ........ ២៩**
**៣.២. លក្ខខណ្ឌតម្រូវនៃការបង្កើតស្មុំកូនអន្តរប្រទេស ........ ៣០**
៣.២.១.លក្ខខណ្ឌសម្រាប់កូនសុំ ........ ៣១
៣.២.២.ការយល់ព្រមរបស់ឪពុកម្តាយបង្កើត ឬអាណាព្យាបាល ........ ៣២
៣.២.៣. លក្ខខណ្ឌសម្រាប់អ្នកសុំ ........ ៣៤
**៣.៣. នីតិវិធីនៃការស្មុំកូនអន្តរប្រទេស ........ ៣៥**
៣.៣.១.នីតិវិធីរដ្ឋបាលស្មុំកូនអន្តរប្រទេស ........ ៣៥
៣.៣.២. ការគ្រប់គ្រងសំណុំឯកសាររបស់រដ្ឋបាលស្មុំកូនអន្តរប្រទេស ........ ៣៩
៣.៣.៣. នីតិវិធីតុលាការ ........ ៤០
៣.៣.៤.អានុភាពនៃស្មុំកូនអន្តរប្រទេស ........ ៤២
**៣.៤. ចំណាត់ការក្រោយពីបញ្ចប់នីតិវិធីស្មុំកូន ........ ៤២**
៣.៤.១. ការទុកដាក់សំណុំឯកសារ ........ ៤៣
៣.៤.២. ការអនុញ្ញាតឲ្យកូនសុំមើលលិខិតស្មុំកូន ........ ៤៣
៣.៤.៣. ទណ្ឌកម្ម ........ ៤៤
**សេចក្តីសន្និដ្ឋាន ........ ៤៨**
**អនុសាសន៍ ........ ៥០**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

ការកសាងគ្រួសារ ជាកាតព្វកិច្ចពីធម្មជាតិ ដើម្បីទទួលបាននៅគ្រួសារមួយពេញលេញត្រូវមានប្ដីប្រពន្ធ ឪពុកម្ដាយកូន បន្តគ្នាជាច្រើនតំណ ជាខ្សែលោហិត ជាសាខាញាតិ ញាតិសាច់ថ្លៃ(ញាតិពន្ធ) ជាដើម។ ប្ដីប្រពន្ធខ្លះដោយសារមានហេតុផលផ្សេងគ្នា អាចនឹងមិនមានកូន អ្នកខ្លះទៀតមានកូនប្រុស ហើយចង់បានកូនស្រី ឬមានតែកូនស្រី ចង់បានកូនប្រុសជាដើម។ ជាទូទៅចំណងមនោសញ្ចេតនារវាងឪពុកម្ដាយ និងកូនជ្រាលជ្រៅណាស់ពិសេសគឺនៅពេលកូននៅតូចៗ។ ប៉ុន្តែមានហេតុផលជាច្រើននៃការបែកបាក់ ដែលបណ្ដាលឲ្យកុមារខ្លះក្លាយទៅជាក្មេងកំព្រាព្រោះ ឪពុកម្ដាយស្លាប់ចោលគ្មានទីពឹងក្រលំបាក ខ្លះទៀតកើតក្នុងគ្រួសារដែលមានជីវភាពលំបាក ហើយឪពុកម្ដាយដើម្បីអនាគតកូនឲ្យកូនទៅធ្វើការទាំងវ័យក្មេង ឬទៅនៅមណ្ឌលកុមារកំព្រា ឬទៅនៅជាមួយជនសប្បុរស ជួយចិញ្ចឹមបីបាច់ថែរក្សាទុកដូចកូនចៅ ឬអាចនិយាយបានម្យ៉ាងទៀតថាជាការ "សុំកូន" ។ សម្រាប់ការសុំកូននេះផងដែរ គឺជារឿងមួយដែលកើតមានតាំងពីយូណាស់មកហើយ ដែលមានការធ្វើបន្តៗគ្នាមក ជាច្រើន ដែលភាគីទាំងសងខាង ពោលគឺរវាងអ្នកមានអំណាចមេបា ជាមួយភាគីដែលសុំកូន ដែលអាចមានសញ្ជាតិដូចគ្នា (ពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ) ឬសញ្ជាតិផ្សេងគ្នា(ពលរដ្ឋខ្មែរ និងបរទេស)។ នៅក្នុងសង្គមជួនកាលពួកគាត់ធ្វើកិច្ចព្រមព្រៀងផ្ទាល់មាត់ រួចក៏ទទួលយកកុមារទៅចិញ្ចឹម ដោយមិនបានបង្កើតជាទំនាក់ទំនងតាមផ្លូវច្បាប់ ហើយកុមារទាំងនោះពុំអាចក្លាយទៅជាអ្នកដែលមានសិទ្ធិនិងករណីយកិច្ចឬទទួលបានឋានៈក្នុងគ្រួសារឡើយ។

ដោយមានការសម្លឹងឃើញនៅការលំបាករបស់កុមារ និងដើម្បីការពារផលប្រយោជន៍របស់ពលរដ្ឋខ្លួន ចាប់តាំងពីប្រទេសកម្ពុជាចាប់ផ្ដើមអនុវត្តប្រពន្ធ័ច្បាប់សរសេរ ស៊ីវិលឡ យើងឃើញថានៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ មានចែងពីការសុំកូន ក្រោយមកទៀតក៏មានការកែប្រែការសុំកូននៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩៦៧ ក៏មានបញ្ញត្តិអំពីសុំកូននេះដែរ។ បន្ទាប់មកទៀតក៏មានច្បាប់ពិសេសមួយទៀតក៏មានចែងពីការសុំកូនដែរ គឺច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ប៉ុន្តែវានៅតែពុំទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ ពោលគឺនៅគោលការណ៍សុំកូនអន្តរប្រទេសជាដើម។

បច្ចុប្បន្ន ដោយសារការយកចិត្តទុកដាក់ទៅលើកុមារពីសំណាក់ប្រជាជនខ្មែរ ជាពិសេសនោះគឺរាជរដ្ឋាភិបាលកម្ពុជា បានផ្ដល់សច្ចាប័នកាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ ក្នុងអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងអនុសញ្ញាអន្តរជាតិក្រុងឡាអេស្ដីពី ការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹង សុំកូនអន្តរប្រទេស។ ម្យ៉ាងវិញទៀតដោយរដ្ឋាភិបាលយល់ឃើញថា កុមារពិតជាមានសារៈសំខាន់ដែជាទីពាំងស្នងឫស្សីពាក់ពន្ធ័នឹងការសុំកូន រដ្ឋក៏បានចងក្រងច្បាប់ស្ដីពីសុំកូនពេញលេញ សុំកូនធម្មតា និងសុំកូនអន្តរប្រទេសដែលមានចែងពីសិទ្ធិ ករណីយកិច្ច ពោលគឺបញ្ញត្តិអំពីលទ្ធភាពរបស់អ្នកសុំ ដើម្បីថែរក្សាកូនសុំនេះឲ្យបាន

ត្រឹមត្រូវ នឹងសិទ្ធិករណីយកិច្ចរបស់កូនសុំ។ យ៉ាងណាមិញចំពោះប្រធានបទ ដែលនិយាយពី របបគតិយុត្ត នៃសុំកូនពិតជាមានសារៈសំខាន់សម្រាប់និស្សិតសិក្សាស្រាវជ្រាវ និងមានប្រយោជន៍ជាច្រើនសម្រាប់អ្នកមាន បំណងចងសុំកុមារទៅចិញ្ចឹម។

ប៉ុន្តែទោះបី ជាមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលយ៉ាងណា ក៏កម្ពុជានៅតែជួបប្រទះករណី យកកូនទៅចិញ្ចឹមមិនស្របច្បាប់ ក្នុងន័យជាប្រជាប្រយោជន៍អាពាហ៍ពិពាហ៍ ឬជាប្រយោជន៍ពីការទាញយក កម្លាំងកុមារ ឬពេលកុមារធំឡើងមើលថែខ្លួនពេលចាស់ជរា។

ដូច្នេះ តើការសុំកូនមានលក្ខខណ្ឌបែបណាខ្លះ? ហើយអ្នកសុំ បានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ កុមារ? តើការសុំកូនមានអានុភាពយ៉ាងដូចម្តេចខ្លះ?

យោងតាមលំនាំបញ្ហាខាងលើ យើងសង្កេតឃើញថានៅក្នុងករណីនៃការសុំកូន នៅតែមានបញ្ហា កើតឡើងជុំវិញមូលហេតុដូចជា ការយកកុមារទៅចិញ្ចឹមមិនព្រមអនុវត្តតាមនីតិវិធីច្បាប់ ការគេចវេសមិនព្រម បង់ពន្ធលើដំណើរការសុំកូនជាដើម។ ម្យ៉ាងទៀតវិញទៀតដោយ ឪពុកម្តាយ មិនមានចំណេះដឹង ជីវភាពក្រ លំបាក ទើបបណ្តោយឲ្យជនឆ្លៀតឱកាសមួយចំនួន អាចនិយាយញុះញង់ឆបោក ឲ្យព្រមប្រគល់កូនឲ្យគេ ដោយសន្យាថានឹងមើលថែយ៉ាងល្អ និងផ្តល់អនាគតមួយល្អដល់កុមារ តែជាក់ស្តែងពួកគាត់ទទួលបានតែ ប្រាក់បន្តិចបន្តួចតែប៉ុណ្ណោះ។ លើសពីនេះទៅជនឆ្លៀតឱកាសទាំងនោះ បានយកកុមារទៅលក់ដូរដូចជាទំនិញ នៅលើទីផ្សារ ហើយដែលគួរឲ្យខ្លាចជាងនេះទៅទៀតនោះ គឺជនដែលទិញកុមារទៅនោះចាត់ទុកកុមារដូចជា ទាសករ ដោយការរំលើភបំពានទាំងរាងកាយ និងផ្លូវចិត្ត។

ចំពោះគោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេះ ដោយយើងខ្ញុំចង់សិក្សា នឹងយល់ដឹង លំអិតអំពីការសុំកូននេះ មានដំណើរការបែបណាខ្លះ នឹង ដើម្បីជួលលើកកម្ពស់ដល់ការការពារសិទ្ធិកុមារ ជួយដល់កុមារកំព្រាគ្មានឪពុកម្តាយ ក្រីក្រលំបាក គ្មានចំណេះដឹង រងនៅការគាបសង្កត់ ការកេងប្រវញ្ច័លើ កម្លាំងពលកម្មកុមារ ដើម្បីឲ្យកុមារនោះទទួលបាននៅការចិញ្ចឹមបីបាច់ថែរក្សា និងទទួលបានការអប់រំ និង មានអនាគតល្អ ទុកជាស្នាដៃមួយសម្រាប់និស្សិតជំនាន់ក្រោយ គ្រាន់ជាផ្នែកមួយដែលជំនួយដល់ការសិក្សា ស្រាវជ្រាវដែលទាក់ទងនិងប្រធានបទខាងលើ ឲ្យកាន់តែមានភាពងាយស្រួល។

ប្រធានបទខាងលើពិតជាមានសារៈសំខាន់ណាស់ដល់និស្សិតក្នុងការសិក្សា និងសាធារណៈជន គ្រប់រូប ដើម្បីជំនួយផ្នែកចំណេះដឹង ស្មារតីឲ្យកាន់តែច្បាស់ និងស៊ីជម្រៅថែមមួយកម្រិតទៀត។

ទំហំនៃការស្រាវជ្រាវនេះ វាទាក់ទងជាមួយនឹង ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ជំពូកទី៤ ផ្នែកទី២ នៃមាត្រា១០០៧ ដល់មាត្រា១០១៩ ដែលស្តីពីសុំកូនពេញលេញ និងមាត្រា

១០២០ ដល់១០៣០ ស្តីពីស្មុំកូនធម្មតា ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសឆ្នាំ២០០៩ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម ជាដើម។ ដោយប្រធានបទខាងលើនេះមានភាពស៊ីជម្រៅ នឹងការស្មុំកូន និងការការពារសិទ្ធិកុមារ ដូច្នេះខ្លឹមសារនៃប្រធានបទនេះផ្តោតសំខាន់ទៅលើ៖

ទី១ ទាក់ទងទៅនឹងលក្ខខណ្ឌនៃការស្មុំកូន

ទី២ ទាក់ទងទៅនឹងនីតិវិធី ដំណើរការនៃការស្មុំកូន

ទី៣ ទាក់ទងទៅនឹងលទ្ធផលនៃការស្រាវជ្រាវ

ទី៤ ការពិភាក្សាទៅលើប្រធានបទដែលបានស្រាវជ្រាវ

សារៈសំខាន់នៃប្រធានបទដែលយើងខ្ញុំលើកមកសិក្សាស្រាវជ្រាវជាទូទៅគឺគិតពិចារណាលើចំណុចមួយចំនួនដែលមានសារៈសំខាន់ខ្លាំងណាស់ចំពោះការស្មុំកូននៅក្នុងប្រទេសកម្ពុជា ពីព្រោះនៅក្នុងអត្ថបទទាំងមូលបាននិយាយបង្ហាញពី ដំណើរការនៃនីតិវិធី និងលក្ខខណ្ឌនៃស្មុំកូនពេញលេញ ស្មុំកូនធម្មតា និងស្មុំកូនអន្តរប្រទេសនៅក្នុងប្រទេសកម្ពុជា។ លើសពីនេះទៅទៀត គឺដើម្បីពង្រឹងគំនិតប្រជាជនខ្មែរ និងនិស្សិតជំនាន់ក្រោយៗទៀតឲ្យយល់ដឹងពីអានុភាពគតិយុត្ត និងបញ្ឈប់ការស្មុំកូនដែលមិនមានការទទួលស្គាល់ពីច្បាប់ផងដែរ។

ទិន្នន័យការស្រាវជ្រាវ គឺយកមកវិភាគតាមរយៈពិពណ៌នាបែបគុណភាព និងកម្រិតនៃការជឿជាក់អាចទទួលយកបាន ដោយប្រើទិន្នន័យមួយចំនួនដូចជា៖ ការសាកសួរទៅកាន់សាស្ត្រាចារ្យដែលមានជំនាញបង្រៀនផ្នែកច្បាប់រដ្ឋប្បវេណី។ ទិន្នន័យបានមកពីការដកស្រង់នៅខ្លឹមសារសំខាន់ៗ របស់ច្បាប់មួយចំនួនដែលពាក់ពន្ធ័នឹងការស្មុំកូន សៀវភៅរបស់សាស្ត្រាចារ្យ និងសារណារបស់សិស្សច្បង យកមកពីបណ្ណាល័យសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបណ្ណាល័យផ្សេងទៀតតាមរយៈ Google និង YouTube ជាដើម។

បន្ទាប់មកយើងបានប្រមូលយកទិន្នន័យ ដែលបានរៀបរាប់ខាងលើយកមកសិក្សា និងពិភាក្សា និងធ្វើការស្វែងយល់ទៅលើកលក្ខខណ្ឌ ក៏ដូចជានីតិវិធីនីមួយៗ រួចហើយចុងក្រោយទើបទទួលនៅទិន្នន័យមួយដែលជាក់លាក់ យកមកធ្វើការពិពណ៌នា។

ការស្រាវជ្រាវនេះត្រូវបានចែកចេញជាសេចក្តីផ្តើម និង៣ជំពូកគឺ៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃការស្មុំកូន** ដែលនិយាយបរិយាយអំពី បទដ្ឋានគតិយុត្ត និយមន័យ ការបែងចែកប្រភេទនៃស្មុំកូន ស្មុំកូនពេញលេញ លក្ខខណ្ឌនៃការបង្កើតស្មុំកូនពេញលេញ នីតិវិធី

នៃការបង្កើតសុំកូនពេញលេញ អានុភាពនៃសុំកូនពេញលេញក្រោយដីការសម្រេចចូលជាស្ថាពរ ការកាត់កាល់កូនសុំពេញលេញ។

**ជំពូកទី២៖ សុំកូនធម្មតា** លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតា នីតិវិធីនៃការបង្កើតសុំកូនធម្មតាអានុភាពនៃសុំកូនធម្មតា ការកាត់កាល់សុំកូនធម្មតា។

**ជំពូកទី៣៖ សុំកូនអន្តរប្រទេស** លក្ខខណ្ឌតម្រូវនៃការបង្កើតសុំកូនអន្តរប្រទេស នីតិវិធីនៃការសុំកូនអន្តរប្រទេស ចំណាត់ការក្រោយពីបញ្ចប់នីតិវិធីសុំកូន។

# ជំពូកទី១ សញ្ញាណទូទៅនៃសុំកូន

ធម្មជាតិរបស់មនុស្សរស់នៅតែងតែមានគ្រួសារ ដែលមានឪពុកម្តាយ កូន និងញាតិលោហិតជាដើម។ នៅក្នុងគ្រួសារតែងតែជួបនៅបញ្ហាជាក់ជាមិនខានឡើយ ដោយបញ្ហាខ្លះបណ្តាលយឲ្យមានការបែកបាក់គ្រួសារ រវាងឪពុកម្តាយត្រូវលែងលះគ្នា ឬឪពុក ឬម្តាយស្លាប់ ដែលធ្វើឲ្យកូនត្រូវក្លាយជាក្មេងកំព្រា ត្រូវបញ្ជូនកុមារទៅរស់នៅមណ្ឌលកុមារកំព្រា។ ចំណែកឯគ្រួសារមានជីវភាពក្រីក្រ ពុំមានលទ្ធភាពចិញ្ចឹមកូន ក៏ត្រូវដាច់ឲ្យកូនទៅរស់នៅជាមួយអ្នកដ៏ទៃ។ រីឯគ្រួសារខ្លះមានតែប្តីប្រពន្ធ មានទ្រព្យសម្បត្តិតែអាចពុំមានកូនបាន ឬមានកូនតិច ដែលជាហេតុនាំឲ្យ ពួកគេត្រូវសុំកូនរបស់អ្នកដ៏ទៃមកចិញ្ចឹមដើម្បីបំពេញនូវភាពខ្វះខាតនៃគ្រួសារ ដែលមិនមានសមាជិកគ្រប់គ្រាន់ ឲ្យក្លាយទៅជាគ្រួសារមួយដែរពេញលេញ។ ដោយហេតុទាំងនេះហើយទើបបង្កើតឲ្យមាន របបសុំកូន បានកើតឡើង ដែលជាការបង្កើតទំនាក់ទំនងញាតិភាពតាមផ្លូវច្បាប់របស់បុគ្គលដែលជាឪពុកម្តាយចិញ្ចឹម ញាតិឪពុកម្តាយចិញ្ចឹម ជាមួយកូនសុំ ឲ្យមានទំនាក់ទំនងជាមួយគ្នានៅក្នុងគ្រួសារ ដែលមានសិទ្ធិ កាតព្វកិច្ចលើគ្នាទៅវិញទៅមក ដូចឪពុកម្តាយបង្កើត និងកូនបង្កើតដែរ។

## ១.១.បទដ្ឋានគតិយុត្ត

ការបង្កើតទំនាក់ទំនងបុត្តភាពពីធម្មជាតិត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងក្រមរដ្ឋប្បវេណីយ ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ដែលមាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឲ្យក្លាយជាពលរដ្ឋល្អ រីឯកូនប្រុសស្រី មានករណីយកិច្ចចិញ្ចឹម នឹងមើលថែមាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ។[1] មិនតែប៉ុណ្ណោះនៅក្នុងក្រមរដ្ឋប្បវេណីក៏មានការទទួលស្គាល់ពីទំនាក់ទំនងបុត្តភាពដែលកើតចេញពីកសុំកូនផងដែរ (សុំកូនពេញលេញ និងសុំកូនធម្មតា) ដែលជាទំនាក់ទំនងដែលកើតចេញពីការសុំកុមារកំព្រា គ្មានម្តាយឬឪពុក(ស្លាប់) ឬម្តាយឪពុកលែងលះគ្នាគ្មានទីពឹង គ្មានអាណាព្យាបាលទៅចិញ្ចឹមមើលថែរក្សា ដោយគ្រួរសារដែលមិនកូន ឬមានកូនតិច ដែលមានការទទួលស្គាល់ដោយច្បាប់។ ដើម្បីការរក្សាការពារសិទ្ធកុមារ ដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសនោះដើម្បីឲ្យកុមារទទួលបាននៅគ្រួសារ ការអប់រំ ការការពារកុមារពីការជួញដូរផ្លូវភេទ ការកេងប្រវ័ញ្ចលើកម្លាំងពលកម្មកុមារ ទើបបង្កើតច្បាប់ការសុំកូននេះឡើង ដោយរដ្ឋគិតគូរពីឧត្តមប្រយោជន៍កុមារ។ មិនតែប៉ុណ្ណោះដោយរដ្ឋាភីបាលបានសម្លឹងឃើញប្រយោជន៍ជាច្រើនដែលកុមារអាចនឹងទទួលបានពីការសុំកូននេះ ក៏បានបង្កើតអោយមានច្បាប់ស្តីការសុំកូនអន្តរប្រទេស ឆ្នាំ២០០៩ កើតមានផងដែរ នៅក្នុងប្រទេសចក្រកម្ពុជាយើង។ ការសុំកូនអន្តរ

[1] មាត្រា៤៧ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

ប្រទេសនេះ បានបើកឱកាសឲ្យដល់ជនបរទេសដែល ពុំអាចមានកូន ឬមានកូនតិចនៅក្នុងគ្រួសារ អាចស្នើសុំកុមារនៅក្នុងប្រទេសកម្ពុជាទៅចិញ្ចឹមនិងរស់ក្នុងប្រទេសខ្លួនបាន។ ការសុំកូននេះផងដែរបានផ្តល់នូវប្រយោជន៍យ៉ាងច្រើនទៅកុមារកំព្រា កុមារក្រីក្រ គ្មានទីពឹង អាចមានឱកាសទទួលបាននូវគ្រួសារមួយដែលពេញលេញ និងទទួលបាននូវការអប់រំ មើលថែពីសំណាក់ឪពុកម្តាយចិញ្ចឹម ដើម្បីឲ្យកុមារបានទទួលនៅអនាគតមួយដ៏ល្អបាន។

បន្ថែមពីនេះទៅទៀតការសុំកូននេះផងដែរ មិនថាសុំកូនក្នុងប្រទេស ឬការសុំកូនអន្តរប្រទេសនោះទេ គឺបានផ្តល់នូវផលវិជ្ជមានមួយចំនួនដល់រដ្ឋាភិបាលផងដែរ ក្នុងការកាត់បន្ថយថវិការចំណាយមួយចំនួនទៅលើការមើលថៃកុមារកំព្រានៅតាមមណ្ឌលកុមារកំព្រា កាត់បន្ថយចំនួនកុមារកំព្រា កាត់ន្ថយនៅចំនួនកុមារដែលពុំបានទទួលការសិក្សានៅក្នុងប្រទេស ជាផ្នែកមួយក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងប្រទសផងដែរ។

ដើម្បីឲ្យដឹងកាន់តែច្បាប់ពីផលប្រយោជន៍ នឹងនីតិវិធី ក៏ដូចជាលក្ខខណ្ឌ នៃការបង្កើតការសុំកូន យើងនឹងសិក្សានៅចំនុចបន្តទៀតខាងក្រោមនេះ ដែលនិយាយពីនិយមន័យនៃពាក្យ **សុំកូន** និងប្រភេទនៃការសុំកូនជាដើម។

### ១.១.១. និយមន័យ

សុំកូន គឺជាការសុំកូនរបស់អ្នកដ៏ទៃយកមកចិញ្ចឹមដោយស្របច្បាប់ និងបង្កើតទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម និងកូនចិញ្ចឹម ឲ្យមានសិទ្ធិនឹងករណីកិច្ចដូចគ្នា និងកូនបង្កើតដែរឬយើងអាចឲ្យនិយមន័យម៉្យាងទៀតបានថា គឺជាកិច្ចសន្យាដែលចងបុគ្គលពីរនាក់ ដែលម្នាក់ហៅថាឪពុក ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀហៅថាកូនចិញ្ចឹម ឲ្យមានចំណងនឹងគ្នាដូចកូនឥតខាន់ស្លាដែរ។

ការសុំកូននេះផងដែរបង្កើតឡើងក្នុងគោលបំណងដូចជា៖

- អ្នកដែលគ្មានអ្នកស្នងត្រកូល អាចរកទាយាទស្នងត្រកូលបានតាមរយៈការសុំកូន។
- ចំពោះអ្នកដែលគ្មាន ទាយាទស្នងមរតក់ ឬសន្តតិកម្មទ្រព្យសម្បត្តិជាអាទិ៍ ត្រូវរកទាយាទស្នងបានតាមរយៈសុំកូន។
- អ្នកដែលអសមត្ថភាពពុំអាចមានកូនបាន អាចរកកូនទៅចិញ្ចឹមបានតាមរយៈការសុំកូន។
- អ្នកដែលមានតែកូនស្រី ឬមានតែកូនប្រុស អាចរកកូនទៅចិញ្ចឹមបន្ថែមបានតាមរយៈការសុំកូននេះដូចគ្នា។
- រកឪពុកម្តាយឲ្យកុមារកំព្រា ឬកុមារដែលខ្វះការមើលថៃរក្សាពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល។

គោលបំណងទាំងនេះ សុទ្ធតែជាគោលបំណងសំខាន់ៗ ក្នុងការយកមកពិចារណាវិនិច្ឆ័យបង្កើតការសុំកូននេះឡើង ប៉ុន្តែគោលបំណងដែលមានអាទិភាពជាងគេនោះ គឺ ផលប្រយោជន៍របស់កូនសុំ ដែលមូលដ្ឋានគ្រឹះដើម្បីបង្កើតសុំនេះបាន។

### ១.១.២. ការបែងចែកប្រភេទនៃសុំកូន

ការសុំកូននាពេលបច្ចុប្បន្នយើងឃើញថា មានការបែងចែកជាបីប្រភេទរួមមានដូចជាៈ ការសុំកូនពេញលេញ សុំកូនធម្មតា សុំកូនអន្តរប្រទេស និងការសុំកូនស្ថិតក្រោមអានុភាពនៃច្បាប់ស្តីពីសញ្ជាតិ។

#### ១.១.២.១. សុំកូនពេញលេញ

កូនពេញលេញ គឺជាកិច្ចសន្យាដែលចងបុគ្គលពីរនាក់ ដែលម្នាក់ហៅថាឪពុក ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀតហៅថាកូនចិញ្ចឹម ឲ្យមានចំណងនឹងគ្នាដូចកូនមានខាន់ស្លាដែរ (ក្រមរដ្ឋប្បវេណី មាត្រា ១០០៧)។[2] សុំកូនពេញលេញ សំដៅដល់ការសុំកូនរបស់អ្នកដ៏ទៃមកចិញ្ចឹមដោយស្របច្បាប់ និងធ្វើឡើងតាមផ្លូវតុលាការដោយទាមទារឲ្យកូនសុំនោះផ្តាច់ទំនាក់ទំនងញាតិ និងទំនាក់ទំនងគតតិយុត្តរវាងឪពុកម្តាយបង្កើត នឹងញាតិសន្តានរបស់កូនសុំទាំងស្រុង ដើម្បីឲ្យបង្កើតទំនាក់ទំនងញាតិ និងទំនាក់ទំនងគតិយុត្តរវាងឪពុកម្តាយ ចិញ្ចឹម នឹងកូនសុំនោះវិញ។ការដែលធ្វើបែបនេះ ពីព្រោះដើម្បីឲ្យទំនាក់ទំនងឪពុកម្តាយចិញ្ចឹម និងកូនសុំ ដូចគ្នាទៅនឹងទំនាក់ទំនងឪពុកម្តាយ និងកូនបង្កើតដែលច្បាប់ទទួលស្គាល់។

#### ១.១.២.២. សុំកូនធម្មតា

សុំកូនធម្មតា គឺជាការសុំកូនមួយប្រភេទ ដែលញាតិរវាងកូនសុំ និង ឪពុកម្តាយបង្កើតត្រូវបន្តអត្ថិភាព មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ហើយកូនសុំនិងឪពុកម្តាយបង្កើតមានសិទ្ធិទាមទារ និងករណីកិច្ច ផ្តល់អាហារកាតព្វកិច្ច។ ម្យ៉ាងវិញទៀត កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ហើយកូនសុំត្រូវទទួលបានឋានៈដូចគ្នានិងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និងត្រូវទទួលបាននូសិទ្ធិ ករណីយកិច្ចដូចគ្នានិងកូនបង្កើតនៅក្នុងទំនាក់ទំនង ជាមួយនឹងឪពុកម្តាយចិញ្ចឹម(មាត្រា ១០២០នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។[3]

#### ១.១.២.៣. សុំកូនអន្តរប្រទេស

សុំកូនអន្តរប្រទេស គឺជាការសុំទារក ឬកុមារកំព្រាសញ្ជាតិខ្មែរ មានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយប្តីប្រពន្ធ ដែលរស់នៅប្រទេសផ្សេងទៀត ដើម្បីយកកុមារទៅចិញ្ចឹមជាកូន

[2] មាត្រា ១០០៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[3] មាត្រា១០២០ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ហើយនឹងទទួលស្គាល់ដោយច្បាប់ប្រទេសនោះ។ ស្មុំកូនអន្តរប្រទេស ក៏មិនខុសពីស្មុំកូនពេញលេញដែរពោល គឺជាការសុំអនីតិជនដែលមានអាយុក្រោម៨ (ប្រាំបី)ឆ្នាំ យកមកចិញ្ចឹមដែលមានឋានៈស្មើនឹងកូនបង្កើតដែរ ហើយត្រូវបញ្ចប់ញាតិភាពជាមួយឪពុកម្តាយបង្កើតទាំងស្រុង និងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ហើយការស្មុំកូននេះក៏ត្រូវសម្រេចដោយតុលាការពីប្រទេសដែលស្មុំកូននោះ រួចធ្វើដំណើរទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសរបស់អ្នកសុំ។

### ១.១.២.៤. ស្មុំកូនស្ថិតក្រោមអានុភាពនៃច្បាប់ស្តីពីសញ្ជាតិ

សម្រាប់ស្មុំកូនស្ថិតនៅក្រោមអនុភាពនៃច្បាប់ស្តីពីសញ្ជាតិ បានន័យចង់សំដៅទៅលើកូនជនបរទេសទាំងឡាយណាដែលត្រូវបានស្មុំកូនពេញលេញដោយសហពទ្ធ័ដែលជាពលរដ្ឋខ្មែរ ត្រូវទទួលបានសញ្ជាតិខ្មែរ នៅពេលដែលស្មុំកូនពេញលេញត្រូវបានបង្កើតឡើងស្របតាមច្បាប់ជាធរមាន (មាត្រា១០ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨)។[4] ដោយសារតែ ស្មុំកូនស្ថិតនៅក្រោមអានុភាពច្បាប់ស្តីពីសញ្ជាតិ ត្រូវអនុលោមតាមអនុក្រឹត្យ តែពុំទាន់មាននៅឡើយដូច្នេះ ពួកខ្ញុំពុំទាន់បានយកមកបកស្រាយនៅពេលនេះនៅឡើយទេ។

## ១.២. លក្ខខណ្ឌនៃការបង្កើតស្មុំកូនពេញលេញ

ស្មុំកូនពេញលេញ សំដៅដល់ការស្មុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ រវាងឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម នឹងកូនសុំហើយបញ្ចប់សិទ្ធិ និងកាតព្វកិច្ចរវាងកូនសុំ និងឪពុកម្តាយបង្កើត ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់ខ្លួន។ ហើយអាចនិយាយបានទៀតថាម្យ៉ាងថាដោយបង្កើតស្មុំកូនពេញលេញ កូនសុំត្រូវទទួលបានឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និងត្រូវទទួលសិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម។ បន្ថែមលើសពីនេះញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតត្រូវបញ្ចប់ដោយកូនសុំពេញលេញលើកលែងចំពោះសហព័ទ្ធម្ខាងក្លាយជាឪពុកឬម្តាយចិញ្ចឹម នៃកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត។ បុគ្គលដែលមានបំណងចង់បង្កើតស្មុំកូន ត្រូវតែជាបុគ្គលដែលមានសមត្ថភាព អាចចិញ្ចឹមបីបាច់ថែរក្សាកូនសុំបានយ៉ាងល្អ និងអាចផ្តល់ភាពកក់ក្តៅដូចគ្នាទៅនឹងឪពុកម្តាយបង្កើត និងកូនបង្កើត។ កូនសុំនឹងត្រូវរស់នៅជាមួយឪពុកម្តាយចិញ្ចឹមក្នុងនាមសមាជិកថ្មីនៅក្នុងគ្រួសារ ឪពុកម្តាយចិញ្ចឹម ដែលមានសិទ្ធិ និងករណីកិច្ចស្មើ នឹងកូនបង្កើតដែរ។

ដូច្នេះដើម្បីបង្កើតស្មុំពេញពេញលេញបាន ត្រូវមានលក្ខខណ្ឌចម្បងសម្រាប់ឪពុកម្តាយចិញ្ចឹម និងកូនសុំ ដូចគ្នា។

[4] មាត្រា១០ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨

### ១.២.១. លក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម

ដើម្បីអាចបង្កើតសុំកូនពេញលេញបាន លុះត្រាតែបានបំពេញតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ហើយមានលក្ខខណ្ឌជាច្រើន សម្រាប់សុំកូនពេញលេញ លក្ខខណ្ឌទាំងនោះ ទាក់ទងនឹងអាយុរបស់ឪពុកម្តាយចិញ្ចឹម និងកូនសុំ ការចូលរួមរបស់ភាគី ដែលមានផលប្រយោជន៍ពាក់ពន្ធ័ ។ ការសុំកូនពេញលេញអាចប្រព្រឹត្តទៅបានលុះត្រាតែឪពុកម្តាយចិញ្ចឹមទាំងពីរ ព្រមទាំងកូនចិញ្ចឹមមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ហើយត្រូវបានតុលាការប្រកាសអនុញ្ញាតឲ្យមានការសុំកូនពេញលេញ។ ការសម្រេចរបស់តុលាការទៅតាមពាក្យសុំនឹងបញ្ចប់នូវរាល់ទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយជាមួយនឹងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម។

### ១.២.២. អាយុរបស់ឪពុកម្តាយចិញ្ចឹម

ដោយសារតែ ការបង្កើតសុំកូនពេញលេញ គឺជាការផ្តល់នៅគ្រួសារមួយដ៏ពេញលេញដូច្នេះឪពុកម្តាយចិញ្ចឹមត្រូវមានអាយុចាប់ពី ២៥(ម្ភៃប្រាំ) ឆ្នាំឡើងទៅហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០(ម្ភៃ) ឆ្នាំ ទើបអាចបង្កើតសុំកូនពេញលេញបាន។[5]

ក្រមរដ្ឋប្បវេណី ពុំបានបញ្ជាក់ថាអាយុ ២៥(ម្ភៃប្រាំ) ឆ្នាំ គិតចាប់ពីពេលណានោះទេ ប៉ុន្តែគោលគំនិតនៃមាត្រានេះ គិតនៅពេលដែលកើតឡើងនូវអានុភាពនៃដីកាសម្រេច បុគ្គលដែលដាក់ពាក្យសុំត្រូវមានអាយុ ២៥(ម្ភៃប្រាំ) ឆ្នាំឡើងទៅ ទើបអាចបង្កើតសុំកូនពេញលេញបាន ។ ហេតុនេះក្នុងករណីបុគ្គលដែលដាក់ពាក្យសុំមានអាយុ ២៤(ម្ភៃបួន) ឆ្នាំ នៅពេលដែលតុលាការចេញដីកាសម្រេចបង្កើតសុំកូនបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមមានអាយុ ២៥(ម្ភៃប្រាំ) ឆ្នាំ អាចបង្កើតសុំកូនពេញលេញបាន។ ផ្ទុយទៅវិញ ប្រសិនបើនៅពេលដែលតុលាការចេញដីការសម្រេចបុគ្គលដែលដាក់ពាក្យសុំមានអាយុតិចជា ២៥(ម្ភៃប្រាំ) ឆ្នាំ នោះសុំកូនមិនអាចបង្កើតបានទេ ។

### ១.២.៣.ស្ថានភាពគ្រួសាររបស់ឪពុក ឬម្តាយចិញ្ចឹម

#### ក. ភាពចាំបាច់នៃការមានសហព័ទ្ធរបស់ជនដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម

បុគ្គលដែលអាចក្លាយជាឪពុកឬម្តាយចិញ្ចឹមបាន ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធហេតុនេះបុគ្គលដែលគ្មានសហព័ទ្ធមិនអាចបង្កើតសុំកូនពេញលេញបានទេ។[6] ដោយហេតុច្បាប់មានគោលគំនិតចង់ផ្តល់អោយនូវគ្រួសារមួយដែលមានឪពុកម្តាយទាំងពីរ ហើយមានស្នេហភាពដល់កុមារដែលត្រូវបាន

[5] មាត្រា ១០០៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[6] មាត្រា ១០០៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ស្នើសុំមកចិញ្ចឹម។ លើកលែងចំពោះសហព័ទ្ធក្លាយជាឪពុក ឬម្តាយចិញ្ចឹមនៃកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត។

**ខ. ការចូលរួមរបស់សហព័ទ្ធរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម**

ការបង្កើតស្មុំកូនពេញលេញមិនត្រឹមតែតម្រូវឱ្យបុគ្គលដែលជាឪពុក ឬម្តាយចិញ្ចឹមត្រូវតែជាជនដែលមានសហព័ទ្ធប៉ុណ្ណោះទេ ពោលក្នុងការបង្កើតស្មុំកូនពេញលេញ ត្រូវតែធ្វើឡើងដោយមានការសហការគ្នារវាងប្តីប្រពន្ធ (ឪពុកម្តាយចិញ្ចឹម) ប្តី ឬប្រពន្ធតែម្ខាងមិនអាចធ្វើការស្មុំកូនបានទេ ។ ដោយតម្រូវឱ្យមានការចូលរួមរបស់សហព័ទ្ធថែមទៀតផងមានន័យថា បុគ្គលដែលចង់បង្កើតស្មុំកូនពេញលេញត្រូវតែមានសហព័ទ្ធ និងការយល់ព្រមរបស់សហពទ្ធ័មិនគ្រប់គ្រាន់ទេត្រូវដាក់ពាក្យសុំដោយរួមគ្នាជាមួយសហព័ទ្ធទើបអាចសុំបង្កើតស្មុំកូនពេញលេញបាន ហេតុនេះក្នុងករណីដែលបុគ្គលចង់បង្កើតស្មុំពេញលេញ ដាក់ពាក្យសុំតែម្នាក់ឯង ឬដាក់ពាក្យសុំម្នាក់ឯងដោយមិនទទួលការយល់ព្រមរបស់សហព័ទ្ធម្ខាងទៀត ពាក្យសុំនោះនឹងត្រូវលើកចោល។ ម្យ៉ាងវិញទៀតទោះបីជាមានហេតុផលថាសហព័ទ្ធម្ខាងទៀតមិនអាចចូលរួមដាក់ពាក្យសុំជាមួយគ្នា ដោយមូលហេតុកំពុងបាត់ខ្លួន ឬមានជំងឺធ្ងន់ធ្ងរជាអាទិ៍ក៏ដោយ ក៏ពាក្យសុំនោះត្រូវលើកចោលដែរ។

## ១.៣. លក្ខខណ្ឌចំពោះកូនសុំពេញលេញ

ចំនួនកូនសុំត្រូវបានកំណត់ថា អាចសុំកូនបានតែពីរនាក់ប៉ុណ្ណោះ បើកូនសុំនោះមានមួយណាស្លាប់គេអាចសុំកូនមួយនាក់ទៀត។ ប៉ុន្តែក្នុងក្រមរដ្ឋប្បវេណីមិនមានមាត្រាណាមួយកំណត់ពីចំនួននៃកូនសុំឡើយ ហេតុនេះនៅពេលនេះក្រមរដ្ឋប្បវេណីឆ្នាំ២០០៧បានចូលជាធរមានតើចំនួនកូនសុំកំណត់យ៉ាងណា?

### ១.៣.១. អាយុរបស់កូនសុំ

ជាគោលការណ៍កូនសុំ ត្រូវមានអាយុតិចជាង ៨(ប្រាំបី)ឆ្នាំ។[7] ចំណុចនេះក្រមរដ្ឋប្បវេណីជជប៉ុនចែងថា ក្មេងដែលមានអាយុដល់ ៦(ប្រាំមួយ)ឆ្នាំ នៅពេលដាក់ពាក្យសុំមិនអាចក្លាយកូនសុំបានទេ ប៉ុន្តែប្រសិនបើ ក្មេងដែលមានអាយុតិចជាង ៨ឆ្នាំហើយដែលត្រូវបានថែរក្សាដោយបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមជាបន្តបន្ទាប់តាំងពីមុនពេលក្មេងនោះ មានអាយុដល់ ៦ឆ្នាំអាចសុំបាន ។ មានន័យថាជាគោលការណ៍ ស្មុំកូនពេញលេញអាចបង្កើតបានក្នុងករណីកូនសុំមានអាយុត្រឹម ៦ឆ្នាំប៉ុណ្ណោះ ប៉ុន្តែក្នុងករណីកូនសុំនោះ មានអាយុច្រើនជាង ៦(ប្រាំមួយ) ឆ្នាំ តែមិនលើសពី ៨(ប្រាំបី) ឆ្នាំ និងត្រូវបានថែរក្សាដោយ

[7] មាត្រា ១០១០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ( អង្គហេតុបានចិញ្ចឹមមុនពេលដាក់ពាក្យសុំ ) តុលាការអាចបង្កើតស្មុំកូនពេញលេញបាន ។

ដោយឡែកក្រមរដ្ឋប្បវេណី ពុំបានកំណត់ច្បាស់លាស់បែបនេះទេ គ្រាន់តែប្រើពាក្យថាជាគោលការណ៍ នាំឱ្យមានការបកស្រាយខុសៗគ្នា ហេតុនេះអាស្រ័យលើគោលគំនិតនៃការបកស្រាយរបស់កម្ពុជា ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មិនគួរទទួលស្គាល់នូវការបង្កើតស្មុំកូនពេញលេញចំពោះកុមារ ដែលមានអាយុច្រើនពេកនោះទេ ទោះបីជាមានអង្គហេតុនៃការចិញ្ចឹមមុនពេលដាក់ពាក្យសុំបង្កើតស្មុំកូនក៏ដោយ ពីព្រោះស្មុំកូនពេញលេញគឺ ការបង្កើតញាតិថ្មី ឱ្យកូនសុំ និង ផ្តាច់កូនសុំពីញាតិចាស់ ហើយកូនសុំ ត្រូវស្ថិតក្រោមការគ្រប់គ្រង របស់ឪពុកម្តាយចិញ្ចឹមទាំងស្រុង ហេតុនេះ ប្រសិនបើកូនសុំមានអាយុច្រើនអាចយល់ដឹងបាន នោះជាបញ្ហារំខានក្រោយពេលស្មុំកូន ត្រូវបានបង្កើតឡើង។ ដូច្នេះគួរមានការបកស្រាយកម្រឹតអំពីបញ្ហាអាយុនេះ ។

មានន័យថា ក្នុងករណីបុគ្គល ដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានថែរក្សាកូនសុំ មុនពេលដាក់ពាក្យសុំបង្កើតស្មុំកូនពេញលេញ គួរអនុញ្ញាតឱ្យបង្កើតស្មុំកូនពេញលេញប្រសិនបើកូនសុំមានអាយុចន្លោះ ៨,៩,១០ ឆ្នាំប៉ុន្តែប្រសិនបើ អាយុលើសពីនេះមិនគួរអនុញ្ញាតទេ។

### ១.៣.២. ស្ថានភាពរបស់កូនស្មុំ

ចំពោះកុមារគេនឹងពិនិត្យទៅលើទិដ្ឋភាពកុមារ ក្នុងករណីកុមារលំបាកខ្លាំង ឪពុកម្តាយក្រីក្រខ្លាំង ឬមានជម្ងឺផ្នែកស្មារតីធ្ងន់ធ្ងរ ឬកំពុងបាត់ខ្លួនជាអាទិ៍។ ម៉្យាងវិញទៀតការគ្រប់គ្រងកុមារមិនសមរម្យពីសំណាក់ឪពុកម្តាយ អាចនឹងមានការបំពានផ្លូវចិត្ត ផ្លូវកាយតាមរយៈពាក្យសំដី ឬអាចជាការមិនយកចិត្តទុកដាក់ក្នុងការមើលថែកុមារ។ លើសពីនេះដោយគិតពីភាពចាំបាច់ពីប្រយោជន៍របស់កុមារ អាចឲ្យកុមារមានភាពល្អប្រសើរទាំងផ្លូវកាយ ផ្លូវចិត្ត និងការផ្គត់ផ្គង់ចាំបាច់ដល់កុមារបានល្អជាងឪបុកម្តាយចិញ្ចឹម ទើបតុលាការបង្កើតឲ្យមានការស្មុំកូនបាន។

## ១.៤. លក្ខខណ្ឌពាក់ពន្ធ័ចំពោះឪពុកម្តាយបង្កើត

### ក. ការយល់ព្រមរបស់ឪពុកម្តាយបង្កើតរបស់កូនសុំ

ដើម្បីបង្កើតស្មុំកូនពេញលេញ លុះត្រាតែមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំនោះ។[8] ប៉ុន្តែក្នុងករណី ឪពុកម្តាយបង្កើតរបស់កូនសុំមិនអាចបង្ហាញឆន្ទៈបាន ឬមានករណីមានការធ្វើបាប ដោយឪពុកម្តាយ បោះបង់ចោលកូនដោយគំនិតទុច្ចរិត ឬ

[8] មាត្រា ១០១១វាក្យខ័ណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ហេតុផ្សេងទៀតដែលបំពានផលប្រយោជន៍ របស់កុមារដែលនឹងក្លាយជាកូនសុំយ៉ាងធ្ងន់ធ្ងរ។ ក្នុងករណីនេះ ស្មុំកូនពេញលេញអាចបង្កើតបានដោយមិនចាំបាច់ទទួលការយល់ព្រមពីឪពុកម្តាយបង្កើតរបស់កូនសុំឡើយ។[9] ការយល់ព្រមរបស់ឪពុកម្តាយបង្កើតអាចដកវិញពេលណាក៏បាន មុនពេលដីកាសម្រេចបង្កើតស្មុំកូនពេញលេញចូលជាស្ថាពរ ក្នុងករណីឪពុកម្តាយបង្កើត របស់កូនសុំបានដកនូវការយល់ព្រម តុលាការត្រូវលើកចោលពាក្យសុំបង្កើតស្មុំកូនពេញលេញ។ លើកលែងតែការដកការយល់ព្រមនោះបំពានផលប្រយោជន៍ធ្ងន់ធ្ងររបស់កូនសុំនោះ។

### ខ. លទ្ធភាពរបស់ឪពុកម្តាយបង្កើត

ដើម្បីការពារផលប្រយោជន៍ និងការបង្កើតក្រុមគ្រួសារថ្មីដ៏ល្អសម្រាប់កុមារជាចម្បង ច្បាប់បានបញ្ញត្តិយ៉ាងតឹងរឹងថា ឪពុកម្តាយបង្កើតមិនអាចយល់ព្រមប្រគល់កូនទៅអោយបុគ្គលណាម្នាក់បានឡើយ បើសិនជាឪពុកម្តាយបង្កើតមិនបានស្ថិតក្រោមស្ថានភាព និងលក្ខខណ្ឌដូចជា នៅក្នុងករណីដែលឪពុកម្តាយបង្កើតមានស្ថានភាពពិបាកយ៉ាងខ្លាំង ឬមិនសមរម្យក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជជាកូនសុំដោយឪពុកម្តាយបង្កើតឬស្ថានភាពពិសេសផ្សេងៗ ទៀតបើយល់ឃើញមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍កូននោះ។[10] ក្នុងករណីលក្ខខណ្ឌផ្សេងៗខាងលើត្រូវបានបំពេញក៏ដោយ តុលាការនឹងត្រូវពិនិត្យលើស្ថានភាពផ្សេងទៀតដែលមានឥទ្ធិពលក្នុងការសម្រេចបង្កើតស្មុំកូនពេញលេញដែលស្ថានភាពទាំងនោះរួមមានៈការលំបាកក្នុងការគ្រប់គ្រងថែរក្សាកូនៈ ឪពុកម្តាយបង្កើតក្រីក្រខ្លាំង មានជំងឺផ្លូវកាយ វិបត្តិស្មារតីធ្ងន់ធ្ងរ កំពុងបាត់ខ្លួនជាអាទិ៍។

- មានភាពមិនសមស្របក្នុងការថែរក្សាកូនៈ បំពាន ឬធ្វើបាបផ្លូវកាយ ឬតាមរយៈពាក្យសំដី ការធ្វេសប្រហែសក្នុងការមិនអើពើថែរក្សាកូនជាអាទិ៍។
- ភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍កូនៈ មានភាពល្អប្រសើរសម្រាប់កូននោះទាំងផ្នែកស្មារតី និងសម្ភារៈក្នុងការរស់នៅជាមួយបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមជាជាងរស់នៅជាមួយឪពុកម្តាយបង្កើត។

[9] មាត្រា ១០១១វាក្យខ័ណ្ឌទី១ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[10] មាត្រា ១០១២ មូលដ្ឋានវិនិច្ឆ័យស្មុំកូនពេញលេញ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.៤.១. ផលប្រយោជន៍របស់កូនសុំ និងលក្ខខណ្ឌផ្សេងៗមួយចំនួនទៀត

កត្តាដែលបង្កើតឲ្យមានអានុភាពរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម គឺកូនសុំត្រូវតែកាត់ផ្តាច់ញាតិភាពជាមួយឪពុកម្តាយបង្កើតហើយកូនសុំត្រូវតែទទួលបានសិទ្ធិ និងករណីកិច្ចដូចកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ រីឯអំណាចមេបាត្រូវប្រគល់ទៅឲ្យឪពុកម្តាយចិញ្ចឹម។[11]

ដើម្បីឲ្យការសុំកូនសម្រេចទៅបានត្រូវមានការព្រមព្រៀងពីឪពុកម្តាយឬអ្នកអាណាព្យាបាលនៃកូនសុំនោះ បើជាទារកឬកុមារដែលគេបោះបង់ត្រូវមានការយល់ព្រមពីរដ្ឋអំណាចឃុំឬសង្កាត់ នៅពេលដែលមានជនណាម្នាក់ដែល រើសបានទារកត្រូវយកទៅប្រគល់ឲ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំសង្កាត់នៅទីកន្លែងដែលរើសបានទារកនោះ។ ក្នុងអំឡុងពេលដែលទារក ឬកុមារដែលគេបោះបង់ចោលស្ថិតក្នុងការថែរក្សារបស់មន្ត្រីអត្រានុកូលដ្ឋាន បើមានជនណាសុំទារកដែលត្រូវបានរើសបាននោះជាកូនចិញ្ចឹមត្រូវយកនាមត្រកូលអ្នកសុំ។ ប៉ុន្តែបើពុំមានជនណាម្នាក់សុំទារក ដែលរើសបានធ្វើជាកូនចិញ្ចឹមទេនោះមន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកនោះដោយភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ទារក និងកំណត់ហេតុស្តីពីការប្រគល់ទារកទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬកុមារ។ ការសុំកូន ឬទារកពីឪពុកម្តាយជាកូនចិញ្ចឹមត្រូវអនុវត្តទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានជាធរមាន។

## ១.៥. នីតិវិធីនៃការបង្កើតសុំកូនពេញលេញ

ក្នុងនោះដើម្បីបង្កើតការសុំកូនពេញលេញបានស្របតាមច្បាប់ យើងត្រូវដំណើរការនីតិវិធីនៃការសុំកូន ដែលយើងអាចនិយាយបានថាជាលក្ខខណ្ឌទម្រង់នៃការសុំកូន។ នីតិវិធីក្នុងការដាក់ពាក្យសុំទៅតុលាការ និងការទទួលបានដីកាសម្រេចពីតុលាការ ក្នុងការអនុញ្ញាតអោយសុំកូន។ ការតម្រូវការអោយឆ្លងកាត់តុលាការវាជាភាពចាំបាច់ ព្រោះកម្មវត្ថុនៃសុំកូនពេញលេញ គឺកំណត់យកអនីតិជនហើយការកំណត់បែបនេះដើម្បីអោយមានការស្រាវជ្រាវ និងការវិនិច្ឆ័យដោយប្រុងប្រយ័ត្នអំពីផលប្រយោជន៍របស់កុមារ។

### ១.៥.១. ការដាក់ពាក្យសុំ

#### ១.៥.១.១. បុគ្គលដែលមានសិទ្ធិដាក់ពាក្យសុំ

បុគ្គលដែលអាចដាក់ពាក្យសុំត្រូវតែជាជនពាក់ព័ន្ធ ដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម គឺជាបុគ្គលដែលមានសិទ្ធិតាមបញ្ញត្តិសារធាតុក្នុងការដាក់ពាក្យសុំ។[12] សកម្មភាពដាក់ពាក្យសុំក៏តម្រូវអោយអ្នកដាក់ពាក្យមានសមត្ថភាពនៅក្នុងការធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាប

[11] មាត្រា ១០១៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[12] មាត្រា១៦ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១០

ណ្ដឹងដែរ។ ក្នុងករណីដែលសហព័ទ្ធណាម្ខាង គឺជាជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ សកម្មភាពដាក់ពាក្យសុំរបស់សហព័ទ្ធនោះក៏ត្រូវបានទទួលស្គាល់ដែរ។

### ១.៥.១.២. ទម្រង់នៃការដាក់ពាក្យសុំ

នីតិវិធីសុំកូនត្រូវធ្វើដោយអនុឡោមតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។ ពាក្យសុំអោយតុលាការចេញដីកាសម្រេចចាប់ផ្ដើមសុំកូនពេញលេញ អាចធ្វើឡើងជាលាយលក្ខអក្សរ ឬដោយផ្ទាល់មាត់បានលើកលែងតែក្នុងករណីមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ហើយនៅក្នុងពាក្យត្រូវសរសេរ

ចំណុចនីមួយៗដូចខាងក្រោម [13]៖

- អត្តសញ្ញាណជនពាក់ព័ន្ធ៖ ឈ្មោះ និងអាសយដ្ឋានអ្នកដាក់ពាក្យសុំ (របស់ឪពុកម្ដាយចិញ្ចឹម) និងភាគីម្ខាងទៀត (ឪពុកម្ដាយបង្កើត និងកូនសុំ)។
- ខ្លឹមសារនៃដីកាសម្រេច៖ សុំត្រូវតុលាការចេញដីកាសម្រេចចាប់ផ្ដើមរបបសុំកូនឪពុកម្ដាយចិញ្ចឹមឈ្មោះ.....និង កូនសុំឈ្មោះ.....។
- អង្គហេតុដែលជាមូលហេតុនៃការទាមទារ៖ ត្រូវបង្ហាញអោយតុលាការយល់អំពីស្ថានភាពលំបាករបស់កុមារនៅក្នុងគ្រួសារបង្កើត របបសុំកូនពិតជាអាចធ្វើអោយស្ថានភាពរស់នៅរបស់កុមារមានភាពល្អប្រសើរជាងមុន។
- ឧបសម្ព័ន្ធពាក្យសុំ៖ សេចក្ដីចម្លងសំបុត្រកំណើតរបស់ឈ្មោះអ្នកដាក់ពាក្យសុំ និងកូនសុំ។

### ១.៥.១.៣.ទីកន្លែងដាក់ពាក្យសុំ និងពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ

ទីកន្លែងដាក់ពាក្យសុំ និងពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំមានដូចជា៖

- ពាក្យសុំត្រូវដាក់នៅតុលាការខាងលំនៅឋានរបស់បុគ្គលដែល នឹងក្លាយជាឪពុកម្ដាយចិញ្ចឹម។ នៅក្នុងករណីដែលបុគ្គលជាអ្នកសុំមិនមានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេដូច្នេះគេ នឹងកំណត់យកទីសំណាក់របស់បុគ្គលនោះដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើជាលំនៅឋាន។
- ចំពោះពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ អ្នកដាក់ពាក្យត្រូវបង់៥០០០(ប្រាំពាន់)រៀល។

### ១.៥.២. ការពិនិត្យពាក្យសុំ

ពេលទទួលបានពាក្យសុំ តុលាការត្រូវពិនិត្យសុំថាបានសរសេរនូវចំណុចដែលច្បាប់តម្រូវហើយ ឬនៅ បើមិនទាន់សរសេរ ឬសរសេរមិនត្រឹមត្រូវតុលាការត្រូវបង្គាប់អោយភាគីអ្នកដាក់ពាក្យសុំ កែតម្រូវពាក្យសុំដោយទុករយៈពេលកំណត់មួយសមរម្យ។ បើអ្នកដាក់ពាក្យសុំ មិនព្រមកែតម្រូវតាមការបង្គាប់

[13] មាត្រា២៦ច្បាប់ស្តីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង ឆ្នាំ២០១០

របស់តុលាការ តុលាការត្រូវលើកពាក្យសុំចោលដោយ ដីកាសម្រេច។ អ្នកដាក់ពាក្យសុំ មានសិទ្ធិប្តឹងជំទាស់លើដីកាសម្រេចលើកចោលពាក្យសុំ ក្នុងអំឡុងពេលដែលច្បាប់បានកំណត់។

#### ១.៥.២.១. មូលដ្ឋានវិនិច្ឆ័យដែលតុលាការនឹងពិចារណា

បន្ទាប់ពីទទួលបានពាក្យសុំ និងបានពិនិត្យឃើញថាពាក្យមានលក្ខណៈត្រឹមត្រូវហើយ តុលាការត្រូវធ្វើការវិនិច្ឆ័យលើពាក្យសុំ ដើម្បីចេញសេចក្តីសម្រេច។ តុលាការត្រូវសម្រេចដោយវិនិច្ឆ័យតាមឆន្ទានុសិទ្ធិរបស់ខ្លួនដែលជាការស្រាវជ្រាវអង្គហេតុ និងការពិនិត្យភស្តុតាងនានា ដើម្បីចេញសេចក្តីសម្រេចចាប់ផ្តើមពីរបបសុំកូនតុលាការត្រូវធ្វើការវិនិច្ឆ័យអំពីៈ ឆន្ទៈព្រមព្រៀងរវាងសហព័ទ្ធជាឪពុកម្តាយចិញ្ចឹមអាយុរបស់កូនសុំ និងឪពុកម្តាយចិញ្ចឹម ឯកភាពរបស់ឪពុកម្តាយបង្កើត លទ្ធភាពដែលអាចធ្វើឲ្យកុមារមានការថែទាំប្រសើរជាងមុន ដើម្បីអាចចេញដីកាសម្រេចចាប់ផ្តើមសុំកូន ចាំបាច់ត្រូវឆ្លងកាត់ការចិញ្ចឹមសាកល្បងជាមុនសិន។

#### ១.៥.២.២. អំឡុងពេលសាកល្បងចិញ្ចឹម

សុំកូនពេញលេញ គឺបង្កើតអោយមានអានុភាពខ្លាំង ហើយលក្ខខណ្ឌនៃការបង្កើត និងលក្ខខណ្ឌនៃការកាត់កាលមានភាពតឹងរឹង ដូច្នេះតុលាការត្រូវសម្រេចអោយហ្មត់ចត់ថា តើឪពុកម្តាយចិញ្ចឹមានសមត្ថភាពក្នុងការចិញ្ចឹមមើលថែរក្សាកូនបានដែរឬទេ? ឬតើឪពុកម្តាយចិញ្ចឹមនិងកូនសុំអាចរស់នៅចុះសម្រុងគ្នាដែរឬទេ?។ អំឡុងពេលសាកល្បងនឹងចាប់ផ្តើមអនុវត្តក្រោយពេលអ្នកពាក្យសុំបង្កើតសុំកូនទៅតុលាការ មិនមែនកើតឡើងមុនពេលដាក់ពាក្យទៅតុលាការនោះទេ។ នៅក្នុងអំឡុងពេលសាកល្បងតុលាការត្រូវពិចារណាលើស្ថានភាពបុគ្គល ដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម បានធ្វើការគ្រប់គ្រងថែរក្សាកុមារ ដែលនឹងក្លាយជាកូនសុំជាគោលការណ៍យ៉ាងតិច ៦(ប្រាំមួយ)ខែ ឬអាចលើសពីនេះបើតុលាការយល់ឃើញថាគួរបន្ថែម។

### ១.៥.៣. ការចេញដីកាសម្រេចរបស់តុលាការ

ជាចុងក្រោយតុលាការត្រូវចេញ **ដីកាសម្រេច** ដែលជាដីកាសម្រេចទទួលស្គាល់សុំកូនពេញលេញ ឬដីកាសលើកចោលពាក្យសុំ។[14] តុលាការត្រូវចេញដីកាសម្រេច ទទួលស្គាល់សុំកូនពេញលេញក្នុងករណីដែលតុលាការបានពិចារណាឃើញថា ភាគីដែលពាក់ព័ន្ធបានបំពេញគ្រប់លក្ខខណ្ឌដែលច្បាប់បានតម្រូវ និងមានមូលដ្ឋានវិនិច្ឆ័យគ្រប់គ្រាន់ដើម្បីបង្កើតសុំកូនពេញលេញ។

[14]មាត្រា១០១៣ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ផ្ទុយទៅវិញ ប្រសិនបើតុលាការ ពិនិត្យផ្ទៀងផ្ទាត់អង្គហេតុ និងភស្តុតាងរួច ប្រសិនបើតុលាការយល់ឃើញថា រឿងក្តីសុំកូនពេញលេញ មិនបានបំពេញលក្ខខណ្ឌណាមួយ ក្នុងចំណោមលក្ខខណ្ឌទាំងអស់ តុលាការត្រូវចេញដីការសម្រេចលើកចោលពាក្យសុំ និងទុកសិទ្ធិឲ្យភាគីអ្នកដាក់ពាក្យសុំ និងបុគ្គលពាក់ព័ន្ធមានសិទ្ធប្តឹងជំទាស់។

លក្ខខណ្ឌទាំងអស់នោះមានដូចខាងក្រោម[15]៖

១. លក្ខខណ្ឌសម្រាប់ឪពុកម្តាយចិញ្ចឹម មាត្រា១០០៨ និងមាត្រា១០០៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

២. លក្ខខណ្ឌសម្រាប់កូនសុំ មាត្រា១០១០

៣.ការបង្ហាញឆន្ទៈយលព្រមរបស់ឪពុកម្តាយចិញ្ចឹម មាត្រា១០១១ នៃក្រមរដ្ឋប្បវេណី

៤. មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ មាត្រា១០១២ នៃក្រមរដ្ឋប្បវេណី

ដីកាសម្រេចអំពីសុំកូនពេញលេញ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយត្រូវសរសេរអំពីសំអាងហេតុនិងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមទទួលបន្ទុកត្រូវចុះហត្ថលេខាលើដីកាសម្រេចនេះ។ ដីកាសម្រេច ត្រូវធ្វើការជូនដំណឹងទៅជនដែលត្រូវទទួលដីកាសម្រេចនេះដែលរួមមាន អ្នកដាក់ពាក្យសុំ កុមារដែលនឹងក្លាយជាកូនសុំ និងឪពុកម្តាយបង្កើត។ ដីកាសម្រេចអំពីសុំកូនពេញលេញចូលជាស្ថាពរ នៅអំឡុងពេលសម្រាប់ប្តឹងទាស់បានកន្លងហួស ឬពេលដែលតុលាការនៃបណ្តឹងជំទាស់ដែលសាលាឧទ្ធរណ៍បានចេញដីកាសម្រេចអំពីពាក្យបណ្តឹងជំទាស់

## ១.៥.៤. អានុភាពនៃសុំកូនពេញលេញក្រោយដីកាសម្រេចចូលជាស្ថាពរ

របបសុំកូន បង្កើតអានុភាពនៅពេលដីកាសម្រេចចាប់ផ្តើមរបបសុំកូនចូលជាស្ថាពរ។ ស្របពេល និងការចូលជាស្ថាពរនៃដីកាសម្រេចនេះវាបានបង្កើតអោយមានអានុភាពគតិយុត្តមួយចំនួនដូចជា៖

### ១.៥.៤.១.ការបង្កើតញាតភាពជាមួយឪពុកម្តាយចិញ្ចឹម

ទំនាក់ទំនងឪពុកម្តាយ និងកូនតាមច្បាប់ត្រូវកើតឡើងរវាងពុកម្តាយចិញ្ចឹមនិងកូនសុំ ចាប់ពីថ្ងៃបង្កើតសុំកូន(ដីកាសម្រេចបង្កើតឱ្យសុំកូនចូលជាស្ថាពរ) ហើយទំនាក់ទំងញាតិភាពរវាងកូនសុំជាមួយនឹងជាលោហិតរបស់ឪពុកម្តាយចិញ្ចឹម ដែលដូចគ្នាទៅនឹងទំនាក់ទំនងញាតិលោហិតតាំងពីកំណើត ក៏ត្រូវកើតឡើងដែរ ។ កូនសុំមានឋានៈដូចគ្នានឹងកូនបង្កើតទទួលបានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើត

[15] មាត្រា៣៥ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១០

នៅក្នុងទំនាក់ទំនងជាមួយ នឹងឪពុកម្តាយចិញ្ចឹង ហើយកូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនរបស់ខ្លួនបាន ។ កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ។ ប៉ុន្តែក្នុងករណីដែល ប្តីប្រពន្ធណាម្ខាងក្លាយជាឪពុក ឬម្តាយចិញ្ចឹមរបស់កូនបង្កើតរបស់សហពទ្ធ័ម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬម្តាយបង្កើត និងឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ។

ឧទាហរណ៍ អ្នកស្រី **គ** និង លោក **ខ** បានលែងលះគ្នា ហើយកូនស្រី **ច** ស្ថិតនៅក្រោមអំណាចមេបា របស់អ្នកស្រី **គ** , អ្នកស្រី **គ** បានរៀបអាពាហ៍ពិពាហ៍ថ្មីមួយ ជាមួយ លោក **ក** បន្ទាប់មក លោក **ក** មានបំណងចង់សុំ ច ធ្វើជាកូនសុំ ក្នុងករណីនេះ អ្នកមានអំណាចមេបារួមលើ **ច** គឺ **គ** និង **ក** ។

### ១.៥.៤.២.ការបញ្ចប់ញាតភាពជាមួយឪពុកម្តាយបង្កើត

ក្រោយបង្កើតសុំកូន ញាតិភាពជាមួយឪពុកម្តាយបង្កើតត្រូវបានបញ្ចប់ មានន័យថាឪពុកម្តាយនិងកូនបង្កើតក្លាយជាអ្នកដទៃ លែងជាប់សាច់ឈាមនឹងគ្នា ហើយញាតិលោហិតរបស់ឪពុកម្តាយបង្កើត ក៏ត្រូវបញ្ចប់តដែរ។[16] លើកលែងតែករណីកូនសុំជាកូនរបស់សហពទ្ធ័ម្ខាងទៀត ។ ហេតុនេះ សិទ្ធិធ្វើសន្តតិកម្មចំពោះគ្នា ទៅវិញទៅមក ត្រូវបានបាត់បង់និងមិនអាចទទួលកាតព្វកិច្ចទៅវិញទៅមកបានទៀតទេ ហើយឪពុកម្តាយបង្កើត ក៏ពុំមានសិទ្ធិសួរសុខទុក្ខកូនដែរ ។ ការកំណត់បែបនេះ ដោយហេតុថាគោលបំណងនៃការបង្កើតសុំកូនពេញលេញគឺបង្កើតញាតិភាពថ្មីមួយ នៅក្នុងមជ្ឈដ្ឋាន នៃគ្រួសាររបស់ឪម្តាយចិញ្ចឹមដែលមានស្នេហភាពល្អហើយកូនសុំត្រូវស្ថិតក្រោមការគ្រប់គ្រងទាំងស្រុងរបស់ឪពុកម្តាយចិញ្ចឹម ហេតុនេះដើម្បីជៀសវាងការរំខាន ឬជ្រៀតជ្រែកដោយមិនសមរម្យរបស់ឪពុកម្តាយបង្កើត ត្រូវតែបញ្ចប់ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ។

### ១.៥.៤.៣. អានុភាពចំពោះទ្រព្យសម្បត្តិ

ក្រៅពីទំនាក់ទំនងសុំកូនពេញលេញត្រូវបានបង្កើតរួចហើយ តាមរយៈអានុភាពនៃសេចក្តីសម្រេច ដែលចូលជាស្ថាពរទំនាន់ទំនងលើទ្រព្យសម្បត្តិរបស់កូនសុំត្រូវបានបង្កើតឡើង។ អាស្រ័យហេតុនេះ កូនសុំត្រូវទទួលបានសិទ្ធិធ្វើសន្តតិកម្មទៅលើទ្រព្យសម្បត្តិរបស់ឪពុកម្តាយចិញ្ចឹម ក្នុងឋានៈជាសន្តតិជនលំដាប់ទី១។ បន្ថែមពីនេះកូនសុំមានសិទ្ធិទទួលបាននូវអាហារកាតព្វកិច្ច។

### ១.៥.៤.៤. ការចុះបញ្ជីអត្រានុកូលដ្ឋាន

អានុភាពចម្បងនៃការបង្កើតការសុំកូនពេញលេញ គឺជាការបង្កើតទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម រួមទាំងញាតិរបស់ឪពុកម្តាយចិញ្ចឹម និងកាត់ផ្តាច់ទាំងស្រុងនូវទំនាក់ទំនងរវាងកូន

[16] មាត្រា១០១៨ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ជាមួយឪពុកម្តាយបង្កើត និងញាតិរបស់ឪពុកម្តាយបង្កើត។ ដោយសារតែហេតុនេះឪពុកម្តាយចិញ្ចឹមត្រូវធ្វើការកែប្រែបញ្ជីកំណើតរបស់កូនសុំជាថ្មីដោយភ្ជាប់ទៅជាមួយ នឹងដីកាសម្រេចបង្កើតសុំកូនរបស់តុលាការ។[17] ថ្វីត្បិតតែក្រមរដ្ឋប្បវេណីពុំបាន បញ្ញត្តិអំពីនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋានរបស់កូនសុំ ក្រោយដីកាសម្រេចបង្កើតសុំកូនពេញលេញចូលជាស្ថាពរក៏ដោយ ក៏នៅមានលិខិតបទដ្ឋានដទៃទៀតបានកំណត់អំពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋានដែលមានលម្អិតនៅក្នុងអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានដែរ។ ក្នុងនោះដីកាសម្រេចបង្កើតសុំកូនពេញលេញ នឹងក្លាយជាមូលដ្ឋានគតិយុត្តយ៉ាងសំខាន់សម្រាប់កូនសុំ និងឪពុកម្តាយចិញ្ចឹមក្នុងការរៀបចំ និងកែប្រែអត្រានុកូលដ្ឋានកំណើតថ្មីដូចជាការធ្វើសំបុត្រកំណើតថ្មី និងសៀវភៅគ្រួសារថ្មីជាអាទិ៍។

ពេលបង្កើតសុំកូនហើយ កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនសុំកូនក៏បាន។ ឪពុកម្តាយចិញ្ចឹមដែលបានសុំកូនត្រូវទៅចុះបញ្ជីកំណើតថ្មីអោយកូនសុំនោះ ដែលបញ្ជីកំណើតថ្មី ត្រូវយកលេខចុះបញ្ជីពីសំបុត្រកំណើតចាស់របស់ក្មេង ដោយអាចធ្វើការផ្លាស់ប្តូរឈ្មោះ និងនាមត្រកូលរបស់កូនសុំ និងឈ្មោះឪពុកម្តាយចិញ្ចឹម តែមិនត្រូវសរសេរចូលពីអំពីការសុំកូនឡើយ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវរក្សាសំបុត្រកំណើតចាស់ ដោយបិទស្រោមសំបុត្រទុកតម្កល់ជាឯកសារនៅការិយាល័យរបស់ខ្លួន។ សំបុត្រកំណើតថ្មីរបស់កូនសុំ ត្រូវបញ្ចូលឈ្មោះឪពុកម្តាយចិញ្ចឹមក្នុងសំបុត្រកំណើតថ្មីដែលចេញអោយដោយមន្ត្រីអត្រានុកូលដ្ឋាន គឺមេឃុំ ឬចៅសង្កាត់នៃលំនៅដ្ឋានរបស់ឪពុកម្តាយចិញ្ចឹម។

### ១.៥.៤.៥. សិទ្ធិដឹងអំពីកំណើតខ្លួន

#### ក.ការដាក់ពាក្យសុំទៅតុលាការ

សុំកូនពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឲ្យបង្ហាញនូវព័ត៌មានក្នុងទំហំចាំបាច់ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្តីពីសុំកូនបាន។ ចំពោះការរក្សាទុកសំណុំរឿង និងទាមទារឲ្យបង្ហាញជាអាទិ៍ ត្រូវបានកំណត់នៅក្នុងបទបញ្ញត្តិរបស់តុលាការ។[18]

**គោលបំណងត្រឹមត្រូវ មានដូចខាងក្រោម៖**

- ធ្វើការបញ្ជាក់ ដោយសារតែមានបញ្ហាដោយភាគីដែលរៀបអាពាហ៍ពិពាហ៍ ការពិតជាបងប្អូនបង្កើត ឬសាច់ញាតិនឹងគ្នា
- ធ្វើការបញ្ជាក់ថា តើឪពុកម្តាយបង្កើតមានជម្ងឺតំណពូជដែរឬទេ?

[17]មាត្រា១០១៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[18]មាត្រា១០១៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**គោលបំណងមិនត្រឹមត្រូវមានះ**

– ទាមទារប្រាក់ពីឪពុកម្តាយបង្កើត។

**ខ. ការជួបប្រាស្រ័យទាក់ទងជាមួយឪពុកម្តាយបង្កើត និងញាតិលោហិត**

នៅក្នុងប្រទេសមួយចំនួន មានការអនុញ្ញាតឲ្យកូនសុំ បានស្គាល់គ្នាជាមួយនឹងឪពុកម្តាយបង្កើត បងប្អូនបង្កើត ឬញាតិលោហិតខាងឪពុកម្តាយបង្កើត ត្រូវបានគេបើកទូលាយពេលដែលកូនសុំមានអាយុដល់វ័យនីតិភាព។ ក្រៅពីនេះក៏មានប្រព័ន្ធរៀបចំឲ្យមាការជួបមុខគ្នាផ្ទាល់រវាងកូនសុំ និងឪពុកម្តាយបង្កើត បងប្អូនបង្កើត ឬញាតិលោហិតខាងឪពុកម្តាយបង្កើតផងដែរ ប្រសិនបើមានការយល់ព្រមព្រៀងជាលាយលក្ខណ៍អក្សរ ពីគ្រួសាររបស់ឪពុកម្តាយចិញ្ចឹម។

## ១.៦. ការកាត់កាលស្មុំកូនពេញលេញ

ការកាត់កាលស្មុំកូនពេញលេញ គឺជាការបញ្ចប់ទំនាក់ទំនងរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម និងទំនាក់ទំនងញាតិភាពរវាងកូនសុំ និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមបូករួមទាំងការកាត់ផ្តាច់ទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ចដូចជា អាហារកាតព្វកិច្ច និងសន្តតិកម្ម។ ការបង្កើតស្មុំកូនពេញលេញមានភាពស្មុគស្មាញ នឹងតាងតឹងជាងស្មុំកូនធម្មតាព្រោះស្មុំកូនពេញលេញសំដៅដល់ការបង្កើតទំនាក់ទំនងញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម ដោយអនុញ្ញាតិអោយកាត់ផ្តាច់ទំនាក់ទំនងញាតិភាពជាមួយឪពុកម្តាយបង្កើត និងញាតិភាពរបស់ឪពុកម្តាយបង្កើតទាំងស្រុង ដូច្នេះហើយទើបធ្វើអោយចំណងមួយនេះបើមានចេតនាចង់បញ្ចប ក៏មិនអាចបញ្ចប់បានដោយងាយស្រួលឡើយ។

### ១.៦.១.នីតិវិធីនៃការកាត់កាល

ការកាត់កាលស្មុំកូនពេញលេញ គឺចាំបាច់ត្រូវធ្វើឡើងតាមរយៈបណ្តឹងទាមទារអោយកាត់កាល ដែលតម្រូវអោយមានការដាក់ពាក្យបណ្តឹងទៅតាមផ្លូវតុលាការដោយអនុលោមតាម ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទង នឹងឋានៈបុគ្គល ។ ការកាត់កាលស្មុំកូនពេញលេញ មិនមែនសុទ្ធតែអាចធ្វើឡើងបានដោយបុគ្គលគ្រប់រូបឡើយ ព្រោះការកាត់កាលនាំអោយមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កុមារដែលជាកូនសុំ ដូច្នេះហើយអ្នកដែលមានសិទ្ធិដាក់ពាក្យបណ្តឹងស្នើសុំកាត់កាលស្មុំកូននេះបាន បុគ្គលមានសិទ្ធិនោះត្រូវតែជាអ្នកដែលបានគិតគូរយ៉ាងល្អិតល្អន់ពីផលប្រយោជន៍របស់កូនសុំ និងជាអ្នកដែរមានទំនាក់ទំនងការពារសិទ្ធិរបស់កូនសុំ បុគ្គលនោះត្រូវជាះ

- ក្នុងករណីកូនសុំជាដើមចោទ នោះឪពុកម្តាយចិញ្ចឹមជាសហចុងចម្លើយ។ [19]

[19] មាត្រា៣ ចំណុចជ ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១

- ក្នុងករណីឪពុកម្តាយបង្កើតជាដើមចោទ នោះឪពុកម្តាយចិញ្ចឹមជាចុងចម្លើយ ។[20]
- ក្នុងករណីតំណាងអយ្យការជាដើមចោទ នោះឪពុកម្តាយចិញ្ចឹមជាសហចុងចម្លើយ។ [21]

ការកាត់កាល់កូនស្មុំអាចធ្វើទៅបានលុះត្រាតែតុលាការយល់ឃើញថា ការកាត់កាលកូនសុំពេញលេញនេះមានភាពចំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កុមារ និងករណីមួយចំនួនដូចជា មានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹមដូចជា វាយដំ ធ្វើទារុណកម្មយ៉ាងសាហាវលើកុមារ ករណីឪពុកម្តាយចិញ្ចឹមមិនមានលទ្ធភាពចិញ្ចឹម រួមទាំងបោះបង់ចោលកូនសុំដោយគំនិតទុច្ចរិត ឬហេតុផលផ្សេងៗ ទៀតដែលបំពានផលប្រយោជន៍របស់កូនសុំ។[22] បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យបាន ។ ក្នុងករណីដែលឪពុកម្តាយបង្កើតមានស្ថានភាពគ្រួសារមួយដែលល្អប្រសើរជាពីមុន ឬមានជីវភាពធូរធារអាចមានលទ្ធភាពនៅក្នុងការគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាកូនបានដោយខ្លួនឯង។[23]

### ១.៦.២.អានុភាពនៃការកាត់កាលស្មុំកូនពេញលេញ

អានុភាពនៃការកាត់កាលស្មុំកូនពេញលេញ បាននាំអោយមានទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើត និងកូនស្មុំត្រូវតភ្ជាប់ឡើងវិញដោយស្វ័យប្រវិត្ត គឺបានន័យថានៅពេលដែលសាលក្រមបានចូលជាស្ថាពរ អ្វីៗនឹងត្រឡប់ទៅជាសភាពដើមវិញ ដូចមុនពេលដែលការស្មុំកូនពេញលេញត្រូវបានបង្កើតដែលបានរៀបរាប់ដូចខាងក្រោម។

#### ១.៦.២.១ អានុភាពចំពោះឪពុកម្តាយចិញ្ចឹម

ក្រោយពីស្មុំកូនពេញលេញ បានរំលាយហើយនោះញាតិភាពរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម រួមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមត្រូវបានបញ្ចប់ទាំងស្រុង មានន័យថា ទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម និងកូនត្រូវបានរលត់តាមផ្លូវច្បាប់ បន្ថែមពីនេះទៀតទំនាក់ទំនងញាតិលោហិតផ្សេងៗទៀតរបស់ឪពុកម្តាយចិញ្ចឹម និងកូនសុំក៏ត្រូវរលត់ដូចគ្នា ហើយកូនសុំត្រូវមិនស្ថិតក្រោមអំណាចមេបារួមរបស់ឪពុកម្តាយចិញ្ចឹមទៀតនោះទេ។

ក្រៅពីទំនាក់ទំនងតាមផ្លូវច្បាប់ ទ្រព្យសម្បត្តិក៏មានអានុភាពកើតឡើងដែរ មានន័យថាកូនសុំលែងជាបុគ្គលដែលមានសិទ្ធិក្នុងការបន្តសន្តិតិកម្មលើទ្រព្យរបស់ឪពុកម្តាយចិញ្ចឹម និងញាតិរបស់ឪពុកម្តាយទៀត

[20] មាត្រា៧ ចំណុច១ ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១

[21] មាត្រា៧ ចំណុច៣ ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១

[22] មាត្រា១០១៦ ចំណុច ក ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[23] មាត្រា១០១៦ ចំនុច ខ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ហើយ ចំណែកឯឪពុកម្តាយចិញ្ចឹម និងញាតិរបស់ឪពុកម្តាយក៏មិនអាចធ្វើសន្តិតិម្មលើមត៌ករបស់កូនសុំវិញបានដូចគ្នា។

### ១.៦.២.២. អានុភាពចំពោះឪពុកម្តាយបង្កើត

ដោយសារតែការសុំកូនពេញលេញ ត្រូវបានបញ្ចប់ដោយសាលក្រមរបស់តុលាការ អានុភាពនៃញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ត្រូវបានកើតឡើងវិញដោយស្វ័យប្រវត្តិគិតចាប់ពីថ្ងៃកាត់កាលនោះ។ ម្យ៉ាងទៀតកូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយបង្កើតវិញ បន្ថែមពីនេះទៀតកូនសុំអាចផ្លាស់ប្តូរនាមត្រកូលមកដាក់នាមត្រកូលរបស់ឪពុកម្តាយបង្កើតបានផងដែរ។ ហេតុនេះហើយសំបុត្រកំណើតចាស់របស់កូនដែលបានរក្សាទុកដោយមន្ត្រីអត្រានុកូលដ្ឋានមុនបង្កើតសុំកូនអាចត្រូវបានយកមកប្រើប្រាស់វិញ។ ទំនាក់ទំនងលើទ្រព្យសម្បត្តិរវាងឪពុកម្តាយបង្កើត និងកូនត្រូវបានតភ្ជាប់វិញផងដែរ ព្រមទាំងសិទ្ធិធ្វើសន្តិកម្មលើទ្រព្យសម្បត្តិរបស់ញាតិលោហិតផ្សេងទៀតរបស់ឪពុកម្តាយបង្កើត ពោលគឺឪពុកម្តាយបង្កើត និងកូន ក្លាយជាសន្តិតិជនម្តងទៀត។

ការបង្កើតបុត្តភាពមួយតាមរយៈសុំកូនដើម្បីឱ្យ មានទំនាក់ទំនងញាតិរវាងកូនសុំនិងឪពុកម្តាយចិញ្ចឹម ដូចជាញាតិ នៃឪពុកម្តាយបង្កើតដែរ។ នៅក្នុងនេះយើងបានដឹងអំពីប្រភេទនៃសុំកូន ហើយដឹងអំពីលក្ខខណ្ឌនៃសុំកូនពេញលេញ ដែលមានទាក់ទងនឹងលក្ខខណ្ឌអាយុរបស់ឪពុកម្តាយចិញ្ចឹម និង លក្ខខណ្ឌអាយុរបស់កូនសុំ ស្ថានភាពលំបាករបស់ឪពុកម្តាយបង្កើតដែលមិនអាចចិញ្ចឹមកូនបាន និងបណ្តាលមកពីមូលហេតុផ្សេងទៀត ដែលចាំបាច់ហើយដើម្បីផលប្រយោជន៍កុមារ ទើបនាំឱ្យមានការសុំបាន ។ នៅក្នុងនេះដែរ ក៏បានដឹងអំពីការវិនិច្ឆ័យរបស់តុលាការទាក់ទងនឹងសុំកូនពេញលេញនេះ ថាតើមូលហេតុ ឬស្ថានភាពបែបណា ដែលអាចឱ្យឪពុកម្តាយចិញ្ចឹមសុំកូនមកចិញ្ចឹមបាន ។ កាលណាដែលសុំបានមក គឺយើងក៏បានដឹងពីអានុភាពនៃសុំកូនពេញលេញ ហើយក៏បានដឹងអំពីការកាត់កាល់ និងអានុភាពនៃការកាត់កាល់ផងដែរ ។

# ជំពូកទី២ ស្មុំកូនធម្មតា

នៅក្នុងការបង្កើតស្មុំកូនធម្មតា គឺមានលក្ខណៈ និងចំណុចដូចគ្នាច្រើនទៅ និងការបង្កើតស្មុំកូនពេញលេញ វាមានភាពខុសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ។ ការតម្រូវឲ្យឆ្លងកាត់តុលាការ វាជាភាពចាំបាច់ ព្រោះកម្មវត្ថុនៃស្មុំកូនកូនធម្មតា អាចជានីតិជន ឬអនីតិជន ហើយការកំណត់បែបនេះ ដើម្បីឲ្យការស្រាវជ្រាវ និងវិនិច្ឆ័យដោយប្រុងប្រយ័ត្នអំពីផលប្រយោជន៍របស់។

## ២.១.លក្ខខណ្ឌនៃការបង្កើតស្មុំកូនធម្មតា

លក្ខខណ្ឌនៃការស្មុំកូនធម្មតាក៏មិនខុសពីលក្ខខណ្ឌនៃការបង្កើតស្មុំកូនពេញលេញប៉ុន្មានដែរ មានដូចជាអាយុរបស់ឪពុកម្ដាយចិញ្ចឹម និងកូនសុំ ការចូលរួមរបស់សហព័ទ្ធម្ខាងរបស់បុគ្គលដែលនឹងក្លាយទៅជាឪពុកម្ដាយ ឬម្ដាយចិញ្ចឹមក្នុងករណីយបុគ្គលនោះមានសហព័ទ្ធ ការចូលរួមរបស់ឪពុកម្ដាយបង្កើត និងមូលដ្ឋានវិនិច្ឆ័យរបស់តុលាការដែលនឹងពិចារណា។

### ២.១.១. អាយុ និងស្ថានភាពរបស់ឪពុកម្ដាយចិញ្ចឹម

បុគ្គលដែលអាចនិងក្លាយទៅជាឪពុកម្ដាយ ឬឪពុក ឬម្ដាយ ចិញ្ចឹមរបស់កូនស្មុំធម្មតាត្រូវបមានអាយុ ចាប់ពី ២៥(ម្ភៃប្រាំ) ឆ្នាំឡើងទៅ ទើបអាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំទៅ តុលាការ អោយបង្កើតកូនស្មុំកូនធម្មតាបាន។[24] ប៉ុន្តែបុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនិងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬបុគ្គលដែលមានអាយុច្រើនជាងបុគ្គលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ។ ក្នុងករណីយបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន អ្នកមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជនត្រូវដាក់ពាក្យសុំដែលបានកំណត់ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ក្នុងមាត្រា១០២០នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។[25]

ស្មុំកូនធម្មតា អាចបង្កើតបានទោះបីជាបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមមាន ឬគ្មានសហព័ន្ធក៏ដោយ។ ប៉ុន្តែប្រសិនបើភាគីម្ខាងបានដាក់ពាក្យជាមួយសហព័ទ្ធម្ខាងទៀត ឬសហព័ទ្ធម្ខាងទៀតមិនអាចបង្ហាញឆន្ទៈយល់ព្រមបាន នោះ ស្មុំកូនធម្មតាអាចបង្កើតបាន។ បើបុគ្គលដែលមានសហព័ន្ធសុំកូនជាអនីតិជន បុគ្គលនោះត្រូវដាក់ពាក្យសុំរួមគ្នាជាមួយសហព័ន្ធទើបអាចបង្កើតស្មុំកូនធម្មតាបាន។ ប៉ុន្តែក្នុងករណីយកកូនរបស់សហព័ន្ធមកធ្វើជាកូនសុំ ឬសហពទ្ធ័ម្ខាងទៀតមិនអាចបង្ហាញឆន្ទៈបាន ស្មុំកូនអាចបង្កើតឡើងបានត្រឹមតែអ្នកដាក់ពាក្យសុំតែម្ខាងប៉ុណ្ណោះ។

---

[24] មាត្រា១០២០ វាក្យខ័ណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[25] មាត្រា១០២០ វាក្យខ័ណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ២.១.២. អាយុ និងស្ថានភាពរបស់កូនសុំ

ដោយនៅក្នុងលក្ខខណ្ឌស្មុំកូនធម្មតាមិនបានកំណត់ជាដាច់ខាតឡើយពីអាយុរបស់នៃកូនសុំ ដូច្នេះកូនសុំអាចជាអនីតិជន ឬនីតិជន ប៉ុន្តែចំនុចសំខាន់មិនត្រូវអោយបុគ្គលដែលនឹងក្លាយជាកូនសុំមានអាយុច្រើនជាងបុគ្គល ដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ។

ករណីបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន តុលាការអាចបង្កើតស្មុំកូនបាន លុះត្រាតែយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជននោះ។[26] នៅក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន បើឪពុកម្តាយបង្កើតរបស់បុគ្គលនោះបានលែងលះ ហើយតុលាការត្រូវសួរយោបល់របស់ឪពុកឬម្តាយដែលមិនមានអំណាចមេបា ដើម្បីវិនិច្ឆ័យ អំពីចំនុចដែលបានកំណត់ខាងលើ យោងតាមមាត្រា១០២៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។[27] ប៉ុន្តែបើសិនជាអនីតិជនមានអាយុដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ដើម្បីបង្កើតការស្មុំកូន ត្រូវទទួលការយល់ព្រមពីអនីតិជននោះ។[28] ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ១៥ (ដប់ប្រាំ) ឆ្នាំក៏ដោយបើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើ។

## ២.២. នីតិវិធីនៃការបង្កើតស្មុំកូនធម្មតា

នីតិវិធីនៃការបង្កើតស្មុំកូនធម្មតា គឺមានចំណុចភាគច្រើនដូចទៅនឹង នីតិវិធីតុលាការចំពោះការបង្កើស្មុំកូនពេញលេញដែរ វាមានភាពខុសគ្នាតិចតួចត្រង់ចំណុចខ្លះ។ ការឆ្លងកាត់តុលាការវាមានភាពចាំបាច់ណាស់សម្រាប់ការបង្កើតការស្មុំកូនធម្មតា ដើម្បីអោយការស្មុំកូននោះមានលក្ខណៈពេញលេញ នឹងស្របទៅតាមច្បាប់ ហើយការកំណត់បែបនេះ ដើម្បីអោយមានការស្រាវជ្រាវ នឹងការវិនិច្ឆ័យយ៉ាងប្រុងប្រយ័ត្នអំពីផលប្រយោជន៍របស់កុមារ។

### ២.២.១. ការដាក់ពាក្យសុំទៅតុលាការ

ដើម្បីបង្កើតស្មុំកូនធម្មតា ត្រូវដាក់ពាក្យសុំទៅតុលាការ ដោយតម្រូវអោយបុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹម និង បុគ្គលដែលនឹងក្លាយជាកូនសុំត្រូវដាក់ពាក្យសុំរួមគ្នាទៅតុលាការ និងបង្ហាញពីឆន្ទៈរបស់ភាគីទាំងសងខាងអោយបានច្បាស់លាស់ក្នុងការបង្កើតការស្មុំការធម្មតា(ច្បាប់ស្តីពីនីតិវិធី

[26] មាត្រា១០២៤ វាក្យខ័ណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[27] មាត្រា១០២៤ វាក្យខ័ណ្ឌទី២ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[28] មាត្រា១០២៤ វាក្យខ័ណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

នៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង)។[29] ទីកន្លែងនៃការដាក់ពាក្យសុំត្រូវធ្វើនៅតុលាការ ខាងលំនៅដ្ឋានរបស់បុគ្គលដែលនឹងក្លាយទៅជាកូនសុំ។ ចំពោះទម្រង់នៃការដាក់ពាក្យសុំ និងពន្ធដែលត្រូវបង់នៅពេលដែលដាក់ពាក្យសុំកូនធម្មតា គឺដូចគ្នាទៅនឹងនីតិវិធីសុំកូនពេញលេញដែរ ត្រូវអនុវត្តដូចគ្នា។

### ២.២.២. ដីកាសម្រេចរបស់តុលាការ

តុលាការធ្វើការវិនិច្ឆ័យដើម្បីចេញដីការសម្រេចបង្កើតសុំកូនធម្មតាដោយផ្អែកទៅលើលក្ខខណ្ឌដូចជា៖

- មានការបង្ហាញឆន្ទៈពិតប្រាកដរបស់ភាគីដែលនឹងក្លាយជាឪពុកម្ដាយ និងកូនសុំ ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយនិងកូន។
- តុលាការមិនត្រូវអោយបង្កើតសុំកូនបានឡើយ បើយល់ឃើញថាសុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ រវាងភេទដូចគ្នា ឬភេទផ្សេងគ្នា ឬក្នុងគោលបំណងផ្សេងទៀត ដែលមិនត្រឹមត្រូវ។
- អ្នកដែលក្លាយទៅជាឪពុកម្ដាយចិញ្ចឹម ត្រូវមានអាយុចាប់ពី២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅ ។
- អ្នកដែលនិងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិ ឬក៏មានអាយុច្រើនជាងអ្នកដែលនឹងក្លាយទេជាឪពុកម្ដាយចិញ្ចឹមបានឡើយ។
- សុំកូនដោយអ្នកមានសហព័ទ្ធ ត្រូវមានការមានការសហការជាមួយសហព័ទ្ធដើម្បីដាក់ពាក្យសុំកូនដែលកូនសុំនោះជាអនីតិជន។ ជនដែលមានសហព័ទ្ធ ដើម្បីសុំកូនធម្មតាត្រូវមានការយល់ព្រមពីសហពទ្ធ័ គឺដោយសារតែតាមរយៈការសុំកូនធម្មតានេះមាន អាចមានឥទ្ធិពលទៅលើជីវភាពរស់នៅជាក់ស្ដែងដូចជាសន្ដតិកម្ម អាហារកាតព្វកិច្ច ត្រកូលជាដើម។ ករណីកូនសុំជាអនីតិជន តុលាការទទួលស្គាល់នូវសុំកូននេះតែក្នុងករណីដែលមានភាពចាំបាច់ដើម្បីផលប្រយោជន៍របស់អនីតិជនប៉ុណ្ណោះ។
- សុំកូនរវាងអាណាព្យាបាល និងអ្នកស្ថិតនៅក្រោមអាណាព្យាបាល តុលាការទទួលស្គាល់បាន តែក្នុងករណីយដែលបានអនុវត្តត្រឹមត្រូវក្នុងការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិប៉ុណ្ណោះ។ សម្រាប់លក្ខខណ្ឌខាងលើ ដែលតុលាការនឹងលើកយកមកពិចារណា និងធ្វើការវិនិច្ឆ័យ ដើម្បីចេញដីការសម្រេចអោយបង្កើតសុំកូនធម្មតាបាន គឺផ្អែកទៅតាមក្រមរដ្ឋប្បវេណី មាត្រា ១០២០ ១០២១ ១០២២ ១០២៣ ១០២៤ ១០២៥ ឆ្នាំ២០០៧។[30]

[29] មាត្រា២៦ ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង

[30] មាត្រា១០២០ ១០២១ ១០២២ ១០២៣ ១០២៤ ១០២៥ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- ប្រសិនបុគ្គលដែលមានបំណងចង់បង្កើតសុំកូនធម្មតា ហើយបានបំពេញនូវលក្ខខណ្ឌដែលបានរៀបរាប់ នឹងត្រឹមត្រូវសព្វគ្រប់ហើយ នឹងតុលាការបានពិចារណា ថាមានផលប្រយោជន៍ដល់បុគ្គលដែលនឹងក្លាយជាកូនសុំនោះតុលាការ និងចេញដីការសម្រេចអោយបង្កើតសុំកូនធម្មតាបាន។

## ២.៣.អានុភាពនៃសុំកូនធម្មតា

ក្រោយពីការសុំកូនធម្មតាបានសម្រេចចូលជាស្ថាពរ នោះអានុភាពមួយចំនួនបានកើតឡើង ដោយនៅក្នុងនោះមានដូចជា ការចុះបញ្ជីកំណើត និងបញ្ជីកំណើត និង ការបង្កើតញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម និងការបន្តញាតិភាពជាមួយឪពុកម្តាយបង្កើត ជាដើម។[31]

### ២.៣.១.ការចុះបញ្ជី និងបញ្ជីកំណើត

ក្នុងករណីសុំកូនធម្មតា មិនមែនជាការផ្តាច់ទំនាក់ទំនងគតិយុត្តជាមួយឪពុកម្តាយបង្កើតនោះទេ ដូច្នេះមិនចាំបាច់មានការលាក់បាំងជាសាធារណៈនូវការសុំកូនឡើយ គឺមិនដូចសុំកូនពេញលេញដែលត្រូវលាក់ការសម្ងាត់ពីការសុំកូនឡើយ។ ការចុះបញ្ជីកំណើត និងលិខិតបញ្ជាក់កំណើត និងអត្រានុកូលដ្ឋាន ត្រូវសរសេរការបង្កើតសុំកូនធម្មតា នៅលើរឹមទំព័រនៃអត្រានុកូលដ្ឋាន និងសំបុត្រកំណើតដើមរបស់កូនសុំនោះ(មាត្រា១០៣៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)។[32]

### ២.៣.២. ការបង្កើតញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម

ដូចគ្នានឹងសុំកូនពេញលេញដែរ ក្រោយពីការបង្កើតសុំកូន ញាតិភាពរវាងឪពុកម្តាយចិញ្ចឹមក៏ត្រូវបានបង្កើតឡើង ដោយកូនសុំមានឋានៈដូចគ្នាជានឹងកូនបង្កើតនៃឪពុកម្តាយចិញ្ចឹមផងដែរ ដោយត្រូវទទួលបានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពូកម្តាយចិញ្ចឹម។[33] កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលរបស់ឪពុកម្តាយបង្កើត មុនសុំកូនក៏បាន។ កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម។ ប៉ុន្តែក្នុងករណីដែលកូនបង្កើតរបស់សហព័ទ្ធមកធ្វើជាកូនសុំ កូនសុំត្រូវស្ថិតក្រោមអំណាចមេបារួមរបស់ឪពុក ឬម្តាយចិញ្ចឹមរបស់សហព័ទ្ធនោះ។

### ២.៣.៣. ការបន្តញាតជាមួយឪពុកម្តាយបង្កើត

[31] មាត្រា១០២៦ នៃ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[32] មាត្រា១០៣៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[33] មាត្រា១០២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដោយស្មុំកូនធម្មតាមានភាពខុសគ្នានឹងស្មុំកូនពេញលេញត្រង់ថា ស្មុំកូនធម្មតានៅតែអាចបន្តញាតិភាពជាមួយឪពុកម្តាយបង្កើតបាន ហេតុនេះកូនសុំនិងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មអោយគ្នាទៅវិញទៅមក ហើយក៏មានសិទ្ធិទាមទារ និងករណីកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកផងដែរ។ គេអាចនិយាយបានថាស្មុំកូនធម្មតា កូនសុំនោះគឺមានទាំងឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង ហេតុនេះទំនាក់ទំនងសិទ្ធិធ្វើសន្តតិកម្មទៅវិញទៅមកនៅតែមាន។ ក្នុងករណីកូនសុំជាអនីតិជន អ្នកមានអំណាចមេបាលើកូនសុំគឺឪពុកម្តាយចិញ្ចឹម។[34]

## ២.៤.ការកាត់កាលកូនស្មុំធម្មតា

ការកាត់កាល់ស្មុំកូនធម្មតា មានមូយលហេតុជាច្រើននៃការកាត់កាល់ស្មុំកូននេះ តុលាការជាអ្នកសម្រេចក្នុងការអនុញ្ញាតឲ្យការកាត់កាល់បាន ឬមិនអាចកាត់កាល់បានរវាងឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹម ដោយពិចារណាយ៉ាងល្អិតល្អន់ទៅលើមូលហេតុនៃការកាត់កាល់ និងផលប្រយោជន៍របស់កូនសុំ ដែលជាអនីតិជន ឬនីតិជន។

ការកាត់កាល់ គឺសំដៅដល់ការបោះបង់ លែងរាប់អានទៅទៀត គឺមានន័យថាបើមានពាក្យសុំកាត់កាល់ស្មុំកូនធម្មតា តុលាការអាចសម្រេចអោយ កាត់កាល់បានក្នុងករណីដែលភាគីទាំងសងខាងមានបំណងពិតប្រាកដមែន ក្នុងការរំលាយទំនាក់ទំនងឪពុកម្តាយ នឹងកូន ដោយយោងតាមមាត្រ១០៣០នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។[35] លើសពីនេះបុគ្គលដែលអាចដាក់ពាក្យបណ្តឹងទាមទារការកាត់កាល់បាន លុះត្រាតែភាគីម្ខាងទៀតបានប្រព្រឹត្តដូចក្នុងបញ្ញត្តិនៃ មាត្រា១០៣១នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែលចែងពីមូលហេតុនៃការកាត់កាល់ស្មុំកូនធម្មតានេះ។[36]

### ២.៤.១. មូលហេតុនៃការកាត់កាល់ស្មុំកូនធម្មតា

មូលហេតុនៃការកាត់កាល់មានពីរករណី

ករណីទី១ ការកាត់កាល់តាមការព្រមព្រៀង គឺជាការកាត់កាល់ដែលភាគីទាំងសងខាង(ឪពុកម្តាយចិញ្ចឹម និងកូនសុំ) បានព្រមព្រៀង ហើយដាក់ពាក្យសុំកាត់កាល់ទៅតុលាការ ហើយតុលាការបានធ្វើការវិនិច្ឆ័យឲ្យមានការកាត់កាល់។ ករណីដែលបានពិនិត្យឃើញថា ភាគីទាំងសងខាងមានឆន្ទៈ ពិតប្រាកដចង់រំលាយចោលនូវទំនាក់ទំនងជាឪពុកម្តាយចិញ្ចឹម និងកូនសុំ តុលាការត្រូវសម្រេចឲ្យកាត់កាល់។

[34] មាត្រា១០២៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[35] មាត្រា១០៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[36] មាត្រា១០៣៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ករណីទី២ ការកាត់កាល់តាមផ្លូវតុលាការ គឺជាការកាត់កាល់ដែលពុំមានការព្រមព្រៀងរវាងភាគីស្តីពីការកាត់កាល់ ហើយភាគីណាម្ខាងប្តឹងទាមទារឲ្យមានការកាត់កាល់ជាមួយភាគីម្ខាងទៀត ហើយតុលាការចេញសាលក្រមកាត់កាល់។ ការកាត់កាលនេះ គឺជាការកាត់កាល់ដោយបង្ខំចំពោះភាគីម្ខាងទៀត ដែលគ្មានបំណងចង់កាត់កាល់ ដូច្នេះទាល់តែមានមូលហេតុធ្ងន់ធ្ងរដូចជា៖

- ករណីដែលមានការបោះបង់ដោយទុច្ចរិត។
- ករណីដែលមិនដឹងថានៅរស់ ឬទទួលមរណភាព ក្នុងអំឡុងពេលមួយឆ្នាំឡើងទៅ។
- ករណីដែលមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលធ្វើឲ្យពិបាកក្នុងការបន្តសុំកូន។[37]

### ២.៤.២.ពាក្យសុំកាត់កាល់សុំកូនធម្មតា

ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាកាឲ្យកាត់កាល់សុំកូនធម្មតាបាន ក្នុងករណីដែលភាគីសងខាងព្រមព្រៀងអំពីការកាត់កាល់នេះ។[38] ក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំកាត់កាល់ត្រូវធ្វើឡើងដោយមានការព្រមព្រៀងគ្នានោះ ត្រូវធ្វើឡើងដោយឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់។ ប៉ុន្តែបើកូនសុំនោះមានអាយុ១៥ (ដប់ប្រាំ)ឆ្នាំហើយត្រូវទទួលបានការយល់ព្រមពីកូនសុំនោះ។ ទោះបីជាអនីតិជនមិនទាន់ដល់អាយុ១៥ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាននោះតុលាការត្រូវសួរយោបល់របស់អនីតិជននោះផងដែរ។[39] ក្នុងករណីដែលឪពុកម្តាយបង្កើតរបស់កូនសុំបានលែងលះគ្នាហើយឪពុកម្តាយបង្កើតរបស់កូនសុំនោះត្រូវពិភាក្សាគ្នា និងកំណត់ថាឪពុក ឬម្តាយបង្កើតជាអ្នកដែលត្រូវក្លាយជាអ្នកមានអំណាចមេបាក្រោយពេលកាត់កាល់ ប៉ុន្តែបើការពិភាក្សាខាងលើ ពុំបានសម្រេច ឬពុំពិភាក្សាបាន តុលាការត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបាដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូនសុំ។[40]

---

[37] មាត្រា១០៣១ វាក្យខ័ណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[38] មាត្រា១០២៨ វាក្យខ័ណ្ឌទី១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[39] មាត្រា១០២៨ វាក្យខ័ណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[40] មាត្រា១០២៨ វាក្យខ័ណ្ឌទី៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ២.៤.៣.អានុភាពនៃការកាត់កាល់សុំកូនធម្មតា

ដោយអានុភាពទាំងឡាយនៃសុំកូនធម្មតា ត្រូវបានបញ្ចប់នៅពេលអនាគតដោយការកាត់កាល់នេះ។[41] ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញនូវនាមត្រកូលមុនសុំកូនក៏បាន ឬអាចប្រើប្រាស់នាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន។[42]

ជារួមមក សម្រាប់ការបង្កើតសុំកូនធម្មតា មានលក្ខខណ្ឌដូចគ្នាច្រើនទៅនិងការបង្កើតសុំកូនពេញលេញដែរ ។ ដែលជាភាពចាំបាច់ត្រូវបំពេញនៅលក្ខខណ្ឌ និងធ្វើទៅតាមនីតិវិធីដែលបានរៀបរាប់ខាងលើនេះ ដើម្បីឲ្យសុំកូនធម្មតានេះមានលក្ខណៈពេញលេញ និងស្របទៅតាមច្បាប់ដែលបានកំណត់ និងមានអានុភាពគ្រប់គ្រាន់ ដើម្បីឲ្យឪពុកម្ដាយចិញ្ចឹមមានសិទ្ធិ និងករណីកិច្ចជាមួយគ្នាទៅវិញទៅមក ដោយពុំអាចរំលងនៅចំនុចណាមួយណាឡើយ។

[41] មាត្រា១០៣វាក្យខ័ណ្ឌទី១២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[42] មាត្រា១០៣២វាក្យខ័ណ្ឌទី២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី៣ ស្មុំកូនអន្តរប្រទេស

នីតិវិធីក្នុងការបង្កើតស្មុំកូនអន្តរប្រទេស គឺមានភាពស្មុគស្មាញ និងមានជាច្រើនដំណាក់ ដែលជាលក្ខខណ្ឌត្រម្រូវឲ្យអ្នកសុំត្រូវតែអនុវត្តតាម ដោយពុំអាចរំលងនៅនីតិវិធី ឬលក្ខខណ្ឌណាមួយបានឡើយ

គោបំណងនៃស្មុំកូនអន្តរប្រទេសនេះ គឺដើម្បីឧត្តមប្រយោជន៍ និងការការពារសិទ្ធិជាមូលដ្ឋានរបស់កុមារគ្រប់រូបត្រូវទទួលបាននូវការរីកចម្រើននៅក្នុងមជ្ឈដ្ឋានថ្មីនៅក្នុងគ្រួសារថ្មី ដែលគប្បីត្រូវទទួលបាននូវសុភមង្គល ការស្រលាញ់យកចិត្តទុកដាក់ សេចក្តីសុខពីឪពុកម្តាយថ្មីដែល ជាអ្នកសុំ ដើម្បីឲ្យកុមារមានការអភិវឌ្ឍពេញលេញស្របទៅតាមបុគ្គលិកលក្ខណៈរបស់ខ្លួន ជាពិសេស គឺកុមារទទួលបានការមើលថែទាំពីមនុស្សជុំវិញខ្លួន។

## ៣.១.គោលការទូទៅនៃស្មុំកូនអន្តរប្រទេស

ស្មុំកូនអន្តរប្រទេសនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការបន្តពង្រឹងគោលនយោបាយរបស់រដ្ឋាភិបាលក្នុងគោលដៅមនុស្សធម៌សុទ្ធសាធ ដើម្បីរកគ្រួសារល្អឲ្យកុមារ និងធានាឧត្តមប្រយោជន៍របស់កុមារ ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយប្រទេសនានា ដើម្បីទប់ស្កាត់ការជួញដូរកុមារ។ ជួយសម្រាលបន្ទុកដល់អាជ្ញាធរសាធារណៈ ក្នុងការមើលថែទាំកុមារដែលគ្មានគ្រួសារ និងគ្មានមធ្យោបាយទ្រទ្រង់ជីវិត។

ភាពចាំបាច់នៃការបង្កើតស្មុំកូនអន្តរប្រទេស គឺត្រូវមានភាពដាច់ខាតនូវគោលការណ៍មូលដ្ឋាន ដែលជាសសរគ្រឹះនៃរបបស្មុំកូន បើមិនដូចច្នេះទេ ទោះបីមានដំណើរការក្នុងការស្មុំកូនរហូតដល់ចប់បរិបូរណ៍ក៏ឥតន័យដែរ គឺពិតជាមិនបានបង្ហាញថា ការធានាដល់ឧត្តមប្រយោជន៍របស់កុមារថាពិតជាកើតមាននោះទេពិសេស គឺប្រឈមមុខនឹងការបរាជ័យ ឬការបញ្ឈប់ការស្មុំកូនអន្តរប្រទេសជាក់ជាមិនខាន។

ស្មុំកូនអន្តរប្រទេសត្រូវអនុវត្តតាមគោលការណទូទៅដូចជា៖

**១.** កុមារត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ និងបរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់ដើម្បីឲ្យមានការអភិវឌ្ឍពេញលេញ និងយ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់ខ្លួន។ ស្មុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឲ្យកុមាររស់នៅក្នុងគ្រួសារកំណើត និងក្រោយពីបានធ្វើការពិចារណា អំពីស្មុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**២.** ស្មុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាតែជាស្មុំកូនពេញលេញដែលបង្កើតទំនាក់ទំនាក់ទំនងរវាងអ្នកសុំ និង កូនសុំជាអចិន្ត្រៃយ៍ និងផ្តល់ដល់កុមារនូវឋានៈ សិទ្ធ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ។

៣. កុមារទាំងឡាយដែលបានបំពេញនូវលក្ខខណ្ឌ ដូចបានចែងក្នុងមាត្រា១០អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបាន ដោយមិនមានការរើសអើងអំពើពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិកំណើត ឋានៈក្នុងសង្គម ធនធាន ពិការភាពឬស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬឪពុកម្តាយ ឬ របស់ឪពុក ឬ របស់ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនិតិជនរបស់កុមារ ។

៤. រាល់ការសម្រេច និង សកម្មភាពទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេសត្រូវគិតគូរឲ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ។

៥. តុលាការ និង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធនៃដំណើរការសុំកូនអន្តរប្រទេសត្រូវធានាថា នៅពេលកំពុងដំណើរការនីតិវិធីសុំកូន កុមារដែលមានសមត្ថភាពអាចដឹងខុសត្រូវ ត្រូវបានពិគ្រោះយោបល់ នឹងពន្យល់ណែនាំឲ្យបានត្រឹមត្រូវអំពីអានុភាពនានា ដែលកើតចេញពីសុំកូននេះដោយគិតគូរដល់សេចក្តីប្រាថ្នានិងឧត្តមប្រយោជន៍របស់កុមារ។

៦. ហាមការធ្វើអាជីវកម្ម ឬការធ្វើសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេសសុំកូន។ អាជីវកម្ម ឬសកម្មភាពយកកម្រៃពីសុំកូនអន្តរប្រទេសមាន៖ អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬឪពុក ឬម្តាយបង្កើតបោះបង់ទារកដែលទើបនឹងកើតមកហើយ ឬដែលនឹងកើតដើម្បីឲ្យប្រគល់កូនតាម រយៈសុំកូនអន្តរប្រទេស។ អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងឪពុក ឬម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត។ អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងស្ត្រីម្នាក់យល់ព្រមពពោះដើម្បី នឹងប្រគល់កូននោះទៅឲ្យអ្នកសុំ។

៧. អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ពន្ធ័ក្នុងនីតិវិធីសុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការសុំកូនអន្តរប្រទេសមិនបណ្តោយឲ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និងត្រូវបង្ការមិនឲ្យមានការចាប់ពង្រត់ ការលក់ នឹងការជួញដូរកុមារក្នុងកំឡុងពេលធ្វើដំណើរការសុំកូនអន្តរប្រទេស។ មានតែប្រាក់ចំណាយ សោហ៊ុយ និង វិភាគ ដែលកំណត់នៅក្នុងបទបញ្ញត្តិនៃច្បាប់នេះត្រូវបង់។[43]

## ៣.២.លក្ខខណ្ឌតម្រូវនៃការបង្កើតសុំកូនអន្តរប្រទេស

ការបង្កើតសុំកូនអន្តរប្រទេសមួយបាន លុះត្រាតែបានបំពេញនូវលក្ខខណ្ឌ ដែលច្បាប់បានកំណត់គ្រប់គ្រាន់ ត្រឹមត្រូវតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ ដូច្នេះ គួរស្វែងយល់ពីលក្ខខណ្ឌដែលមានចែងនៅក្នុង

[43] មាត្រា៥ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសជាចម្បង ដោយចាប់ផ្តើមពីលក្ខខណ្ឌសម្រាប់កូនសុំ និង លក្ខខណ្ឌសម្រាប់អ្នកសុំ។

### ៣.២.១.លក្ខខណ្ឌសម្រាប់កូនសុំ

កុមារជាកម្មវត្ថុនៃស្មុំកូនអន្តរប្រទេស ត្រូវឆ្លើយតបទៅនឹងលក្ខខណ្ឌដូចខាងក្រោម[44]៖

១.កុមារដែលមានសញ្ជាតិខ្មែរដែលមានលំនៅដ្ឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។ ២.កុមារមានអាយុក្រោម ៨(ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យ សុំលើកលែងតែក្នុងករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអនុញ្ញាតបានដល់អាយុក្រោម១៨(ដប់ប្រាំបី)ឆ្នាំ។ ក្នុងករណីមានបងប្អូនបង្កើតច្រើនអ្នកហើយម្នាក់មានអាយុក្រោម ៨(ប្រាំបី)ឆ្នាំ អាចអនុញ្ញាតឲ្យសុំកុមារនោះ រួមជាមួយនឹងបងប្អូនបង្កើត ដែលមានអាយុក្រោម១៨ឆ្នាំ។

៣. កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬរស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រូវពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

៤. កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬកុមារដែលស្ថិតនៅក្រោមអំណាចមេបា ដែលមានស្ថានភាពលំបាកបំផុត។

៥. កុមារទាំងអស់នោះត្រូវបានប្រកាស អាចសុំជាកូនចិញ្ចឹមបានដោយអនុលោមតាមមាត្រា១៣ នៃច្បាប់ស្មុំកូនអន្តរប្រទេស។

ក្នុងករណី ដែលស្មុំកូនដោយសាច់ញាតិ ស្មុំកូនអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ដែលរស់នៅក្នុង ឬក្រៅមណ្ឌលកុមារកំព្រា។

ក្នុងករណីដែលកុមារត្រូវបានរកឃើញ និងបញ្ជូនមកកុមារកំព្រាហើយរកមិនឃើញឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានមណ្ឌលកុមារកំព្រាត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ពីវត្តមានកុមារ យ៉ាងយូរបំផុត ៧ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានកុមារមកដល់មណ្ឌល។ មន្ទីរទទួលបន្ទុក ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចដើម្បីបញ្ជូនឈ្មោះកុមារដែលត្រូវបានរាយការណ៍ថា ត្រូវបានគេបោះបង់ចោល។

មន្ទីរទទួលបន្ទុក ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកសាច់ញាតិរបស់កុមារនោះ តាមរយៈប្រពន្ធផ្សព្វផ្សាយជាសាធារណៈទៅតាមលទ្ធភាព។ បន្ទាប់ពីផ្សព្វផ្សាយរយៈពេលប្រាំខែនៅតែរកមិនឃើញសាច់ញាតិអនីតិជននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត ត្រូវតែធ្វើរបាយការណ៍ស្តីពីការខិតខំ

[44] មាត្រា១០ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ស្រាវជ្រាវនេះ ហើយត្រូវផ្ញើមួយច្បាប់ទៀតទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារដែលត្រូវបោះបង់ចោល។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ និងរហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត គឺជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន។[45]

ប្រសិនបើអ្នកមានអំណាចមេបានៃកុមារនោះ មានជីវភាពក្រលំបាក មិនអាចចិញ្ចឹមកុមារបាន ហើយបានធ្វើការទុកដាក់កុមារអោយនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ ត្រូវបញ្ជូនឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឲ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។[46]

### ៣.២.២.ការយល់ព្រមរបស់ឪពុកម្តាយបង្កើត ឬអាណាព្យាបាល

ការយល់ព្រមរបស់ឪពុកម្តាយបង្កើតឬអាណាព្យាបាលទៅលើដំណើរការសុំកូននេះពិតជាត្រូវការចាំបាច់ ដោយការយល់ព្រមនេះត្រូវស្ថិតនៅក្រោមរូបភាពដែលមិនមានការបង្ខិតបង្ខំ ការឆបោក ឬការបញ្ចុះបញ្ចូលដែលផ្តល់ផលប្រយោជន៍តបស្នងអ្វីឡើយ និងឪពុកម្តាយបង្កើត ឬអាណាព្យាបាលសុទ្ធ តែបានដឹងច្បាស់ពីផលវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេសនេះ។[47] ដូចនេះ ដំណើរការសុំកូនអន្តរប្រទេសអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមរបស់ឪពុកម្តាយ ឬម្តាយ ឬឪពុក ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីដូចជា៖

**១**.ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និងម្តាយ ការយល់ព្រមត្រូវផ្តល់ដោយឪពុក និងម្តាយរបស់កុមារនោះ។

**២**.ក្នុងករណីដែលឪពុក ឬម្តាយណាមួយរបស់កុមារបានស្លាប់ ឬស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយឪពុក ឬម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់។

**៣**.ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ។

---

[45]មាត្រា១១ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[46]មាត្រា១២ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[47] មាត្រា១៤ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវប្រាប់យ៉ាងច្បាស់លាស់ ដល់អ្នកដែលត្រូវផ្តល់ការយល់ព្រម អំពីអានុភាពនៃការយល់ព្រម នូវការបញ្ចប់បុត្តភាពព្រមទាំងការបញ្ចប់នូវសិទ្ធិ និងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងត្រូវប្រាប់អំពីបែបបទ និងរយៈពេលបញ្ឈប់នៃការយល់ព្រមនេះ។

ទោះជាក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខ័អក្សរនៅចំពោះមុខមេឃុំ ឬចៅសង្កាត់ ខាងទីលំនៅរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអាណាព្យាបាលសម្រាប់អនីតិជនកុមារ។

**ក. ការបញ្ឈប់ការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាល**

ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាល សម្រាប់អនីតិជនរបស់កុមារអាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបានរហូតដើរមុនពេលសេចក្តីសម្រេចរបស់តុលាការស្តីពីការសុំកូនចូលជាស្ថាពរ។ ការបញ្ឈប់ការយល់ព្រម ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន នេះអាចត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ នៅចំពោះមុខមេឃុំឬចៅសង្កាត់ខាងលំនៅដ្ឋានរបស់ខ្លួន។ មេឃុំ ឬចៅសង្កាត់ ខាងលំនៅដ្ឋានរបស់ឪពុកម្តាយ ឬឪពុកឬម្តាយឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនកុមារត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះហើយត្រូវបញ្ជូនកំណត់ហេតុនេះ ទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្តប្រធានមណ្ឌលកុមារកំព្រាដែលពាក់ព័ន្ធ នឹងត្រូវប្រគល់កំណត់ហេតុចម្លងដែលមានសេចក្តីបញ្ជាក់នៅលើកំណត់ហេតុនោះ ទៅឲ្យឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ។[48]

**ខ. ការដកហូតអំណាចមេបាដែលមានការយល់ព្រមពីតុលាការ**

ដោយសារតែដំណើរការនៃសុំកូនអន្តរប្រទេស បានធ្វើការកាត់ផ្តាច់ទំនាក់ទំនងសាច់ញាតិដូចនឹងសុំកូនពេញលេញដែរ ដូច្នេះករណីខ្លះឪពុកម្តាយបង្កើតមានការរារែកចិត្តក្នុងការ យល់ព្រមលើដំណើរការសុំកូនអន្តរប្រទេសនេះ។ ដោយនៅក្នុងមាត្រា១៩ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសក៏បានចែងពី ករណីដែលឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ បដិសេធការយល់ព្រម ឬការបញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចប្តឹងសុំអោយតុលាការប្រកាសដកហូតអំណាចមេបា ពីឪពុកម្តាយ ឬពុក ឬម្តាយ ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬការបញ្ឈប់ការយល់ព្រមនេះធ្វើឲ្យបាត់បង់ផលប្រយោជន៍របស់

[48]មាត្រា១៧ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩ មាត្រា១៧

កុមារ ឬបណ្តាលឱ្យប៉ះពាល់ដល់សុខភាពសុវត្ថិភាព ឬសីលធម៌របស់កុមារ។[49] ដោយពាក្យបណ្តឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល ៦០(ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធឬបញ្ឈប់ការយល់ព្រមរបស់ខ្លួន។

**៣.២.៣. លក្ខខណ្ឌសម្រាប់អ្នកសុំ**

អ្នកសុំដែលអាចអនុញ្ញាតឱ្យសុំទារក ឬកុមារទៅចិញ្ចឹមបានជាកូនបានត្រូវសមស្របនឹងលក្ខណ្ឌមួយចំនួនដូចជា៖

- អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុចាប់ពី ៣០(សាមសិប)ឆ្នាំ និងមានអាយុលើសកូនសុំយ៉ាងតិច ២២ (ម្ភៃពីរ)ឆ្នាំនិងច្រើនបំផុត៤៥ (សែសិបប្រាំ)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន។
- បើអ្នកសុំមិនបានបំពេញចំនុចមួយខាងលើ ហើយក្នុងករណីសុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារនោះ ខ្ញុំក៏អាចអនុញ្ញាតឱ្យបានក្នុងករណីអ្នកសុំ មានដើមកំណើតជនជាតិខ្មែរសុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬអ្នកសុំជាសហព័ទ្ធដែលសុំកូនសហព័ទ្ធម្ខាងទៀត ឬអ្នកសុំបានសុំកុមារដែលត្រូវការការថែទាំពិសេស ឬស្ថានភាពផ្សេងទៀតដែលបម្រើឧត្តមប្រយោជន៍របស់កុមារ។
- ករណីអ្នកសុំមានប្តី ឬប្រពន្ធការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នាលើកលែងតែករណីដែលថាភាគីណាមួយខាងសុំកូនបង្កើតនៃសហព័ទ្ធម្ខាងទៀត។
- ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និងច្បាប់ប្រទេសនៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកសុំបាន ទទួលស្គាល់ និងអនុញ្ញាតនៅបុត្រភាពនៃសុំកូនពេញលេញ។
- ប្រទេសនៃសញ្ជាតិឬប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍អ្នកសុំត្រូវតែជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។ អ្នកសុំត្រូវមានលក្ខណៈសម្បត្តិ និងលក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូន ស្របទៅតាមច្បាប់ប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍របស់ខ្លួន។
- អ្នកសុំត្រូវជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬកំពុងត្រូវប្តឹងអំពីកំហុសទំនាក់ទំនង ទៅ និងអាកប្បកិរិយាមាយាទ ឬការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈដ្ឋានណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួនឬប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍ ឬក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ។
- អ្នកសុំត្រូវតែជាអ្នកមានសមត្ថភាពដល់ការថែទាំសមស្រប និងការគាំទ្រដ៏ចាំបាច់ដោយកូនសុំ។
- អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបានលុះត្រាតែអ្នកសុំកូនគ្មានកូន កូនតែម្នាក់នៅក្នុងបន្ទុក។

[49] មាត្រា១៩ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

- អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យសុំច្រើននាក់បាន។[50]

## ៣.៣. នីតិវិធីនៃការសុំកូនអន្តរប្រទេស

### ៣.៣.១.នីតិវិធីរដ្ឋបាលសុំកូនអន្តរប្រទេស

ក្នុងដំណាក់កាលនៃនីតិវិធីរដ្ឋបាលក្នុងការសុំកូនអន្តរប្រទេស ត្រូវការឆ្លងកាត់ ការដាក់ពាក្យសុំរបស់អ្នកសុំ ហើយត្រូវបានពិនិត្យយ៉ាងម៉ត់ចត់ជាមុន ដើម្បីសម្រេចលើពាក្យសុំថាត្រឹមត្រូវ នឹងគ្រប់គ្រាន់ចំពោះសំណុំឯកសារស្នើសុំ។[51]

#### ក.ការដាក់ពាក្យ

អ្នកសុំត្រូវដាក់ពាក្យសុំកូនអន្តរប្រទេសទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា។[52] ដោយភ្ជាប់មកជាមួយនូវឯកសាររួមមាន ដូចជាភស្តុតាងដែលបញ្ជាក់ថា អាជ្ញាធរនៃប្រទេសដើមរបស់ខ្លួន ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍ចាត់ទុកថាអ្នកសុំមានលក្ខណៈសម្បត្តិ និងមានភាពសមស្របសម្រាប់សុំកូនដោយផ្អែកលើការវាយតម្លៃលើជីវប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ ប្រវត្តិសុខភាពបរិយាកាសគ្រួសារ បរិយាកាសសង្គមមូលហេតុសុំកូននឹងលទ្ធភាពនៃការទទួលបន្ទុករ៉ាប់រងចំពោះសុំកូនអន្តរប្រទេស។ មួយវិញទៀតព័ត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបទៅនឹងលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា២១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំដែលក្នុងនោះរួមមាន ឯកសារទាក់ទងអគ្រានុកូលដ្ឋាន។ ព័ត៌មានទាក់ទងនឹងលក្ខណៈសម្បត្តិផ្សេងៗរបស់កុមារដែលអ្នកសុំអាចនឹងមានលក្ខណៈសម្បត្តិថែទាំបាន។ ភស្តុតាងទទួលបានពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសមួយដែលបញ្ជាក់ថានៅ ពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រមហើយកូនសុំនោះត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល។

ឯកសារទាំងអស់ត្រូវបានបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកសុំ។ ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬភាសាបារាំងដែលមានការបញ្ជាក់ត្រឹមត្រូវ។ ចំពោះពាក្យសុំបង្កើតសុំកូនអន្តរប្រទេស អាចធ្វើទៅបានទាំងក្នុងករណីដែល

[50] មាត្រា២១ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[51] មាត្រា២២ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[52] មាត្រា២៣ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

កុមារនោះ ជាសាច់ញាតិ ឬមិនមែនជាសាច់ញាតិរបស់អ្នកសុំក៏ដោយ គឺត្រូវប្រព្រឹត្តទៅតាមបញ្ញត្តិនៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសដូចគ្នា។

ពាក្យសុំដែលបានភ្ជាប់រួចជាស្រេចនូវភស្តុតាងដែលតម្រូវ បានដាក់រួចរាល់ហើយនោះ ត្រូវបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិតាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬស្ថានតំណាងនៃប្រទេសទទួលប្រចាំនៃព្រះរាជាណាចក្រកម្ពុជាដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារនោះ។ ក្រសួងការបរទេសនិងការសហប្រតិបត្តិការអន្តរជាតិត្រូវពិនិត្យផ្តល់យោបល់ និងត្រូវបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេសត្រូវទៅក្រសួងបន្ទុកវិស័យសង្គមកិច្ចក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការចាប់ពីថ្ងៃទទួលបានពាក្យសុំ។ ក្នុងរយៈពេលយ៉ាងយូរបំផុត១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការគិតពីថ្ងៃទទួលបានពាក្យសុំពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកបានសុំកូនអន្តរដោយបញ្ជាក់ថាខ្លួនបានទទួលពាក្យសុំកូននោះ តាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬតាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍។[53]

**ខ. ការពិនិត្យពាក្យសុំ**

បន្ទាប់ពីទទួលបានពាក្យសុំរដ្ឋបាលសុំកូនអន្តរប្រទេសអនុវត្តភារកិច្ចត្រួតពិនិត្យពីភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃសំណុំលិខិតស្នើសុំក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតឯកសារ។ ប្រសិនបើសំណុំលិខិតឯកសារនៅមិនទាន់គ្រប់គ្រាន់ ឬមិនទាន់ត្រឹមត្រូវរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកសុំតាមរយៈអាជ្ញាធរកណ្តាលឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវត្រួតពិនិត្យឯកសារដែលស្នើសុំឲ្យកែតម្រូវ ស្មើគ្នានឹងអំឡុងពេលខាងលើគឺ៦០ (ហុកសិប)ថ្ងៃដែរ។ អំឡុងពេលដែលបានកំណត់ខាងលើ ក្រោយពីមានការជូនដំណឹងពីរដ្ឋបាលកណ្តាលសុំកូនអន្តរប្រទេសឲ្យកែតម្រូវ អ្នកសុំបានធ្វើឲ្យមានភាពយឺតយ៉ាវនោះពាក្យសុំត្រូវចាត់ទុកជាមោឃៈ។[54]

**គ.ការសម្រេចលើពាក្យសុំ**

[53] មាត្រា២៤ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[54]មាត្រា២៦ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ក្នុងករណីដែលសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវហើយអ្នកសុំបានបំពេញលក្ខខណ្ឌច្បាប់សុំកូនអន្តរប្រទេសរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវត្រួតពិនិត្យពិចារណា ទៅលើសំណុំឯកសាររបស់កុមារទាំងឡាយដែលមានលក្ខណសម្បត្តិសុំកូនអន្តរប្រទេសបាន និង ផ្គូផ្គងលក្ខណៈសម្បត្តិដែលត្រូវគ្នាល្អបំផុតនិងលក្ខណៈសម្បត្តិកុមារ។ ក្នុងការផ្គូរផ្គងដោយគិតគូរដល់ឧត្តប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាឲ្យ បានសមស្របទៅលើអត្ថប្រយោជន៍នៃការបន្តឲ្យមានការបីបាច់ថែរក្សាកុមារដូចពេលកន្លងមក ព្រមទាំងពិចារណាទៅលើសាវតាសង្គមជាតិ សាសនា និងវប្បធម៌កុមារ។[55] ភារកិច្ចបន្តរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលបានផ្គូផ្គងរួចហើយនោះដោយរួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការយល់ព្រមចាំបាច់នានា ដឹងអំពីមូលហេតុដែលខ្លួនបានកំណត់ ទុកដាក់កុមារជាមួយអ្នកសុំទៅអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេស ដើម្បីពិនិត្យ នឹងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពី អត្តសញ្ញាណរបស់ឪពុកម្តាយ ឬឪពុកឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ វាលែងតែការសុំកូនដោយសាច់ញាតិ។[56]

ជាគោលការណ៍ អ្នកសុំត្រូវធ្វើការឆ្លើយតបវិញជាលាយលក្ខណ៍អក្សរអំពីការយល់ព្រមសុំកុមារដែលខាងរដ្ឋបាលសុំកូនបានកុំឱ្យ ទៅកាន់រដ្ឋបាលសុំកូនអន្តរប្រទេសវិញតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដោយកំណត់អំឡុងពេល ៦០ថ្ងៃ (នៃថ្ងៃធ្វើការរាប់ចាប់ពីពេលរដ្ឋបាលសុំកូនបានផ្ញើសំណុំឯកសារទៅកាន់អ្នកសុំ) ។ ក្នុងករណី អ្នកសុំមិនបានឆ្លើយតបទាន់ក្នុងរយៈពេលខាងលើទេ ត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន។ តែមិនយកមកអនុវត្តឡើយក្នុងករណីដែលមានការខកខាននោះមានមូលហេតុត្រឹមត្រូវ ដោយរដ្ឋបាលសុំកូនអន្តរប្រទេសជាអ្នកមានសមត្ថកិច្ចក្នុងការសម្រេចថា តើឲ្យមានការផ្គូរផ្គងសារជាថ្មី ឬការទទួលពាក្យសុំកូនសារជាថ្មី។ដោយឡែក បើអ្នកសុំធ្វើការឆ្លើយតបថាមិនទទួលយកកុមារដែលបានផ្គូរផ្គងឲ្យខ្លួននោះទេ អ្នកសុំអាចស្នើសុំឱ្យរដ្ឋបាលសុំកូនអន្តរប្រទេសផ្គូរផ្គងកុមារជាលើកទីពីរបាន តែការផ្គូរផ្គងនោះ នឹងមិនអនុញ្ញាតឱ្យ មានធ្វើជាលើកទីបីឡើយ។[57]

ផ្ទុយទៅវិញ បើអ្នកសុំឆ្លើយតបយល់ព្រមលើការសម្រេចចិត្តរបស់រដ្ឋបាលសុំកូនអន្តរប្រទេសចំពោះការផ្គូផ្គងរវាងអ្នកសុំនិងកូនសុំនោះ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវរៀបចំឲ្យមានការជួបគ្នារវាងអ្នកសុំ

[55] មាត្រា២៧ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[56] មាត្រា២៨ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[57] មាត្រា២៩ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

និងកុមារដែលបានផ្គូផ្គងរួចហើយនោះ ក្នុងកាលបរិច្ឆេទមួយដែលសមស្របសម្រាប់អ្នកសុំរួមទាំងរដ្ឋបាលសុំកូនអន្តរប្រទេស និងមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ (នៃថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ)។ មុនមានការជួបគ្នារវាងអ្នកសុំ និងកូនសុំ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធ្វើការសម្ភាសន៍អ្នកសុំ និងត្រូវធានាថាអ្នកសុំ និងកុមារបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មាន ការផ្លាស់ប្តូររូបថត និងវិធានការផ្សេងៗទៀតដើម្បីការជួបគ្នានេះ។ នៅក្នុងកាលបរិច្ឆេទ នៃការជួបគ្នាលើកដំបូងនេះ បើមានសហព័ទ្ធណាម្ខាង អវត្តមាន ចាំបាច់ត្រូវមានលិខិតប្រគល់សិទ្ធិឲ្យសហព័ន្ធម្ខាងទៀត ដែលមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួលធ្វើជាអ្នកតំណាងខ្លួនបាន។ ប្រសិនបើអ្នកសុំមិនបានជួបក្នុង រយៈពេលខាងលើដោយគ្មានមូលហេតុត្រឹមត្រូវ ចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន។ បន្ទាប់មករដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារឲ្យដឹងអំពីអានុភាពដែលកើតចេញពីសុំកូនអន្តរប្រទេសនេះ ដោយត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍នឹងការជួបគ្នាលើកនេះ។

រដ្ឋបាលសុំកូនអន្តរប្រទេសធ្វើការត្រួតពិនិត្យ បើយល់ឃើញថា រវាងអ្នកសុំ និងកូនសុំបានបំពេញនូវលក្ខខណ្ឌវិនិច្ឆ័យ និងលក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ហើយឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ ហើយត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការជួបគ្នា។ រួចដាក់ សំណុំឯកសារជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍លើដំណើរការសុំកូន។[58] ក្រោយពីបានពិនិត្យ និងផ្តល់អនុសាសន៍ របស់មន្ត្រីទទួលបន្ទុកក្នុងវិស័យសង្គមកិច្ចរួចមក អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួលដាក់ពាក្យសុំកូនដែលបានផ្គូផ្គងរួចតាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសនៅសាលាដំបូងរាជធានីភ្នំពេញ រដ្ឋបាលផងកូនអន្តរប្រទេសមានកាតព្វកិច្ចបញ្ជូនពាក្យសុំ រួមជាមួយឯកសាររបស់អ្នកសុំនឹងកូន ព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដែលមានការបកប្រែជាភាសាខ្មែរ និងមានការបញ្ជាក់ពីរដ្ឋបាលក្នុងកូនអន្តរប្រទេសផង ដើម្បីសុំដីកាសម្រេចសុំកូនក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃ បើអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានអនុសាសន៍របស់មន្ត្រី ត្រូវបានចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំដោយខ្លួនឯង។[59]

[58] មាត្រា៣២ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[59] មាត្រា៣៣ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

### ឃ.សោហ៊ុយលើការសុំកូន

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា សម្រាប់ជួយឧបត្ថម្ភដល់ជម្រើសការថែទាំជំនួស និងការជួយឧបត្ថម្ភទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និងកម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទង ទៅនឹងសុំកូនអន្តរប្រទេសដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច(អ្នកសុំត្រូវបង់ចំនួន ៥.០០០ USA (ប្រាំពាន់ដុល្លាអាមេរិក) សម្រាប់ការសុំកុមារ ០១ នាក់ ដែលទុកជាថវិកាវិភាគទានមនុស្សធម៌)។ ក្រៅពីនេះមិនត្រូវយកសោហ៊ុយពីអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំ។ មិនអនុញ្ញាឲ្យអ្នកសុំកូមន ឬទីភ្នាក់ងារសុំកូនបង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬទៅតាមសោហ៊ុយសុំកូននីមួយៗ ដែលត្រូវបានបញ្ជូនទៅឲ្យមណ្ឌលកុមារកំព្រាណាមួយ ឬមិនអនុញ្ញាតឲ្យអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំធ្វើការផ្តល់សោហ៊ុយអំណោយ ឬការទូរទាត់ ទោះក្នុងរូបភាពណាក៏ដោយទៅឲ្យមណ្ឌលកុមារកំព្រាដែលកុមារទៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬទៅឲ្យបុគ្គលិក នាយក ឬសមាជិកនៃគណៈគ្រប់គ្រងទោះជាដោយផ្ទាល់ ឬដោយប្រយោលក្តី។

ចំណែកឯនៅក្នុងនីតិវិធីតុលាការ អ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០(មួយលាន) រៀល ដើម្បីទ្រទ្រង់សោហ៊ុយដក់ពាក្យសុំ ការពិនិត្យភស្តុងតាង ការចេញដីការសម្រេច ការបង្ហាញជូនឯកសារ ការផ្សព្វផ្សាយការជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និងសកម្មភាពខាងនីតិវិធីផ្សេងៗ ទៀតដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស។ តុលាការត្រូវបង្គាប់ឲ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន។ ក្នុងករណីដែលចាំបាច់ដែលបានកំណត់ខាងលើនេះ លើសពីនេះ ១.០០០.០០០(មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែមនោះជាមុន។ ចំនួនទឹកប្រាក់នេះមិនអាចធ្វើការបង្វិលវិញបានទេ។

### ៣.៣.២. ការគ្រប់គ្រងសំណុំឯកសាររបស់រដ្ឋបាលសុំកូនអន្តរប្រទេស

រដ្ឋបាលសុំកូនអន្តរប្រទេស គឺត្រូវរៀបចំសំណុំឯកសារផ្ទាល់របស់កុមារម្នាក់ៗដែលមានលក្ខណៈសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមានពត៌មានចាំបាច់ អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹម សាវតារជាតិរបស់កុមារ បរិយាកាសសង្គមរបស់កុមារ ប្រវត្តិគ្រួសាររបស់កុមារ ប្រវត្តិសុខភាពកុមារ និងប្រវត្តិសុខភាពគ្រួសាររបស់កុមារ និងសេចក្តីត្រូវការជាពិសេសណាមួយរបស់កុមារជាដើម។ បើក្នុងករណីកុមារត្រូវបានបោះបង់ចោល រដ្ឋបាលសុំកូណអន្តរប្រទេសត្រូវធានាថា ការខិតខំប្រឹងប្រែងដើម្បីស្វែងរកឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានធ្វើរួចហើយ។ រដ្ឋបាលសុំកូន

អន្តរប្រទេសក៏ត្រូវធានាថាផងដែរថា រាល់ការយល់ព្រមចាំបាច់ទាំងឡាយ ត្រូវបានធ្វើឡើងស្របទៅតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេសនេះ។

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារ រាប់បញ្ចូលទាំងភស្តុតាងបង្ហាញពីការយល់ព្រម និងការខិតខំប្រឹងប្រែង ដើម្បីស្វែងរកឪពុកម្តាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារផងដែរ។

### ៣.៣.៣. នីតិវិធីតុលាការ

ដោយដូចបានចែងនៅក្នុងមាត្រា៣៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ២០០៩ បាននិយាយថា មានតែសាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការទៅលើរឿងក្តីសុំកូនអន្តរប្រទេស ហើយតុលាការត្រូវយកបទបញ្ញត្តិស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹងមកអនុវត្តចំពោះនីតិវិធីតុលាការទាក់ទងនឹងសុំកូនអន្តរប្រទេស លើកលែងតែមានបទបញ្ញត្តិពិសេសដូចមានចែងនៅក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេសនេះ។[60] ដោយនីតិវិធីតុលាការមានដូចជា ការពិនិត្យសំណុំឯកសារ ការសម្រេចសេចក្តី របស់តុលាការ និងនីតិវិធីនៃការប្តឹងទាស់។

#### ក. ការពិនិត្យសំណុំឯកសារ

ជាគោលការណ៍សំណុំឯកសារ និងរបាយការណ៍ដាក់ជូនតុលាការដោយក្រសួងទទួលបន្ទុក វិស័យសង្គមកិច្ច ត្រូវសន្មតជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណសម្បត្តិសុំកូនអន្តរប្រទេស និងភាពសមស្របសម្រាប់សុំកូនរបស់អ្នកសុំលើកលែងតែមានភស្តុតាងផ្ទុយមកបញ្ជាក់។[61] តុលាការត្រូវត្រួតពិនិត្យចំពោះឯកសារពាក់ពន្ធ័នឹងសុំកូណអន្តរប្រទេសដូចជា ត្រូវមានលក្ខណវិនិច្ឆ័យ ឬលក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ មានការពិគ្រោះយោបល់ជាចាំបាច់មុន នឹងផ្តល់ការយល់ព្រមត្រូវបានផ្តល់ដោយគោរពតាមខ្លឹមសារផ្នែកទី២ ជំពូកទី៤ នៃច្បាប់នេះ។ អាជ្ញាកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ច ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលទទួលការអនុញ្ញាតនៃប្រទេសសែលទទួល មានការពិចារណាត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយកុមារ នឹងត្រូវបានអនុញ្ញាតឲ្យចូលទៅរស់នៅជា អចិន្ត្រៃយ៍នៅក្នុងប្រទេសទទួល ជាពិសេសការសុំកូនអន្តរប្រទេសនេះពិតជាផ្តល់ឧត្តមប្រយោជន៍ដល់កុមារ។[62]

#### ខ.ការសម្រេចសេចក្តីរបស់តុលាការ

[60] មាត្រា៣៤ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[61] មាត្រា៣៦ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[62] មាត្រា៣៦ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

តុលាការសម្រេចលើរឿងក្តីដែលទាក់ទងនឹងស្មុំកូនអន្តរប្រទេស ដោយពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ។ ក្នុងករណីមានភាពចាំបាច់ដាច់ខាតត្រូវបំភ្លឺអង្គហេតុពាក់ព័ន្ធ តុលាការអាចអញ្ជើញអ្នកសុំ ឬអ្នកតំណាង ឬអ្នកមានអំណាចមេបាម្ខាង ឬទាំងពីរ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អ្នកតំណាងទីភ្នាក់ងារស្មុំកូនអន្តរប្រទេសពាក់ពន្ធ័ នឹងសាក្សីផ្សេងៗទៀតដើម្បីផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ទាក់ទងនិងអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុ។[63]

តុលាការត្រូវលើកយកសំណុំរឿងស្មុំកូនមកវិនិច្ឆ័យ និងដីការសម្រេចក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលពាក្យសុំកូន។ តុលាការត្រូវបញ្ជូនដីការសម្រេចនេះទៅអ្នកសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំ និងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

ដីការសម្រេចនេះ មិនត្រូវចូលជាស្ថាពរនៅមុនផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលបានកំណត់ក្នុងមាត្រា៤០ នៃច្បាប់ស្មុំកូនអន្តរប្រទេស។

ករណីមានការប្តឹងទាស់ចំពោះដីការសម្រេចនេះ ដីការសម្រេចនេះ មិនត្រូវចូលជាស្ថាពររហូតដល់មានដីការសម្រេចអំពីបណ្តឹងជំទាស់នេះ។[64]

**គ. នីតិវិធីនៃការប្តឹងជំទាស់**

បុគ្គលដែលមានសិទ្ធិ ឬផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីការសម្រេចលើពាក្យស្មុំកូនអន្តរប្រទេសអាចប្តឹងទាស់ទៅសាលាឧទ្ធរណ៍ចំពោះដីការសម្រេចនោះបាន។

- ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ជនដែលត្រូវបានការជូនដំណឹងអំពីដីការសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ថ្ងៃ នៃថ្ងសធ្វើការ គិតពីថ្ងៃដែលទទួលបានការជូនដំណឹងអំពីដីការសម្រេចនេះ។
- ក្នុងករណីដែលបុគ្គលប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងដីការសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលអ្នកសុំបានទទួលការជូនដំណឹងពីដីការសម្រេច។

ដោយអំឡុងពេល ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ដែលបានកំណត់ខាងលើមិនអាចពន្យាបានឡើយ។ សាលាឧទ្ធរណ៍ត្រូវលើកយកពាក្យបណ្តឹងជំទាស់នោះមកវិនិច្ឆ័យ និងចេញដីការសម្រេចក្នុងរយៈ

[63] មាត្រា៣៨ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[64] មាត្រា៣៩ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ពេល ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងជំទាស់។[65]ដោយឡែក ដីការសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់បានឡើយ។[66]

### ៣.៣.៤.អានុភាពនៃសុំកូនអន្តរប្រទេស

សុំកូណអន្តរប្រទេសក៏ដូចជាសុំកូនពេញលេញដែរ។ សុំកូនអន្តរប្រទេសមានអានុភាពបង្កើតទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយចិញ្ចឹម និងកូនជាអចិន្ត្រៃ ដោយផ្តល់ដល់កុមារនូវឋានៈ សិទ្ធ និងកាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ហើយវាបានបញ្ចប់ញាតិភាពរវាងកុមារ និង ឪពុកម្តាយបង្កើត។[67] អានុភាពផ្សេងៗ ទៀតនៃសុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយច្បាប់ជាតិរបស់អ្នកសុំ ឬ ប្រសិនបើគ្មានច្បាប់រួមមួយទេត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកសុំ។ អានុភាពផ្សេងៗទៀតនៃសុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយច្បាប់ជាតិរបស់អ្នកសុំ ឬ ប្រសិនបើគ្មានច្បាប់រួមមួយទេត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកសុំ។[68]

## ៣.៤.ចំណាត់ការក្រោយពីបញ្ចប់នីតិវិធីសុំកូន

ក្រោយពីដីការសម្រេចរបស់តុលាការចូលជាស្ថាពរ នោះក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវជូនដំណឹងទៅក្រសួងការបរទេស និងសហប្រត្តិបត្តិការអន្តរជាតិ អំពីដីការសម្រេចនេះ។

នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេសត្រូវបានបញ្ចប់ ដោយអនុវត្តទៅតាមអនុសញ្ញាទីក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។ ក្រសួងទទួលបន្ទុក វិស័យសង្គមកិច្ចត្រូវចេញលិខិតបញ្ជាក់ដោយអនុលោមតាមមាត្រា២៣ នៃអនុសញ្ញា។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបានរៀបចំប្រគល់កុមារ និងលិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ និងតាមដានស្ថានភាពរស់នៅកុមារ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការរៀបចំ និងផ្តល់នៅលិខិតឆ្លងដែន និងឯកសារចាំបាច់នានា ដើម្បីឲ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកសុំ ដោយរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបានធានាថាការផ្ទេរកុមារទៅកាន់ប្រទេសទទួលប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរ ដល់សេចក្តីត្រូវការនានារបស់កុមារ។[69] ការដំណើរទៅរបស់កុមារទៅកាន់ប្រទេសទទួល ត្រូវអមដំណើរដោយអ្នកសុំ។

[65] មាត្រា៤០ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[66] មាត្រា៤០ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[67] មាត្រា៤១ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[68] មាត្រា៤២ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[69] មាត្រា៤៤ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ក្រោយពីកុមារត្រូវបានទទួលការអនុញ្ញាតឲ្យធ្វើជាកូន ឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវឌ្ឍន៍របស់កុមារមករដ្ឋបាលសុំកូនអន្តរប្រទេសជារៀងរាល់៦ខែម្តង ក្នុងរយៈពេល៣(បី)ឆ្នាំ បន្ទាប់មកត្រូវផ្តល់របាយការណ៍ ១(មួយ)ឆ្នាំ ម្តង រហូតដល់កុមារអាយុ១៨(ដប់ប្រាំបី)ឆ្នាំ។ ឪពុកម្តាយចិញ្ចឹមត្រូវផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនដោយផ្ទាល់ ឬតាមរយៈអាជ្ញាកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប។[70]

### ៣.៤.១. ការឧកដាក់សំណុំឯកសារ

រដ្ឋបាលសុំកូនអន្តរប្រទេស និងសាលាដំបូងរាជធានីភ្នំពេញ ត្រូវរក្សាទុកសំណុំឯកសារសុំកូមអន្តរប្រទេសក្នុងរយៈពេល៦០(ហុកសិប)ឆ្នាំ គឺគិតចាប់ពីកាលបរិច្ឆេទដែលដីការសម្រេចសុំកូនអន្តរប្រទេសនោះចូលជាស្ថាពរ។ [71] សំណុំឯកសារ និងកំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ទោះជាបានរក្សាទុកតុលាការ រដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនងន្តរប្រទេស មណ្ឌលកុមារកំព្រា និងអ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាទុកជាសម្ងាត់។ ក៏ប៉ុន្តែសំណុំឯកសារ និងកំណត់ហេតុទាំងនោះអាចនឹងត្រូវបញ្ចេញទៅតាមការស្នើសុំ ឬការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច នៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានតម្រូវការទាក់ទងនិងករណី ឬនីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅ ឬកាលៈទេសៈពិសេសដ៏ទៃទៀត។[72]

### ៣.៤.២. ការអនុញ្ញាតអោយកូនសុំមើលលិខិតសុំកូន

ឪពុកម្តាយចិញ្ចឹម អាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំ ក្រោយពីដីការសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ។ កូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អំពីផលវិបាកនៃការដឹងអត្តសញ្ញាណខ្លួន អាចត្រូវបានអនុញ្ញាតឲ្យមើលលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបានដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីការមើលនេះបានឧត្តមប្រយោជន៍របស់កូនសុំ។ កូនសុំដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ

[70] មាត្រា៤៥ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[71] មាត្រា៤៥ វាក្យខណ្ឌទី១ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[72] មាត្រា៤៥ វាក្យខណ្ឌទី២ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

និងកំណត់ហេតុទាក់ទងនឹងអត្តសញ្ញាណខ្លួន។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា កូនសុំទទួលបានការពិគ្រោះយោបល់កុមារសមស្របមុន នឹងមើលព័តមាននៅក្នុងសំណុំលិខិតខ្លួន។[73]

### ៣.៤.៣. ទណ្ឌកម្ម

ដោយច្បាប់សុំកូនអន្តរប្រទេសនេះ ត្រូវបានបង្កើតឡើងមិនត្រឹមតែកំណត់ពីគោលការណ៍លក្ខខណ្ឌ នីតិវិធីទម្រង់បែបបទ និងអានុភាពសុំកូនអន្តរប្រទេសប៉ុណ្ណោះទេ ប៉ុន្តែច្បាប់នេះព្រមទាំងបានកំណត់ អំពីការផ្តន្ទាទោសដល់ជនដែលពាក់ពន្ធ័ នឹងច្បាប់សុំកូនអន្តរប្រទេសនេះដែលមានកំហុសណាមួយកើតឡើង ដែលត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ នឹងច្បាប់បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា គឺដើម្បីថែរក្សានូវសន្តិសុខ សណ្តាប់ធ្នាប់ក្នុងសង្គម ជាពិសេសគឺការពារដល់ប្រយោជន៍របស់កុមារដែលត្រូវបានសុំឲ្យខានតែបាន។ ដោយនៅគ្រប់ករណីនៃបទល្មើសទាំងឡាយ នឹងទទួលរងនូវទោសព្រហ្មទណ្ឌ (ទោសដាក់ពន្ធនាគារ) ឬទោសរដ្ឋប្បវេណីក៏ដូចជាសំណងរដ្ឋប្បវេណីផងដែរ និងការប្រកាសនូវទោសផ្សេងៗទៀត គឺស្ថិតទៅតាមស្ថានទម្ងន់ទោសរបស់ជនល្មើស។

ដោយមិនទាន់គិតដល់ទោសបញ្ញត្តិ [74]ដែលមានចែងក្នុងច្បាប់ជាធរមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចព្យួរ ឬដក់ហូតការទទួលស្គាល់ ឬបដិសេធការទទួលស្គាល់ ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឲ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេសជាប់ពាក់ព័ន្ធ នឹងអំពើណាមួយដូចតទៅៈ

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ឬញុះញង់ដោយផ្ទាល់ឲ្យឪពុកម្តាយ ឬឪពុក ឬម្តាយបោះបង់ទារកដែលកើតមកហើយ ឬដែលនឹងកើត ដើម្បីឲ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស។
- អំពើប្រព្រឹត្តស្ថិតនៅក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងឪពុកម្តាយ ឬឪពុក ឬម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬដែលទើបនឹងកើត។
- អំពើប្រព្រឹត្តស្ថិតនៅក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឲ្យអ្នកសុំ។
- អ្នកក្លែងបន្លំ ឬសមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបានការយល់ព្រមពីឪពុកម្តាយបង្កើត ឬឪពុកបង្កើត ឬម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។

[73] មាត្រា៤៥ វាយ្យខ័ណ្ឌទី៣ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[74] មាត្រា៥៤ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

- អំពើរៀបចំឲ្យមានការយល់ព្រមរបស់ឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬរបស់អ្នកអាណាពញ្យាបាលសម្រាប់អនីតិជនរបស់កុមារដោយការបង្ខិតបង្ខំ ឬការបញ្ចុះបញ្ចូលតាមរយៈការផ្ដល់ ឬសន្យាផ្ដល់ប្រាក់រង្វាន់សំណង ឬផលប្រយោជន៍ណាមួយ។
- ការបញ្ចេញសំណុំឯកសារ និងកំណត់ហេតុទាំងអស់ ឬមួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពី ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។
- ការបង្កាប់ ឬការទទួលដោយផ្ទាល់ ឬដោយប្រយោលនូវផ្លូវប្រាក់កាសទំនិញ ឬសេវាដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន។
- ការផ្ដល់ប្រាក់កាស ទំនិញ ឬសេវា ទៅដល់មន្ត្រី ឬអ្នកតំណាងណាមួយនៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្ដាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ឬមន្ត្រីពាក់ពន្ធ័ផ្សេងៗទៀត ដើម្បីឲ្យផ្ដល់នូវសិទ្ធិជាអាទិ៍ភាពនៅក្នុងសុំកូនអន្តរប្រទេសដល់អ្នកសុំ។
- ការផ្សព្វផ្សាយពាណិជ្ជកម្ម ឬបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬរូបថតរបស់កុមារណាមួយដែលកម្មវត្ថុសុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាម្នាក់ដោយដាក់ពាក្យសុំកូន។
- ការតែងតាំង ឬចាត់តាំងអ្នកតំណាងណាមួយដោយមិនមានឯកភាពពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។
- ការចូលរួមក្នុងការរៀបចំការផ្គូរផ្គង ឬការទាក់ទងគ្នារវាងអ្នកសុំ និងឪពុកម្ដាយបង្កើត ឬឪពុកបង្កើត ឬម្ដាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារក្នុងគោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ។
- ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នៃនេះ បទដ្ឋានអប្បបរមានៃការថែទាំជំនួស ចំពោះកុមារ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

ដូចបានកំណត់នៅក្នុងមាត្រា ៤៧ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ដោយទីភ្នាក់ងារដែលបានធ្វើប្រត្តបត្តិការដំណើរការសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា តែត្រូវទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួលថែទាំមិនមានបំណងនៅក្នុងការស្វែងរកប្រាក់ចំណេញនៅក្នុងគោលដៅអវិជ្ជមានទាំងឡាយ ជាពិសេសមានគោដៅរួមមួយ គឺដើម្បីឧត្តមប្រយោជន៍នៃកុមារដែលត្រូវបានសុំនោះជាប្រាក់១០.០០០.០០០(ដប់លាន)រៀល។ ការដាក់ពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ប្រសិនបើក្នុងករណី ទីភ្នាក់ងារ

មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងនេះទៅតុលាការ។[75]

ម្យ៉ាងវិញទៀត នៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទនៃព្រះរាជណាចក្រកម្ពុជា ក៏បានចែងនូវមាត្រាមួយចំនួនអំពីការនាំចេញដោយមិនស្របច្បាប់ គឺការនាំយកអនីតិជន ឬជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬនៅក្រោមហិតូបត្ថម្ភ ឬនៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬយុត្តិកម្មតាមផ្លូវច្បាប់ ចេញពីការគ្រប់គ្រងស្របច្បាប់នៃឪពុកម្ដាយ អ្នកថែរក្សា ឬអ្នកអាណាព្យាបាលរបស់គេ នឹងត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ដល់ ៥(ប្រាំ)ឆ្នាំ។[76]

ក្នុងករណីជនណាដែលនាំយកជនដ៏ទៃចេញដោយមិនស្របច្បាប់ ក្នុងគោលបំណងស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧(ប្រាំពីរ)ឆ្នាំ ដល់ ១៥(ដប់ប្រាំ)ឆ្នាំ។

ប៉ុន្តែក្នុងករណីដែលជាអនីតិជន ហើយប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ និងអំពើប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ)ឆ្នាំ ដល់ ២០ (ម្ភៃ)ឆ្នាំ។[77]

សរុបជារួមមក ការបង្កើតសុំកូនអន្តរប្រទេស គឺជាការសុំកុមារដែលរស់នៅក្នុងប្រទេសកម្ពុជា មានសញ្ជាតិខ្មែរ អាយុក្រោម៨ (ប្រាំបី) ឆ្នាំ ដោយជនជាតិបរទេសដែលមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់មើលថែកុមារឲ្យរស់នៅ និងទទួលបានការសិក្សាអប់រំដ៏ល្អមួយ និងរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសរបស់ឪពុកម្ដាយចិញ្ចឹមដែលជាជនជាតិបរទេសនោះ ហើយការសុំកូនអន្តរប្រទេសនេះអាចមានអានុភាពបាន លុះត្រាតែអ្នកសុំអនុវត្តទៅតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់សុំកូនអន្តរប្រទេស ឲ្យគ្រប់តាមលក្ខខណ្ឌដែលច្បាប់បានកំណត់។ សុំកូនអន្តរប្រទេសនេះមានសារៈសំខាន់ណាស់ចំពោះ កូនសុំ អ្នកសុំ និងរដ្ឋ៖

- ជួយឲ្យកុមារ មានអាណាព្យាបាល មើលថែ មានជម្រក ទទួលបានការសិក្សាអំបរំ និងមានអនាគតល្អ។
- ជួយឲ្យ គ្រួសារដែលគ្មានកូនចិញ្ចឹម ឬមានកូនតិច(មានតែស្រីម្នាក់ ឬប្រុសម្នាក់) អាចសុំកុមារទៅចិញ្ចឹមបាន ធ្វើឲ្យគ្រួសាមានភាពអ៊ូអរ មានសុភមង្គល នៅក្នុងគ្រួសារថែមមួយកម្រិតទៀត។

[75] មាត្រា៥៥ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[76] មាត្រា៨និងមាត្រា៩ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

[77] មាត្រា១១ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

- ជួលសម្រាលបន្ទុកដល់រដ្ឋាភិបាលចំពោះការចំណាយ ក៏ដូចជាការឧបត្ថម្ភផ្សេងៗក្នុងការចិញ្ចឹមកុមារកំព្រាដែលរស់នៅមណ្ឌលកុមារកំព្រា។
- កាតបន្ថយចំនួនកុមារកំព្រានៅក្នុងប្រទេសកម្ពុជាបានមួយកម្រិតផងដែរ។

# សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវនូវប្រធានបទ របបគតិយុត្តនៃសុំកូន រួចមកក្រុមនាងខ្ញុំពិតជាទទួលបានចំណេះដឹង ការអប់រំបន្ថែមយ៉ាងច្រើនទាក់ទងនឹងរបបនៃសុំកូន ពាក់ព័ន្ធនឹងគោលបំណងការបង្កើតសុំកូននៅកម្ពុជាធ្វើអោយនាងខ្ញុំ សង្កេតឃើញថាសុំកូននៅក្នុងប្រទេសកម្ពុជាពិតជាមានសារៈសំខាន់ខ្លាំងណាស់៖

- ដើម្បីគាំពារចំពោះកុមារកំព្រា កុមារដែលគ្រួសារមានជីវភាពលំបាកខ្លាំងដែលរងចាំការសង្គ្រោះពីសប្បុរសជន ហើយក៏ជាឱកាសមួយសម្រាប់ក្រុមគ្រួសារមួយចំនួនដែលត្រូវការកុមារទៅចិញ្ចឹមមើលថែ ដើម្បីចូលទៅបំពេញចន្លោះនឹងជាផ្នែកមួយនៃគ្រួសារដ៏កក់ក្តៅ។ សុំកូនអាចជួយធ្វើអោយកុមារជាច្រើនអាចទទួលបានឱកាសមានគ្រួសារមួយដែលពេញលេញ កក់ក្តៅ ទទួលបានការមើលថែការពារដូចកុមារដទៃទៀត ព្រមទាំងមានឱកាសបានសិក្សារៀនសូត្រដើម្បីជាសសរទ្រូងប្រទេសជាតិ មិនត្រឹមតែប៉ុណ្ណោះទេសុំកូនក៏ជួយធ្វើអោយគ្រួសារមួយអាចសម្រេចនូវគោលបំណងក្នុងការមានកូនស្រី ឬកូនប្រុស និងគ្រួសារដែលមិនមានកូនសោះ។ ជាពិសេសសម្រាប់កុមារដែលត្រូវបានគេសុំទៅចិញ្ចឹមនៅក្រៅប្រទេស ក្លាយជាឱកាសមួយក្នុងការកសាងអនាគតរបស់ពួកគាត់ជាមួយអ្វីដែលថ្មី។ ទន្ទឹមនឹងនេះរបបគតិយុត្តនៃសុំកូនពិតជាមានសារៈសំខាន់ណាស់ក្នុងការរួមចំណែករៀបចំគោលការណ៍ នីតិវិធី អានុភាពនៃសុំកូន ដើម្បីការពារផលប្រយោជន៍ជារួមរបស់ឪពុកម្តាយបង្កើត ឪពុកម្តាយចិញ្ចឹម និងកូនសុំ។

តែក្នុងនោះរបបគតិយុត្តនៃសុំកូននៅមានផលវិបាកមួយចំនួនតូច៖

- ទោះបីជានៅកម្ពុជាយើងមានរបបគតិយុត្តនៃសុំកូនក៏ពិតមែន ប៉ុន្តែនៅតែស្ថិតក្នុងស្ថានភាពមួយដែលមិនទាន់មានភាពលម្អិតច្បាស់លាស់ ជាពិសេសនីតិវិធីនៃសុំកូន នៅតែមានបញ្ហាចោទយ៉ាងខ្លាំងចំពោះបញ្ហាមនោសញ្ចេតនារវាងឪពុកម្តាយបង្កើត ឪពុកម្តាយចិញ្ចឹម និងកូន ញាតិលោហិត ញាតិពន្ធ ជាដើម។ យើងនៅតែបន្តឃើញមានបញ្ហាបោកបញ្ឆោតកុមារ វាយធ្វើបាប មិនមើលថែអោយបានល្អដូចពេលដំបូង។
- សុំកូនអន្តរប្រទេសដែរគួរអោយបារម្ភបំផុត ព្រោះការយកកុមារទៅចិញ្ចឹមនៅក្រៅប្រទេសធ្វើអោយរដ្ឋាភិបាលពិបាក ក្នុងការតាមដានពិនិត្យមើលស្ថានភាពជីវភាពរបស់កុមារដែលត្រូវយកទៅចិញ្ចឹម។

ការបង្កើតសុំកូន ត្រូវធានាពីនិយ័តភាពនៃការគោរពតាម គោលការណ៍ លក្ខខណ្ឌ និងលក្ខខណ្ឌពិសេសសម្រាប់កុមារទៅតាមប្រភេទនីមួយៗ បែបបទ និងនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់ ទាំងច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែរមានចែងស្តីពី សុំកូនពេញលេញ និងសុំកូនធម្មតា ទើបបង្កើតបាននូវអានុភាពនៃសុំកូន និងដើម្បីធានាបានថា ឧត្តមប្រយោជន៍របស់កុមារត្រូវបានធានាយ៉ាងពិតប្រាកដ។ ប្រសិទ្ធភាពដែលទទួលបានពីការបង្កើតសុំកូន ក៏ជាកត្តាដែលអាចនាំទៅរកការវាយតម្លៃលើសារៈ

ប្រយោជន៍ក្នុងការបង្កើតរបបគតិយុត្តនៃសុំកូនក្នុងប្រទេសមួយ ហើយពិតជាអាចស្វែងរកបាននូវគ្រួសារមួយសម្រាប់កុមារ។ ដោយឡែកក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់ស្តីសុំកូនទាំងក្នុងស្រុក និងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ពិតជាអាចរារាំងការរំលោភបំពានសិទ្ធិកុមារ និងអាចធានាដល់ការការពារសិទ្ធិជាមូលដ្ឋាន និងផ្តល់នូវអត្ថប្រយោជន៍ដល់កុមារបាន។ ក្របខណ្ឌគតិយុត្តលើទំទាក់ទំនងនីតិអន្តរជាតិឯកជន សម្រាប់ការបង្កើតសុំកូនអន្តប្រទេស គឺបោះជំហានទៅរកការគោរពសិទ្ធិរបស់កុមារជាចម្បងដែលពាក់ពន្ធ័សិទ្ធិរស់រានមានជីវិតដែលមានតាំងពីកំណើត ហើយដែលត្រូវធានាដោយរដ្ឋ។

ក្នុងការជ្រើសរើសប្រធានបទនេះមកធ្វើការស្រាវជ្រាវធ្វើអោយក្រុមយើងខ្ញុំកាន់តែទទួលបានការយល់ដឹងយ៉ាងលម្អិតថា ការសុំកូនមិនមែនត្រឹមតែជារបបគតិយុត្តធម្មតានោះទេ តែវាជារបបមួយដែលមានភាពលំបាក និងស្មុគស្មាញបំផុត ដូច្នេះហើយទើបទាក់ទងនឹងរបបគតិយុត្តនៃសុំកូននៅព្រះរាជាណាចក្រកម្ពុជា គួរគប្បីត្រូវកំណត់អោយកាន់តែច្បាស់លាស់ និងលម្អិតពីនីតិវិធីអនុវត្តដោយពឹងលើច្បាប់សារធាតុ និងផ្តោតសំខាន់ជាមួយនឹងការរស់នៅជាក់ស្តែងក្នុងសង្គមជាកត្តាចម្បង។ ជាចុងក្រោយខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសារណាពីប្រធានមួយនេះ អាចផ្តល់ជាអត្ថប្រយោជន៍ និងចំណេះដឹងដ៏ច្រើនសម្រាប់អ្នកសិក្សាទូទៅក្នុងការស្រាវជ្រាវ រួមជាមួយការផ្តល់ជាគន្លឹះក្នុងការស្វែងយល់បន្ថែមទៀតរបស់បុគ្គលជាអ្នកដែលមានបំណងក្នុងការសុំកូនមកជាចំណែកនៃគ្រួសារមួយដែលកក់ក្តៅ។

# អនុសាសន៍

ឆ្លងកាត់តាមការស្រាវជ្រាវ និងចងក្រងនូវប្រធានបទ របបគតិយុត្តនៃសុំកូន រួចមកធ្វើអោយក្រុមនាងខ្ញុំបានទទួលបានការអប់រំ និងចំណេះដឹងយ៉ាងច្រើន ពាក់ព័ន្ធនឹងគោលបំណង ការបង្កើតនីតិវិធីនៃសុំកូននៅកម្ពុជា ធ្វើអោយយើងខ្ញុំសង្កេតឃើញថាចំណុចមួយចំនួន ដែលប្រព័ន្ធការពារក្នុងការមើលថែទាំកុមារមិនទាន់មានភាពរឹងមាំ មានការក្លែងបន្លំ ឆបោក ពីឪពុកម្តាយសុំកូនទៅចិញ្ចឹម ហេតុនេះក្នុងនាមជាអ្នកសិក្សានាងខ្ញុំសូមមានជាមតិក្នុងការដោះស្រាយដោយយើងអាចធ្វើការរៀបចំកិច្ចពិភាក្សា វែកញែក អោយបានច្រើនពីសំណាក់អ្នកដែលមានតួនាទីផ្សេងៗពីគ្នានៅក្នុងសង្គម ដើម្បីជាការបំផុសគំនិតសម្រាប់រកអោយឃើញនូវចំណុចខ្វះខាតដែរគួរកែតម្រូវ។ ពិនិត្យរកនូវចំណុចលម្អិតៗអោយកាន់តែស៊ីជម្រៅជារៀងរាល់ មួយឬពីរឆ្នាំម្តង ពីនីតិវិធីសុំកូនទាំងក្នុងស្រុក និងក្រៅស្រុក រួមទាំងស្តង់ដារគ្រប់គ្រងលើករណីមានវិវាទរបស់ឪពុកម្តាយ កូន និងសមាជិកញាតិ។

ក្រុមយើងខ្ញុំបានបំផុសគំនិតក្នុងការផ្តល់នូវអនុសាសន៍មួយចំនួនជាការស្នើសុំដល់ស្ថាប័នដែលពាក់ព័ន្ធ ៖

- ការបង្កើតសុំកូននៅកម្ពុជាមានបញ្ហាចោទយ៉ាងខ្លាំងទាក់ទងនឹងវិវាទរវាងឪពុកម្តាយចិញ្ចឹមនឹងកូនសុំ ឪពុកម្តាយបង្កើតនឹងកូន ឪពុកម្តាយចិញ្ចឹមនឹងឪពុកម្តាយបង្កើត ជាដើម។ ដូច្នេះជាការស្នើសុំ ដល់តុលាការដែលទទួលការដាក់ពាក្យស្នើសុំសុំកូន អោយមានការយកចិត្តទុកដាក់យ៉ាងតឹងរឹង ក្នុងការពិនិត្យមើលលក្ខណៈសម្បត្តិរបស់ឪពុកម្តាយចិញ្ចឹម ឪពុកម្តាយបង្កើត រួមជាមួយចរិតលក្ខណរបស់កូនសុំថាការរស់បានចុះសម្រុងគ្នាជាមួយឪពុកម្តាយចិញ្ចឹមដែរឬទេ ហើយឪពុកម្តាយចិញ្ចឹមពិតជាមានលក្ខខណ្ឌសមស្របក្នុងការចិញ្ចឹមមើលថែកុមារដែរឬទេ។
- ជាចុងក្រោយក្រុមនាងខ្ញុំសូមស្នើសុំទៅ ឪពុកម្តាយដែលសុំកូនយកទៅចិញ្ចឹមមិនថាជាសុំកូនធម្មតា សុំកូនពេញលេញ សុំកូនអន្តរប្រទេស មេត្តាស្រឡាញ់ ចិញ្ចឹមបីបាច់ ថែរក្សាការពារ ផ្តល់នូវ ការអប់រំសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្តដល់ពួកគេ។ សូមកុំប្រព្រឹត្តិនូវទង្វើបោកបញ្ឆោត កេងបន្លំ វាយធ្វើបាបរាងកាយ ផ្លូវចិត្តកុមារ ព្រោះកុមារជាក្រដាសមួយសរស្តើងងាយរងការប៉ះទង្គិចពីទង្វើទាំងនេះណាស់។ កុមារម្នាក់ៗតែងតែមានក្តីសង្ឃឹមថ្មីឡើងវិញនៅពេលដែរពួកគេទទួលបានគ្រួសារមួយថ្មីដែលផ្តល់នូវសុភមង្គលក្តីស្រឡាញ់ដល់ពួកគេ។

# ឯកសារយោង

១. ច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

២.  អនុសញ្ញាទីក្រុងឡាអេស្តីពី  ការការពារកុមារ  នឹងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសត្រូវបានផ្តល់សច្ចាប័នយល់ព្រមដោយព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧

៣.ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

៤.. ច្បាប់ស្តីពី "នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង" ឆ្នាំ២០១០

៥. ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩

៦. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០

៧. នីតិបេតិកភណ្ឌ និងគ្រួសារ

៨. ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨

៩. ច្បាប់ស្តីពី "សុំកូនអន្តរប្រទេស" ឆ្នាំ២០០៩

១០. អនុសញ្ញា ស្តីពីសិទ្ធិកុមារ និងពិធីសាបន្ថែម

១១. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨

## បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធ១ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
- ឧបសម្ព័ន្ធ២ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជា ២០១០
- ឧបសម្ព័ន្ធ៣ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

# ឧបសម្ព័ន្ធ១

**ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧**

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ក្រមរដ្ឋប្បវេណី

**មាត្រា ១០០៦.-** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

## ផ្នែកទី ២
## សុំកូន

### កថាភាគទី ១
### សុំកូនពេញលេញ

**មាត្រា ១០០៧.-** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្ដាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមបាន ។

**មាត្រា ១០០៨.-** សុំកូនដោយសហការរវាងប្ដីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្ដី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្ដាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

**មាត្រា ១០០៩.-** អាយុរបស់ឪពុកម្ដាយចិញ្ចឹម

ឪពុកម្ដាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើងទៅ ហើយត្រូវមាន

អាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ១០១០.–** អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

**មាត្រា ១០១១.–** ការយល់ព្រមរបស់ឪពុកម្ដាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្ដាយនោះ មិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្ដាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ១០១២.–** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្ដាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

**មាត្រា ១០១៣.–** អំឡុងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

**មាត្រា ១០១៤.–** ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមក

អនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្ដាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្ដាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) នៃក្រមនេះ ។

**មាត្រា ១០១៥.–** អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបានឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និង ត្រូវទទួលបានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្ដាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។

**មាត្រា ១០១៦.–** ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាគីនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្ដាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-បើមានការធ្វើបាបដោយឪពុកម្ដាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ-បើឪពុកម្ដាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០១៧.–** អានុភាពនៃការកាត់កាល់ស៊ុំកូនពេញលេញ

ញាតិភាពរវាងកូនស៊ុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយស៊ុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

**មាត្រា ១០១៨.–** ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃស៊ុំកូនពេញលេញ

ប្រសិនបើបានបង្កើតស៊ុំកូនពេញលេញ បញ្ជីកំណើតរបស់កូនស៊ុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្តីពីស៊ុំកូនឡើយ ។

**មាត្រា ១០១៩.–** សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនស៊ុំពេញលេញ

កូនស៊ុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្តីពីស៊ុំកូនបាន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទ-យុត្តិរបស់តុលាការ ។

## កថាភាគទី ២

## ស៊ុំកូនធម្មតា

**មាត្រា ១០២០.–** ពាក្យសុំនៃស៊ុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនស៊ុំ ទៅតុលាការ ឱ្យបង្កើតស៊ុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនស៊ុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនស៊ុំ ជាអនីតិជន អ្នកមានអំណាច

មេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

**មាត្រា ១០២១.–** ករណីដែលបុគ្គលដែលនឹងក្លាយជាឪពុក ឬម្ដាយចិញ្ចឹមមានសហព័ទ្ធ

បើបុគ្គលដែលមានសហព័ទ្ធ សុំកូនដែលជាអនីតិជន បុគ្គលនោះត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលយកកូនរបស់សហព័ទ្ធ មកធ្វើជាកូនសុំ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២២.–** ការយល់ព្រមរបស់សហព័ទ្ធ

ចំពោះបុគ្គលដែលមានសហព័ទ្ធ ដើម្បីដាក់ពាក្យសុំនៃសុំកូនធម្មតា ត្រូវទទួលការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២៣.–** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនធម្មតា

១-តុលាការ អាចឱ្យបង្កើតសុំកូនបាន លុះត្រាតែករណីដែលអាចបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ។

២-តុលាការមិនត្រូវឱ្យបង្កើតសុំកូនឡើយ បើយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ភេទដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត ។

**មាត្រា ១០២៤.–** ករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន

១-បើបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជន

នោះ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន បើឪពុកម្ដាយបង្កើតរបស់បុគ្គលនោះបានលែងលះហើយ តុលាការត្រូវសួរយោបល់របស់ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើអនីតិជនបានដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ដើម្បីបង្កើតសុំកូន ត្រូវទទួលការយល់ព្រមពីអនីតិជននោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០២៥.-** សុំកូនរវាងអ្នកអាណាព្យាបាល និង ជននៅក្រោមអាណាព្យាបាល

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដាក់ពាក្យសុំឱ្យបង្កើតសុំកូនដោយយកអនីតិជននៅក្រោមអាណាព្យាបាលរបស់ខ្លួន មកធ្វើជាកូនសុំ ឬ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ដាក់ពាក្យសុំឱ្យបង្កើតសុំកូន ដោយយកជននៅក្រោមអាណាព្យាបាលទូទៅរបស់ខ្លួន មកធ្វើជាកូនសុំ តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវ ក្នុងការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតួនាទីរបស់អ្នកអាណាព្យាបាលបានចប់ តែមិនទាន់បានបញ្ចប់ការគណនាទូទាត់ចំណូលចំណាយក្នុងការគ្រប់គ្រង ។

**មាត្រា ១០២៦.-** អានុភាពនៃសុំកូនធម្មតា ចំពោះបុគ្គលភាព

១-ទោះបីជាមានការបង្កើតសុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ត្រូវបន្តអត្ថិភាព ហើយកូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ។

២-កូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិទាមទារ និង ករណីយកិច្ចផ្គត់ផ្គង់

អាហារកាតព្វកិច្ច ។

**មាត្រា ១០២៧.-** អានុភាពនៃសុំកូន ក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ជាអាទិ៍

១-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១០១៥ (អានុភាពនៃសុំកូនពេញលេញ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសុំកូនធម្មតា ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-ក្នុងករណីដែលកូនសុំ ជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធ មកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្ដាយចិញ្ចឹម និង សហព័ទ្ធនោះ ។

**មាត្រា ១០២៨.-** ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា

១-ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យកាត់កាល់សុំកូនបាន ក្នុងករណីដែលភាគីសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ ។

២-ក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ដោយឪពុកម្ដាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់ ។ ប៉ុន្តែ បើកូនសុំដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ហើយ ត្រូវទទួលការយល់ព្រមពីកូនសុំនោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើឪពុកម្ដាយបង្កើតរបស់កូនសុំ បានលែងលះគ្នាហើយ ឪពុកម្ដាយបង្កើតរបស់កូនសុំនោះ ត្រូវពិភាក្សា និង កំណត់ថា ឪពុក ឬ ម្ដាយបង្កើត ជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបានៅក្រោយពេលកាត់កាល់ ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូន ។

**មាត្រា ១០២៩.–** ការកាត់កាល់រវាងប្ដីប្រពន្ធដែលបានសុំកូនដោយសហការ និង កូនសុំជាអនីតិជន

ក្នុងករណីដែលប្ដីប្រពន្ធដែលបានសុំកូនដោយសហការគ្នា ជាឪពុកម្ដាយចិញ្ចឹម ដើម្បីកាត់កាល់កូនសុំជាអនីតិជន ប្ដីប្រពន្ធត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស្ម័គ្រកូនធម្មតា) ខាងលើនេះ ជាមួយគ្នា ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះប្ដីប្រពន្ធណាម្ខាងមិនអាចបង្ហាញឆន្ទៈរបស់ខ្លួន ។

**មាត្រា ១០៣០.–** ការវិនិច្ឆ័យអំពីការកាត់កាល់ស្ម័គ្រកូនធម្មតា

បើមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស្ម័គ្រកូនធម្មតា) ខាងលើនេះ តុលាការអាចសម្រេចឱ្យកាត់កាល់ស្ម័គ្រកូនបាន លុះត្រាតែបានបញ្ជាក់ថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ។

**មាត្រា ១០៣១.–** មូលហេតុនៃការកាត់កាល់

១-ភាគីម្ខាងនៃស្ម័គ្រកូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យកាត់កាល់បាន លុះត្រាតែក្នុងករណីខាងក្រោមនេះ :

ក-បើត្រូវបានបោះបង់ចោល ដោយភាគីម្ខាងទៀត ដោយទុច្ចរិត ។

ខ-បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ (មួយ) ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព ។

គ-បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្ដាលឱ្យមានការពិបាកក្នុងការបន្តស្ម័គ្រកូន ។

២-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្ដាយចិញ្ចឹម មិនអាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនសុំបានឡើយ ។

៣-បើកូនសុំជាអនីតិជន បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនសុំដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះឪពុកម្ដាយចិញ្ចឹម ។

**មាត្រា ១០៣២.–** អានុភាពនៃការកាត់កាល់សុំកូនធម្មតា

១-អានុភាពទាំងឡាយនៃសុំកូនធម្មតា ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់ ។

២-ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញ នូវនាមត្រកូលមុនសុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន ។

**មាត្រា ១០៣៣.–** ការចុះបញ្ជីនៃសុំកូនធម្មតា និង បញ្ជីកំណើត

ប្រសិនបើបានបង្កើតសុំកូនធម្មតា ត្រូវសរសេរការបង្កើតសុំកូនធម្មតា នៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ ។

# ឧបសម្ព័ន្ធ២

## ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

# ច្បាប់
# ស្តីពី
# នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី
# ដែលមិនមែនជាបណ្តឹង

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលដៅនៃច្បាប់នេះ

ច្បាប់នេះមានគោលដៅបញ្ញត្តនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ។

### មាត្រា ២.- គោលបំណងនៃច្បាប់នេះ

ច្បាប់នេះមានគោលបំណងធានាការអនុវត្តឲ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ។

### មាត្រា ៣.- វិសាលភាពនៃច្បាប់នេះ

១- ក្នុងចំណោមចំណុចដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការ ដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗ នៃតារាងឧបសម្ព័ន្ធ តុលាការត្រូវសម្រេចសេចក្ដីតាមបញ្ញត្តិនៃច្បាប់នេះ លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង ។

២- ការសម្រេចសេចក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងដោយដីកាសម្រេច ។

៣- ក្រៅពីករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់នេះ បញ្ញត្តិស្ដីពីដីកាសម្រេច ដូចមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ។

## ជំពូកទី ២
## តុលាការ
## ផ្នែកទី ១
## សមត្ថកិច្ចសាលាជម្រះក្ដី

### មាត្រា ៤.- តុលាការដែលមានសមត្ថកិច្ច

១- រឿងក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ ។

២- សមត្ថកិច្ចសាលាជម្រះក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ដោយយកពេលដាក់ពាក្យសុំ ។

## មាត្រា ៥.- ការកំណត់តុលាការដែលមានសមត្ថកិច្ច

១- ក្នុងករណីដែលតុលាការមានសមត្ថកិច្ច មិនអាចអនុវត្តសិទ្ធិសម្រេចសេចក្តីបាន ដោយសារច្បាប់ ឬ ហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនអាចកំណត់បាន ដោយសារដែនសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ច ដោយដីកាសម្រេចតាមពាក្យសុំ ។

២- ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចប្តឹងឧបាស្រ័យបានឡើយ ។

## មាត្រា ៦.- ការចាត់ចែងរឿងក្តីខុសសមត្ថកិច្ច

១- ប្រសិនបើតុលាការយល់ឃើញថា រឿងក្តីណាមួយមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនេះត្រូវផ្ទេររឿងក្តីនោះទៅតុលាការដែលមានសមត្ថកិច្ច តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ ។

២- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ ។ នៅពេលដាក់ពាក្យសុំនេះ ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់អំពីមូលហេតុនៃពាក្យសុំនោះ ។

## មាត្រា ៧.- សមត្ថកិច្ចជាអាទិភាព និង ការផ្ទេរ

១- ក្នុងករណីមានតុលាការច្រើនមានសមត្ថកិច្ចលើរឿងក្តីណាមួយ តុលាការដែលទទួលពាក្យសុំមុនគេចំពោះរឿងក្តីនោះ ត្រូវមានសមត្ថកិច្ច ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យដើម្បីចាត់ចែងរឿងក្តី តុលាការអាចផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិបាន ។

៣- ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ លើកលែងតែករណីដែលមានការដាក់ពាក្យសុំនៅកាលបរិច្ឆេទ។

ROYAUME DU CAMBODGE
PALAIS ROYAL

Kol

### មាត្រា ៨.- ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

តុលាការអាចពិនិត្យភស្តុតាងចំពោះបញ្ហាដែលទាក់ទងនឹងសមត្ថកិច្ចដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

### មាត្រា ៩.- បណ្តឹងជំទាស់

១- ចំពោះដីកាសម្រេចផ្ទេរ និង ដីកាសម្រេចលើកចោលពាក្យសុំផ្ទេរ អាចប្តឹងជំទាស់បាន ។

២- បញ្ញត្តិនៃមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) និង មាត្រា ៤១ (ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយពីអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត) នៃច្បាប់នេះ ត្រូវយកមកអនុវត្តផ្ទុកគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

### មាត្រា ១០.- អានុភាពនៃដីកាសម្រេចផ្ទេរ ជាស្ថាពរ

១- ដីកាសម្រេចស្ថាពរនៃការផ្ទេរ ត្រូវមានអានុភាពឲ្យតុលាការដែលទទួលការផ្ទេរប្រតិបត្តិតាម ។

២- តុលាការដែលទទួលការផ្ទេរ មិនអាចផ្ទេររឿងក្តីទៅតុលាការផ្សេងទៀតបានឡើយ ។

៣- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ រឿងក្តីនោះត្រូវចាត់ទុកថាតុលាការដែលទទួលការផ្ទេរចាត់ការតាំងពីដើម ។

៤- នៅពេលដីកាសម្រេចផ្ទេរចូលជាស្ថាពរ តុលាការដែលបានសម្រេចការផ្ទេរ ត្រូវបញ្ជូនសំណុំរឿងអំពីរឿងក្តីនេះ ទៅតុលាការដែលទទួលការផ្ទេរ ។

## ផ្នែកទី ២
## រចនាសម្ព័ន្ធនៃតុលាការ

### មាត្រា ១១.- ការជម្រះក្តីលើកទី ១ ដោយចៅក្រមមួយរូប ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម

១- នៅសាលាដំបូង រឿងក្តីត្រូវទទួលបន្ទុកដោះស្រាយដោយចៅក្រមម្នាក់ លើកលែងតែករណីដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២- ចំពោះរឿងក្តីដែលតុលាការយល់ឃើញថា គួរតែត្រូវបានវិនិច្ឆ័យ និង ជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃជនពាក់ព័ន្ធ និង បញ្ហាផ្សេងទៀត ត្រូវទទួលបន្ទុកដោះស្រាយដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ។

៣- ក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវមានចៅក្រម ៣ ( បី ) នាក់ ហើយចាត់តាំងម្នាក់ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៤- ដីកាសម្រេចឲ្យវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយយោងតាមកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សា ។

## មាត្រា ១២.- ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការពិភាក្សានៃក្រុមប្រឹក្សាជំនុំជម្រះមិនត្រូវធ្វើជាសាធារណៈទេ ។

២- ការពិភាក្សាត្រូវបានបើក និងដឹកនាំដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៣- ចៅក្រមម្នាក់ៗ ត្រូវបញ្ចេញមតិយោបល់របស់ខ្លួនក្នុងការពិភាក្សានេះ ។

៤- ដំណើរការនៃការពិភាក្សា មតិយោបល់របស់ចៅក្រមម្នាក់ៗ និង ចំនួនសំឡេងនៃមតិត្រូវរក្សាទុកជាសម្ងាត់ ។

## មាត្រា ១៣.- ការសម្រេចនៃក្រុមប្រឹក្សាជំនុំជម្រះ

១- ការសម្រេចត្រូវធ្វើឡើងដោយមតិភាគច្រើនរបស់ចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ ។

២- ចៅក្រមម្នាក់ៗ ក្នុងក្រុមប្រឹក្សាជំនុំជម្រះ ត្រូវមានសិទ្ធិសម្រេចស្មើគ្នា ។

# ផ្នែកទី ៣
# ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ និង ការដកខ្លួន

## មាត្រា ១៤.- ការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ និង ការដកខ្លួន របស់ចៅក្រម ជាអាទិ៍

១- បញ្ញត្តិស្តីពីការដកហូតសមត្ថកិច្ចជំនុំជម្រះ បណ្តឹងជំទាស់ និងការដកខ្លួនរបស់ចៅក្រម និង ក្រឡាបញ្ជីតុលាការនៅក្នុងផ្នែកទី ៣ (ការបែងចែករឿងក្តី និង ការដកហូតសមត្ថកិច្ចជំនុំជម្រះ និង បណ្តឹងជំទាស់) ជំពូកទី ២ គន្ថីទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ។

២- បញ្ញត្តិនៃមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) និង មាត្រា ៤១ (ការបំពេញនូវសកម្មភាពប្តឹងជំទាស់ ក្រោយអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងផុត) នៃច្បាប់នេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងជំទាស់ដែលកំណត់ក្នុងបញ្ញត្តិនៃផ្នែកទី ៣ (ការបែងចែករឿងក្តី

និង ការដកហូតសមត្ថកិច្ចជំនុំជម្រះ និងបណ្តឹងជិតចិត្ត) ជំពូកទី ២ គន្ថីទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានយកមកអនុវត្ត ដោយយោងតាមកថាខណ្ឌទី ១ ខាងលើនេះ ។

## ជំពូកទី ៣
## ជនពាក់ព័ន្ធ

### មាត្រា ១៥.- ជនពាក់ព័ន្ធ

ចំពោះរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ ជនដាក់ពាក្យសុំ ភាគីម្ខាងទៀតនៃពាក្យសុំ និងជនផ្សេងទៀត ដែលទទួលឥទ្ធិពលផ្ទាល់ដល់សិទ្ធិរបស់ខ្លួន ឬ ដល់ឋានៈរបស់ខ្លួនតាមផ្លូវច្បាប់ដោយដីកាសម្រេចអំពីរឿងក្តីនោះ អាចចូលរួមក្នុងនីតិវិធីនៃរឿងក្តីនោះ ក្នុងនាមជាជនពាក់ព័ន្ធនៅក្នុងរឿងក្តីនោះ ។

### មាត្រា ១៦.- សមត្ថភាពរបស់ជនពាក់ព័ន្ធ

ជនដែលកំណត់ក្នុងមាត្រា ១៥ (ជនពាក់ព័ន្ធ) ខាងលើនេះ ត្រូវតែជាបុគ្គលដែលអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត ។

### មាត្រា ១៧.- សមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាពនៃនីតិវិធី

១- បុគ្គលដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និង ច្បាប់ផ្សេងទៀត អាចធ្វើសកម្មភាពនៃនីតិវិធីចាំបាច់ ដោយតាំងខ្លួនជាជនពាក់ព័ន្ធក្នុងនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះបាន ។

២- អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ មិនអាចធ្វើសកម្មភាពនៃនីតិវិធីសុពលបានឡើយ ប្រសិនបើសកម្មភាពនោះមិនបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលបានកំណត់ខាងក្រោមនេះ ៖

ក- ករណីដែលអនីតិជនអាចធ្វើសកម្មភាពដោយឯករាជ្យ ។

ខ- ករណីដែលអនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ ធ្វើសកម្មភាពពាក់ព័ន្ធនឹងឋានៈរបស់ខ្លួន ។

អ្នកតំណាងដោយផ្អែកលើការអនុញ្ញាតរបស់តុលាការដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៩ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ។

### មាត្រា ២១.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីសិទ្ធិតំណាងដោយអាណត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី

បញ្ញត្តិនៃមាត្រា ៥៥ (ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់) មាត្រា ៥៦ (ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ) និង មាត្រា ៥៧ (វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងដោយអាណត្តិ ។

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្តី

### មាត្រា ២២.- បន្ទុកនៃប្រាក់ប្រដាប់ក្តី

១- ដើម្បីដាក់ពាក្យសុំតាមនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។

២- បញ្ញត្តិនៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) និង មាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីភាគី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាក់ប្រដាប់ក្តីក្រៅពីពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

៣- ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ
គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ
លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ ។

៤- ចំពោះរឿងក្តីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬ រឿងក្តីដែលតុលាការបានចាប់ផ្តើមដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ជាបន្ទុករបស់រដ្ឋ ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានជនច្រើននាក់ដែលត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តីដោយរួមគ្នា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានបណ្តឹងជំទាស់ ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ។

## មាត្រា ២៥.- ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន

ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់ការពិនិត្យភស្តុតាង ការកោះហៅ ការជូនដំណឹង និង ការចាត់ចែងចាំបាច់ផ្សេងទៀត ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ រដ្ឋត្រូវបង់ជំនួសជាមុន ប៉ុន្តែចំពោះសកម្មភាពដែលត្រូវការប្រាក់ប្រដាប់ក្តី តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធបង់ប្រាក់ប្រដាប់ក្តីនោះជាមុនបាន ។

# ជំពូកទី ៥
# ការវិនិច្ឆ័យ

## មាត្រា ២៦.- របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ

១- ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

២- នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

៣- ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ។ ក្នុងករណីនេះក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និង ចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ ។

៤- ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ ។



# ឧបសម្ព័ន្ធ៣

## ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

# ច្បាប់

# ស្តីពី

# ស្នំកូនអន្តរប្រទេស

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ពីគោលការណ៍ លក្ខខណ្ឌ នីតិវិធី ទម្រង់បែបបទ និង អានុភាពនៃសុំកូនអន្តរប្រទេស ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងធានាឧត្តមប្រយោជន៍ និង ការពារសិទ្ធិជាមូលដ្ឋាន របស់កុមារ ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពលើការសុំកុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្តីប្រពន្ធ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយផ្សេងទៀត ដើម្បីយកទៅចិញ្ចឹមជាកូន ដែលទទួលស្គាល់ដោយច្បាប់នៅប្រទេសនោះ ។

**មាត្រា ៤.-**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

- **ការថែទាំជំនួស** សំដៅដល់ការថែទាំ ដែលផ្តល់ទៅឱ្យកុមារកំព្រា និង កុមារងាយរងគ្រោះ ដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើតនៃកុមារទាំងនោះ ។
- **កុមារដែលត្រូវការនូវការថែទាំពិសេស** សំដៅដល់កុមារពិការផ្នែកកាយសម្បទាធ្ងន់ធ្ងរ ឬ ពិការផ្នែកស្មារតី ឬ កុមារដែលមានជំងឺរ៉ាំរ៉ៃ ។
- **កុមារដែលត្រូវគេបោះបង់ចោល** សំដៅដល់កុមារដែលអាជ្ញាធរមានសមត្ថកិច្ចរកឃើញ ឬ ត្រូវបានសាធារណជនរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច និង ជាកុមារដែលគេមិនស្គាល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ជាកុមារដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបោះបង់ចោល និង មិនឃើញអ្នកទាំងនោះ យ៉ាងតិច ៥(ប្រាំ) ខែជាប់គ្នា ។

- **ជនម្នាក់** សំដៅដល់ជនដែលគ្មានសហព័ទ្ធស្របច្បាប់ ។

- **ទីភ្នាក់ងារសុំកូនអន្តរប្រទេស** សំដៅដល់ទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួលកូនសុំ ដើម្បីធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

- **មុត្តភាព** សំដៅដល់ក្រសែញាតិ ដែលទាក់ទងពីឪពុកម្តាយទៅកូនបង្កើតរបស់ខ្លួន ។

- **ប្រទេសលំនៅឋានអចិន្ត្រៃយ៍** សំដៅដល់ប្រទេសដែលជនណាមួយកំពុងរស់នៅដោយមានបំណងយកប្រទេសនោះធ្វើជាលំនៅឋានអចិន្ត្រៃយ៍ ។ ជននោះត្រូវបានទទួលស្គាល់ដោយច្បាប់នៃប្រទេសដែលខ្លួនរស់នៅ ថាមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសនោះ ។

- **មណ្ឌលកុមារកំព្រា** សំដៅដល់មណ្ឌលរបស់រដ្ឋ ឬ របស់អង្គការមិនមែនរដ្ឋាភិបាល ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ចិញ្ចឹមថែទាំ និង ផ្តល់នូវតម្រូវការជាមូលដ្ឋានគ្រប់យ៉ាងក្នុងការអភិវឌ្ឍរបស់កុមារដែលគ្មានឪពុកម្តាយ ឬ គ្មានឪពុក ឬ គ្មានម្តាយ ឬ កុមារ ដែលត្រូវបោះបង់ចោល ឬ កុមារដែលឪពុកម្តាយ ឬ អ្នកអាណាព្យាបាលពុំមានលទ្ធភាពផ្តល់ការថែទាំគ្រប់គ្រាន់ ។

- **ប្តីប្រពន្ធ** សំដៅដល់បុរសម្នាក់ និង ស្ត្រីម្នាក់ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ។

- **សុំកូនដោយសាច់ញាតិ** សំដៅដល់ការសុំកូនដោយអ្នកសុំនូវកុមារដែលត្រូវជាចៅរបស់ខ្លួន ចៅទួតរបស់ខ្លួន ក្មួយរបស់ខ្លួន ឬ កុមារដែលត្រូវជាកូន ចៅ ចៅទួត ឬ ក្មួយរបស់សហព័ទ្ធរបស់ខ្លួន ។

- **សុំកូនពេញលេញ** សំដៅដល់សុំកូនដែលមានអានុភាពបង្កើតនូវចំនាក់ចំនងអចិន្ត្រៃយ៍ ជាឪពុកម្តាយ និង កូនរវាងឪពុកម្តាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម និង កូនសុំ និង បញ្ចប់សិទ្ធិ និង កាតព្វកិច្ចរវាងកូននិងឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាល [illegible]ជនរបស់ខ្លួន ។

- **អ្នកសុំ** សំដៅដល់ប្តីប្រពន្ធដែលកំពុងស្វះស្វែងសុំកុមារយកទៅចិញ្ចឹម ។

- **ឪពុកម្តាយចិញ្ចឹម** សំដៅដល់ប្តីប្រពន្ធដែលបានទទួលសិទ្ធិជាផ្លូវការពី

តុលាការមានសមត្ថកិច្ច ឱ្យធ្វើជាឪពុកម្តាយថ្មីនៃកូនសុំស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ។

## ជំពូកទី ២

## គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស

**មាត្រា ៥.-**

សុំកូនអន្តរប្រទេសត្រូវអនុវត្តតាមគោលការណ៍ដូចតទៅ :

១- កុមារត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និង ការយោគយល់ ដើម្បីឱ្យមានការអភិវឌ្ឍពេញលេញ និង យ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។ សុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឱ្យកុមាររស់នៅក្នុងគ្រួសារកំណើត និង ក្រោយពីបានធ្វើការពិចារណា អំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- សុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាតែជាសុំកូនពេញលេញ ដែលបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំ និង កូនសុំជាអចិន្ត្រៃយ៍ និង ដែលផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ ។

៣- កុមារទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០ អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបានដោយមិនមានការរើសអើងអំពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិកំណើត ឋានៈក្នុងសង្គម ធនធាន ពិការភាព ឬ ស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬរបស់ឪពុកម្តាយ ឬ របស់ឪពុក ឬ របស់ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

៤- រាល់ការសម្រេច និង សកម្មភាពទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេស ត្រូវគិតគូរឱ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ ។

៥- តុលាការ និង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការសុំកូនអន្តរប្រទេស ត្រូវធានាថា នៅពេលកំពុងដំណើរការនីតិវិធីសុំកូន កុមារដែលមានសមត្ថភាពអាចយល់ដឹងសព្វគ្រប់ ត្រូវបានពិគ្រោះយោបល់ និង ពន្យល់ណែនាំឱ្យបានត្រឹមត្រូវអំពីអានុភាព

នានា ដែលកើតចេញពីសុំកូននេះដោយគិតគូរដល់សេចក្ដីប្រាថ្នា និង មតិរបស់កុមារ ដើម្បីឧត្តមប្រយោជន៍របស់កុមារ ។

៦- ហាមការធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេស ។ អាជីវកម្ម ឬ សកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេសមាន :

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឱ្យបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើតដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្ដីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុក ឬ ម្ដាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត និង

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្ដីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

៧- អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការសុំកូនអន្តរប្រទេស មិនបណ្ដាលឱ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និង ត្រូវបង្ការមិនឱ្យមានការចាប់ពង្រត់ ការលក់ និង ការជួញដូរកុមារក្នុងពេលកំពុងដំណើរការសុំកូនអន្តរប្រទេស ។ មានតែប្រាក់ចំណាយ សោហ៊ុយ និង វិភាគទាន ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះដែលត្រូវបង់ ។

## ជំពូកទី ៣

## អាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស

**មាត្រា ៦.-**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច បំពេញតួនាទីជាអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស ។

**មាត្រា ៧.–**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសមានតួនាទី និង ភារកិច្ចដូចតទៅ :

១- រៀបចំ និង ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និង នីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស ។

២-ធ្វើសហប្រតិបត្តិការ និង ធ្វើការសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នា ទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និង ទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង ជាមួយអាជ្ញាធរកណ្តាល និង អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសទទួល ។

៣- ចាត់វិធានការសមស្របដើម្បីបង្ការ និង ទប់ស្កាត់ ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬ ផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ។

៤- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។

៥- ពិនិត្យលើសំណើរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់ ។

៦- ធ្វើអធិការកិច្ចលើកិច្ចការពាក់ព័ន្ធសុំកូនអន្តរប្រទេស ។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ ។

៧- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច យល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨.–**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានរដ្ឋបាលសុំកូនអន្តរប្រទេសជាលេខាធិការ ។ មន្ត្រីបម្រើការក្នុងរដ្ឋបាលសុំកូនអន្តរប្រទេសរួមមាន អ្នកធ្វើការងារផ្នែកសង្គមកិច្ច [illegible] និង អ្នកជំនាញខាងច្បាប់បានទទួលការបណ្តុះបណ្តាលពិសេស ស្តីពីសុំកូន

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ៩.-**

រដ្ឋបាលសុំកូនអន្តរប្រទេស មានតួនាទី និង ភារកិច្ចដូចតទៅ :

១-រៀបចំ ថែរក្សាបញ្ជីសម្ងាត់ និង សំណុំឯកសាររបស់កុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

២-វាយតម្លៃស្ថានភាពកុមារទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីសម្ងាត់ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុតសម្រាប់កុមារ និង ធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ ។

៣-ប្រឹងប្រែងរកដំណោះស្រាយឱ្យអស់លទ្ធភាពក្នុងប្រទេស ក្នុងការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬ នៅជាមួយអ្នកអាណាព្យាបាល មុននឹងដំណើរការសុំកូនអន្តរប្រទេស ។

៤-ទទួលពិនិត្យ និង ចាត់ការពាក្យសុំកូនអន្តរប្រទេស និង ឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់អ្នកសុំ ។

៥-ផ្គូផ្គងអ្នកសុំជាមួយកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស និង ផ្ដល់មតិយោបល់លើករណីសុំកូនអន្តរប្រទេស ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៦-ផ្ដល់ដំណឹងទៅអាជ្ញាធរកណ្ដាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល អំពីនីតិវិធីសុំកូន និង ការវិវត្តនៃករណីសុំកូន ។

៧-សម្របសម្រួលការប្រគល់កុមារទៅឱ្យអ្នកសុំ និង រៀបចំឯកសារ ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ ។

៨-ផ្ដល់ ឬ សម្របសម្រួលការផ្ដល់សេវាក្រោយសុំកូនសមស្របដល់កុមារ [illegible] និង គ្រួសារបង្កើតតាមការចាំបាច់ ។

៩-ផ្ដល់មតិយោបល់ទាក់ទងនឹងការផ្ដល់ការអនុញ្ញាតឱ្យទីភ្នាក់ងារសុំកូនអន្តរ-

ប្រទេស ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ឬ ការដកហូតការអនុញ្ញាត ជូនអាជ្ញាធរកណ្ដាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ។

១០- បំពេញភារកិច្ចផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសតាមការចាំបាច់ ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ជា របស់ព្រះរាជាណាចក្រកម្ពុជា និង តាមការប្រគល់អំណាចរបស់អាជ្ញាធរកណ្ដាល ។

## ជំពូកទី ៤

## លក្ខខណ្ឌសម្រាប់សុំកូន

## ផ្នែកទី ១

## កូនសុំ

**មាត្រា១០.–**

កុមារដែលអាចជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌទាំងអស់ ដូចខាងក្រោម :

១- កុមារសញ្ជាតិខ្មែរដែលមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-កុមារមានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអាចអនុញ្ញាតបានដល់អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។ ក្នុងករណី កុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំ អាចអនុញ្ញាតឱ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

៣- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៤- កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬ កុមារដែលស្ថិតនៅក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត ។

៥- កុមារនោះត្រូវបានប្រកាសថាអាចសុំជាកូនចិញ្ចឹមបាន ដោយអនុលោមតាមមាត្រា ១៣ នៃច្បាប់នេះ ។

ក្នុងករណីសុំកូនដោយសាច់ញាតិ សុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលរស់នៅក្នុង ឬ ក្រៅមណ្ឌលកុមារកំព្រា ។

**មាត្រា ១១.-**

ករណីមានកុមារត្រូវបានរកឃើញ និង បញ្ជូនមកមណ្ឌលកុមារកំព្រា ហើយរកមិនឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានមណ្ឌលកុមារកំព្រា ត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត អំពីវត្តមានរបស់កុមារ ដែលបានចូលមកស្នាក់នៅក្នុងមណ្ឌល យ៉ាងយូរបំផុតរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីពេលដែលកុមារមកដល់មណ្ឌល ។ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីបញ្ចូលឈ្មោះកុមារទៅក្នុងបញ្ជី ស្តីពីកុមារដែលត្រូវបានរាយការណ៍ថាត្រូវបានគេបោះបង់ចោល ។

មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាលសម្រាប់អនីតិជនមុន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសាធារណៈទៅតាមលទ្ធភាពដូចជា ទូរទស្សន៍ វិទ្យុ ឬ សារព័ត៌មាន និង រូបភាពរបស់កុមារនោះ ។ ជនណាដែលអះអាងថាខ្លួនជាឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ជននោះត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថាខ្លួនមានជាប់ទាក់ទងជាសាច់ញាតិ ឬ អ្នកអាណាព្យាបាល សម្រាប់អនីតិជនជាមួយកុមារស្របទៅតាមបទប្បញ្ញត្តិជាធរមាន ។

បន្ទាប់ពីការផ្សព្វផ្សាយដំណឹងរយៈពេល ៥ (ប្រាំ) ខែ នៅតែរកមិនឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាល សម្រាប់អនីតិជនមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការខិតខំស្រាវជ្រាវនេះ ហើយត្រូវផ្ញើមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងបញ្ជីស្តីពីកុមារដែលត្រូវបោះបង់ចោល ។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ រហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត គឺជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ បញ្ញត្តិស្តីពីអាណាព្យាបាលសម្រាប់អនីតិជនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ត្រូវយកអនុវត្តផងដែរ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន គ្មានសិទ្ធិផ្តល់ការយល់ព្រមលើសុំកូនទេ ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលត្រូវបោះបង់ចោល ។

ករណីកុមារដែលត្រូវបោះបង់ចោលពុំអាចរកឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយពុំមានសំបុត្របញ្ជាក់កំណើត ប្រធានមណ្ឌលកុមារកំព្រា ត្រូវសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតកុមារនោះ ទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

មាត្រា ១២.-

ប្រសិនបើ អ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ ត្រូវបញ្ចូលឈ្មោះកុមារនៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលអ្នកអនុវត្តអំណាចមេបារបស់ខ្លួន បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

មាត្រា ១៣.-

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើត ហើយបើមិនអាចធ្វើទៅបានទេ ត្រូវទុកដាក់កុមារតាមរយៈសុំកូនក្នុងព្រះរាជាណាចក្រកម្ពុជា មុននឹងពិនិត្យករណីសុំកូនអន្តរប្រទេស [illegible] ។

12/35

Ksl

នៅពេលវិធានការនានា ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបានបញ្ចប់ កុមារអាចនឹងត្រូវបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីស្ដីពីកុមារដែលកំណត់ថាមានលក្ខណ-សម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

## ផ្នែកទី ២
## ការយល់ព្រមលើសុំកូន

**មាត្រា ១៤.-**

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីដូចខាងក្រោមនេះ :

ក- ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និង ម្ដាយ ការយល់ព្រមត្រូវផ្ដល់ដោយឪពុក និង ម្ដាយរបស់កុមារនោះ ។

ខ- ក្នុងករណីដែលឪពុក ឬ ម្ដាយណាមួយរបស់កុមារបានស្លាប់ ឬ ស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្ដល់ដោយឪពុក ឬ ម្ដាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់ ។

គ- ក្នុងករណីដែលឪពុកម្ដាយរបស់កុមារបានស្លាប់ ឬ ស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្ដល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ ។

**មាត្រា ១៥.-**

ការយល់ព្រមខាងលើត្រូវផ្ដល់ឱ្យដោយសេរី និង ច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយដូចជា ការបង្ខិតបង្ខំ ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្ដល់ ឬ ការសន្យាផ្ដល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយឡើយ និង ដោយបានដឹង[illegible]វិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេស ។

**មាត្រា ១៦.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ដែលបានទទួលការអនុញ្ញាតជាមុនសិន មុននឹងផ្តល់ការយល់ព្រម ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវប្រាប់យ៉ាងច្បាស់លាស់ ដល់អ្នកដែលត្រូវផ្តល់ការយល់ព្រមអំពីអានុភាពនៃការយល់ព្រម ការបញ្ចប់នូវបុត្តភាព ព្រមទាំងការបញ្ចប់សិទ្ធិនិងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង ត្រូវប្រាប់អំពីបែបបទ និង រយៈពេលបញ្ឈប់ការយល់ព្រមដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍របស់ខ្លួនជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

នោះក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងទីលំនៅរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

មេឃុំ ឬ ចៅសង្កាត់ និងភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធានាថា រាល់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាការយល់ព្រមដែលគោរពទៅតាមខ្លឹមសារនៃមាត្រា ១៥ នៃច្បាប់នេះ ។

មេឃុំ ឬ ចៅសង្កាត់ ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមនេះ ក្រោយពីបានពិនិត្យថា ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចបានពិគ្រោះយោបល់ជាមុនជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និង បានប្រាប់យ៉ាងត្រឹមត្រូវអំពីអានុភាពនៃការយល់ព្រមនេះ ។

**មាត្រា ១៧.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារអាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មុនពេលសេចក្តីសម្រេចរបស់តុលាការស្តីពីការសុំកូនធម៌ជាស្ថាពរ ។ ការបញ្ឈប់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននេះ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងលំនៅឋានរបស់ខ្លួន ។ មេឃុំ ឬ ចៅសង្កាត់ខាង

លំនៅឋានរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ប្រធានមណ្ឌលកុមារកំព្រាដែលពាក់ព័ន្ធ និង ត្រូវប្រគល់កំណត់ហេតុចម្លងដែលមានសេចក្ដីបញ្ជាក់នៅលើកំណត់ហេតុនោះ ទៅឱ្យឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

**មាត្រា ១៨.-**

នីតិវិធីការសុំកូនអាចប្រព្រឹត្តទៅបាន លុះត្រាតែផុតកំណត់ពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

**មាត្រា ១៩.-**

ករណីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធការយល់ព្រម ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចប្ដឹងសុំឱ្យតុលាការប្រកាសដកហូតអំណាចមេបាពីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ បញ្ឈប់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងជ្រើសតាំងអ្នកអាណាព្យាបាលថ្មីសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬ ការបញ្ឈប់ការយល់ព្រមនេះ ធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់កុមារ ឬ បណ្ដាលឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬ សីលធម៌របស់កុមារ ។ ពាក្យបណ្ដឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ បដិសេធ ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ។

**មាត្រា ២០.-**

ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ដែលយល់ថា ការយល់ព្រមរបស់ខ្លួនបានមកពីការបង្ហាញឆន្ទៈដែលមានវិការៈ ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ ឬ លុបចោលការយល់ព្រមរបស់ខ្លួនបាន រហូតដល់មុនពេលសម្រេចរបស់តុលាការលើសុំកូនចូល

## ផ្នែកទី ៣

## អ្នកសុំ

**មាត្រា ២១.-**

អ្នកសុំដែលអាចអនុញ្ញាតឱ្យ សុំកុមារយកទៅចិញ្ចឹមជាកូនបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌ ដូចតទៅ :

១-អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុចាប់ពី ៣០(សាមសិប)ឆ្នាំ និង មានអាយុលើសកូនសុំយ៉ាងតិច ២២(ម្ភៃពីរ)ឆ្នាំ និង យ៉ាងច្រើនបំផុត ៤៥(សែសិបប្រាំ)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន ។

២-ក្នុងករណីដែលអ្នកសុំមិនបានបំពេញតាមចំណុច ១ ខាងលើ ហើយក្នុងករណីសុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឱ្យ បាន ក្នុងស្ថានភាពដូចតទៅ :

ក-អ្នកសុំមានដើមកំណើតសញ្ជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬ

ខ-អ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត ឬ

គ-អ្នកសុំ សុំកុមារដែលត្រូវការការថែទាំពិសេស ឬ ស្ថានភាពផ្សេងទៀត ដែលបម្រើឧត្តមប្រយោជន៍របស់កុមារ ។

៣-ក្នុងករណីអ្នកសុំមានប្តី ឬ ប្រពន្ធ ការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នា លើកលែងតែករណីដែលសហព័ទ្ធណាម្ខាង សុំកូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

៤-ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និង ច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និង អនុញ្ញាតនូវបុត្តភាពនៃសុំកូនពេញលេញ ។

៥-ប្រទេសនៃសញ្ជាតិ ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា ។

៦-អ្នកសុំត្រូវមានលក្ខណសម្បត្តិ និង លក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូនស្របទៅតាមច្បាប់ប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន ។

៧-អ្នកសុំត្រូវតែជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬ កំពុងត្រូវបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមារយាទ ឬ ការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍ ឬ ក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ ។

៨-អ្នកសុំត្រូវតែជាអ្នកមានសមត្ថភាពផ្តល់ការថែទាំសមស្រប និង ការគាំទ្រចាំបាច់ដល់កូនសុំ ។

៩-អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបាន លុះត្រាតែអ្នកសុំកូនគ្មានកូន ឬ មានកូនតែម្នាក់នៅក្នុងបន្ទុក ។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យសុំច្រើននាក់បាន ។

## ជំពូកទី ៥
## នីតិវិធីសុំកូន
### ផ្នែកទី ១
### នីតិវិធីរដ្ឋបាល

**មាត្រា ២២.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមាន ព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹម សាវតារជាតិរបស់កុមារ បរិយាកាសសង្គមរបស់កុមារ ប្រវត្តិគ្រួសាររបស់កុមារ ប្រវត្តិសុខភាពរបស់កុមារ និង ប្រវត្តិសុខភាពគ្រួសាររបស់កុមារ និង សេចក្តីត្រូវការជាពិសេសណាមួយរបស់កុមារ ។

ក្នុងករណីកុមារត្រូវបានបោះបង់ចោល រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវបានធ្វើរួចហើយ ។

រដ្ឋបាលសុំកូនអន្តរប្រទេសក៏ត្រូវធានាផងដែរថា រាល់ការយល់ព្រមចាំបាច់ទាំងឡាយត្រូវបានធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ ។

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារ រាប់បញ្ចូលទាំងភស្តុតាងបង្ហាញពីការយល់ព្រម និង/ ឬ ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារផងដែរ ។

**មាត្រា ២៣.–**

អ្នកសុំត្រូវដាក់ពាក្យសុំកូនទៅអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាដោយភ្ជាប់មកជាមួយនូវឯកសាររួមមាន :

១-ភស្តុតាងដែលបញ្ជាក់ថា អាជ្ញាធរកណ្ដាលនៃប្រទេសដើមរបស់ខ្លួន ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ចាត់ទុកថា អ្នកសុំមានលក្ខណសម្បត្តិ និង មានភាពសមស្រប សម្រាប់សុំកូនដោយផ្អែកលើការវាយតំលៃលើជីវប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ ប្រវត្តិសុខភាព បរិយាកាសគ្រួសារ បរិយាកាសសង្គម មូលហេតុសុំកូន និងលទ្ធភាពនៃការទទួលបន្ទុកភារៈចំពោះសុំកូនអន្តរប្រទេស ។

២-ព័ត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបទៅនឹងលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ ។

៣-ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំ ដែលក្នុងនោះរួមមានឯកសារទាក់ទងនឹងអត្រានុកូលដ្ឋាន ។

៤-ព័ត៌មានទាក់ទងនឹងលក្ខណសម្បត្តិផ្សេងៗរបស់កុមារ ដែលអ្នកសុំអាចនឹងមានលក្ខណសម្បត្តិថែទាំបាន ។

៥-ភស្តុតាងទទួលបានពីអាជ្ញាធរកណ្ដាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រមហើយ កូនសុំនោះត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល ។

ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬ ភាសាបារាំង ដែលមានការបញ្ជាក់ត្រឹមត្រូវ ។

មាត្រា ២៤.-

ពាក្យសុំដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ត្រូវបញ្ជូនមកក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ តាមរយៈអាជ្ញាធរកណ្ដាល ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ ។ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យផ្ដល់យោបល់ និង ត្រូវបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំ ។ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកសុំ តាមរយៈអាជ្ញាធរកណ្ដាលនៃប្រទេសដើមរបស់អ្នកសុំ ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ ដោយបញ្ជាក់ថា ខ្លួនបានទទួលពាក្យសុំកូន ។

មាត្រា ២៥.-

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និង វិភាគទាននានា សម្រាប់ជួយឧបត្ថម្ភដល់ជីវភាពនានានៃការថែទាំជិន្ទូស និង ការជួយឧបត្ថម្ភទូទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និង កម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ក្រៅពីនេះ មិនត្រូវយកថ្លៃសោហ៊ុយសុំកូនពីអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូន ។ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនបង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬ ទៅតាមសោហ៊ុយសុំកូនមួយៗដែលនឹងត្រូវបញ្ជូនទៅឱ្យមណ្ឌលកុមារកំព្រាណាមួយ ឬ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនធ្វើការផ្ដល់សោហ៊ុយ អំណោយ ឬ ការទូទាត់ ទោះក្នុងរូបភាពណាក៏ដោយឱ្យទៅមណ្ឌលកុមារកំព្រាដែលកុមារនៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬ ទៅឱ្យបុគ្គលិក នាយក ឬ សមាជិកនៃគណៈគ្រប់គ្រងទោះជាដោយផ្ទាល់ ឬ ដោយប្រយោលក្ដី ។

**មាត្រា ២៦.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតសុំកូន ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។ ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ហើយ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវបញ្ជាក់ថា អ្នកសុំបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់នេះហើយ ។

ក្នុងករណីដែលសំណុំលិខិតដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស មិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរអំពីឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលឯកសារដែលនៅខ្វះ ឬ កែតម្រូវរួច។

ក្នុងករណីអ្នកសុំខកខានមិនបានផ្តល់ឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃរដ្ឋបាលសុំកូនអន្តរប្រទេសបានជូនដំណឹងអំពីឯកសារដែលមិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ នោះពាក្យសុំកូនអន្តរប្រទេសត្រូវទុកជាមោឃៈ ។

ក្នុងករណីបដិសេធពាក្យសុំ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវមានបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ ។

**មាត្រា ២៧.-**

ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និង ត្រឹមត្រូវ ហើយអ្នកសុំបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់នេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសាររបស់កុមារទាំងឡាយដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសបាន និងត្រូវផ្គូផ្គងពីលក្ខណសម្បត្តិរបស់អ្នកសុំណាដែលត្រូវគ្នាល្អបំផុតនឹងលក្ខណសម្បត្តិរបស់កុមារ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ក្នុងការផ្តល់ផ្គងដោយគិតគូរពល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិចារណាឱ្យបានសមស្របទៅលើអត្ថប្រយោជន៍នៃការបន្តឱ្យមានការបីបាច់ថែរក្សាកុមារ ដូចពេលកន្លងមក ព្រមទាំងពិចារណាទៅលើសាវតារសង្គម ជាតិពន្ធុ សាសនា និងវប្បធម៌របស់កុមារ ។

**មាត្រា ២៨.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលត្រូវបានផ្តល់ផ្គង រួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការយល់ព្រមចាំបាច់នានា ត្រូវបានទទួលរួចហើយ និងមូលហេតុដែលខ្លួនកំណត់ទុកដាក់កុមារជាមួយអ្នកសុំនោះទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីពិនិត្យនិងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពីអត្តសញ្ញាណឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារឡើយ លើកលែងតែករណីសុំកូនដោយសាច់ញាតិ ។

**មាត្រា ២៩.-**

អ្នកសុំត្រូវឆ្លើយតបទៅរដ្ឋបាលសុំកូនអន្តរប្រទេសជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមសុំកុមារ ដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្តល់ផ្គងឱ្យតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ។

ក្នុងករណីអ្នកសុំមិនបានឆ្លើយតបមករដ្ឋបាលសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្ញើសំណុំឯកសាររបស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសអាចចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ហើយរដ្ឋបាលសុំកូនអន្តរប្រទេសអាចផ្តល់ផ្គងកុមារនោះឱ្យទៅអ្នកសុំផ្សេងទៀតបាន ។ ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនត្រូវបាន[illegible]ឡើយ ។

ក្នុងករណីអ្នកសុំបានឆ្លើយតបថាមិនទទួលយកកុមារដែលបានផ្តួលផ្តងឱ្យខ្លួននៅលើកទីមួយទេ អ្នកសុំនោះអាចស្នើសុំឱ្យរដ្ឋបាលសុំកូនអន្តរប្រទេសផ្តួលផ្តងកុមារជាលើកទីពីរបាន ។ ការផ្តួលផ្តងនេះមិនត្រូវអនុញ្ញាតឱ្យធ្វើជាលើកទីបីឡើយ ។

ចំពោះអ្នកសុំដែលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ អ្នកសុំនោះអាចដាក់ពាក្យសុំកូនសាជាថ្មីស្របតាមនីតិវិធីនៃច្បាប់នេះ ។ ក្នុងការសម្រេចអំពីការសុំឱ្យមានការផ្តួលផ្តងសាជាថ្មី ឬ ការទទួលពាក្យសុំកូនសាជាថ្មី រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាអំពីមូលហេតុដែលអ្នកសុំខកខានមិនបានឆ្លើយតប ឬ ឆ្លើយតបថា មិនមានបំណងសុំកុមារដែលបានផ្តួលផ្តងពីលើកមុននាពេលកន្លងមក ។

**មាត្រា ៣០.-**

បន្ទាប់ពីអ្នកសុំ បានបញ្ជាក់ការយល់ព្រមរបស់ខ្លួនស្របតាមបទប្បញ្ញត្តិក្នុងមាត្រា ២៩ នៃច្បាប់នេះ ហើយអាជ្ញាធរកណ្តាលនៃប្រទេសទទួល បានយល់ព្រមលើការសម្រេចនេះ រដ្ឋបាលសុំកូនអន្តរប្រទេសតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ត្រូវរៀបចំឱ្យមានការជួបប្រទះរវាងអ្នកសុំ និង កុមារដែលត្រូវបានផ្តួលផ្តងរួចហើយ ។

ការជួបប្រទះនេះត្រូវប្រព្រឹត្តទៅតាមកាលបរិច្ឆេទមួយសមស្របសម្រាប់អ្នកសុំ និង រដ្ឋបាលសុំកូនអន្តរប្រទេស និង ត្រូវមានវត្តមានមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង ។ ការជួបប្រទះនេះ ត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ ។

មុនការជួបប្រទះរវាងអ្នកសុំ និង កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើសម្ភាសន៍អ្នកសុំ និង ធានាថា អ្នកសុំ និង កុមារត្រូវបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មាន ការផ្លាស់ប្តូររូបថត និង វិធានការចាំបាច់ផ្សេងៗទៀត ដើម្បីការជួបប្រទះនេះ ។

ករណីមានសហព័ទ្ធ បើសហព័ទ្ធណាម្ខាងមិនអាចមកបាន សហព័ទ្ធនោះត្រូវធ្វើលិខិតប្រគល់សិទ្ធិឱ្យទៅសហព័ទ្ធម្ខាងទៀត ធ្វើជាអ្នកតំណាងរបស់ខ្លួន ដើម្បីធ្វើសកម្មភាពក្នុងការសុំកូននេះ ។ លិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS

2/35

Kol

ក្នុងករណីអ្នកសុំមិនមកក្នុងរយៈពេលដូចបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ដោយគ្មានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារឱ្យបានដឹងអំពីអានុភាពដែលកើតចេញពីសុំកូននេះ ហើយត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួន ដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវយល់ដឹងឱ្យបានច្បាស់ អំពីទស្សនៈកុមារលើរាល់បញ្ហាដែលពាក់ព័ន្ធដល់សុំកូន ក្នុងនោះមានជាអាទិ៍ ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅគិតគូរពិចារណាដោយផ្អែកទៅតាមវ័យ និង កម្រិតយល់ដឹងរបស់កុមារ ។ សំអាងស្តីពីការយល់ព្រមរបស់កុមារត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍ និង ការជួបគ្នាខាងលើនេះ ។

**មាត្រា ៣១.-**

បទប្បញ្ញត្តិ ដែលមានចែងក្នុងជំពូកនេះត្រូវយកមកអនុវត្តផងដែរចំពោះសុំកូនដោយសាច់ញាតិ ។

**មាត្រា ៣២.-**

ក្នុងករណីរដ្ឋបាលសុំកូនអន្តរប្រទេសពិនិត្យឃើញថា អ្នកសុំ និង កុមារបំពេញបាននូវលក្ខណវិនិច្ឆ័យ និង លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ហើយសុំកូននេះពិតជាបានឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការជួបគ្នារវាងអ្នកសុំ និង កុមារ ។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវដាក់សំណុំលិខិតទាំងនេះ ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការពិនិត្យ និង ផ្តល់អនុសាសន៍លើដំណើរការសុំកូន ។

**មាត្រា ៣៣.‒**

ក្រោយពីទទួលអនុសាសន៍លើដំណើរការសុំកូនពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដាក់ពាក្យសុំកូនដែលបានផ្តួចផ្តើម តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសុំដីកាសម្រេចសុំកូន ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជូនពាក្យសុំកូនទៅសាលាដំបូងរាជធានីភ្នំពេញដោយភ្ជាប់មកជាមួយនូវសំណុំឯកសាររបស់កុមារ និង អ្នកសុំ ព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីកាលបរិច្ឆេទទទួលពាក្យសុំ ។ ឯកសារចាំបាច់ទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ និង មានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេស ។

ក្នុងករណីអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់ទុកថាអ្នកសុំនោះបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

## ផ្នែកទី ២
## នីតិវិធីតុលាការ

**មាត្រា ៣៤.‒**

សាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ។

តុលាការដែលមានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ត្រូវយកបទប្បញ្ញត្តិស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងមកអនុវត្តចំពោះនីតិវិធីតុលាការទាក់ទងនឹងសុំកូនអន្តរប្រទេស លើកលែងតែមានបទប្បញ្ញត្តិពិសេសដូចមានចែងនៅក្នុងច្បាប់នេះ ។

**មាត្រា ៣៥.‒**

អ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០ (មួយលាន) រៀល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យសុំ ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយ ការជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និង សកម្មភាពខាងនីតិវិធីផ្សេងៗទៀត

ដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស ។ តុលាការត្រូវបង្គាប់ឱ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន ។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះ លើសពី ១.០០០.០០០ (មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និង បង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន ។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ ។

**មាត្រា ៣៦.-**

ជាគោលការណ៍ សំណុំឯកសារ និង របាយការណ៍ដែលដាក់ជូនតុលាការដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវសន្មតជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណសម្បត្តិ សុំកូនរបស់កុមារ និង ភាពសមស្របសម្រាប់សុំកូនរបស់អ្នកសុំលើកលែងតែមានភស្តុតាងផ្ទុយមកបញ្ជាក់ ។

ក្នុងករណីចាំបាច់ តុលាការអាចបង្គាប់ឱ្យអ្នកតំណាងរដ្ឋបាលសុំកូនអន្តរប្រទេសមកបំភ្លឺបន្ថែមអំពីលទ្ធផលនៃការស្រាវជ្រាវ និង អនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសរួមទាំងឯកសារ របាយការណ៍ និង ភស្តុតាងជាឯកសារពាក់ព័ន្ធដែលគាំទ្រលទ្ធផលនៃការស្រាវជ្រាវខាងលើ ។

**មាត្រា ៣៧.-**

តុលាការត្រូវពិនិត្យផ្ទៀងផ្ទាត់ថា :

ក- លក្ខណវិនិច្ឆ័យ ឬ លក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ ។

ខ- ការពិគ្រោះយោបល់ជាចាំបាច់នានាត្រូវបានធ្វើមុននឹងផ្តល់ការយល់ព្រម ។

គ- ការយល់ព្រមចាំបាច់នានាត្រូវបានផ្តល់ ដោយគោរពតាមខ្លឹមសារផ្នែកទី ២ ជំពូកទី ៤ នៃច្បាប់នេះ ។

ឃ- មានការពិចារណាត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល យល់ព្រមលើការទុកដាក់កុមារ ។

- កុមារនឹងត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេស …

… សុំកូនអន្តរប្រទេសនេះពិតជាឧត្តមប្រយោជន៍របស់កុមារ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៣៨.–**

តុលាការសម្រេចសេចក្ដីអំពីរឿងក្ដីដែលទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

ក្នុងករណីមានភាពចាំបាច់ដាច់ខាតត្រូវបំភ្លឺអង្គហេតុពាក់ព័ន្ធ តុលាការអាចអញ្ជើញអ្នកសុំ ឬ អ្នកតំណាង ឬ អ្នកមានអំណាចមេបាម្ខាង ឬ ទាំងពីរ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសពាក់ព័ន្ធ និងសាក្សីផ្សេងទៀត ដើម្បីផ្ដល់ភស្ដុតាងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ទាក់ទងនឹងអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ ។

**មាត្រា ៣៩.–**

តុលាការត្រូវលើកយកសំណុំរឿងសុំកូនអន្តរប្រទេសមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំកូន ។ តុលាការត្រូវបញ្ជូនដីកាសម្រេចនេះទៅអ្នកសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំ និងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្ដឹងជំទាស់ ដែលបានកំណត់នៅក្នុងមាត្រា ៤០ នៃច្បាប់នេះ ។ ក្នុងករណីមានការប្ដឹងជំទាស់ចំពោះដីកាសម្រេចនេះ ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពររហូតដល់ពេលមានដីកាសម្រេចអំពីបណ្ដឹងជំទាស់នោះ ។

**មាត្រា ៤០.–**

បុគ្គលដែលមានសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្ដឹងជំទាស់ទៅសាលាឧទ្ធរណ៍ ចំពោះដីកាសម្រេចនោះបាន ។

ក្នុងករណីដែលបុគ្គលអាចប្ដឹងជំទាស់ជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្ដឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលខ្លួនទទួលបានការជូនដំណឹងអំពីដីកាសម្រេច ។

ក្នុងករណីដែលបុគ្គលអាចប្ដឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្ដឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ)

ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលអ្នកសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេច ។

អំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ដែលកំណត់ក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើមិនអាចពន្យារបានឡើយ ។

សាលាឧទ្ធរណ៍ត្រូវលើកយកពាក្យបណ្តឹងជំទាស់នោះមកវិនិច្ឆ័យ និង ចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងជំទាស់ ។

ដីកាសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ទៀតបានឡើយ ។

## ជំពូកទី ៦
## អានុភាពនៃសុំកូន

**មាត្រា ៤១.–**

សុំកូនអន្តរប្រទេសត្រូវតែជាសុំកូនពេញលេញ ។ សុំកូនអន្តរប្រទេសមានអានុភាពបង្កើតនូវទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយ និង កូនជាអចិន្ត្រៃយ៍ ដោយផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ហើយវាបញ្ចប់ញាតិភាពរវាងកុមារ និង ឪពុកម្តាយបង្កើតរបស់ខ្លួន ។

**មាត្រា ៤២.–**

អានុភាពផ្សេងទៀតនៃសុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយច្បាប់ជាតិរបស់អ្នកសុំ ឬ ប្រសិនបើគ្មានច្បាប់រួមមួយទេ ត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

## ជំពូកទី ៧
## ការជូនដំណឹងពីចំណាត់ការ និង នីតិវិធី បន្ទាប់ពីបញ្ចប់ដំណើរការសុំកូនអន្តរប្រទេស

**មាត្រា ៤៣.–**

រដ្ឋជាអ្នកសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីសុំកូន ទៅ[illegible]ដែលជាអាជ្ញាធរមានសមត្ថកិច្ចបានចាត់ការ និង ការវិវត្តនៃការសុំកូនទៅគ្រប់

ដំណាក់កាលរបស់នីតិវិធីសុំកូនឱ្យ បានទៀងទាត់ ទៅអ្នកសុំតាមរយៈអាជ្ញាធរកណ្ដាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាត ។

**មាត្រា ៤៤.–**

ក្រោយពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវជូនដំណឹងទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អំពីដីកាសម្រេចនេះ ។

នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេសត្រូវបានបញ្ចប់ ដោយអនុលោមទៅតាម អនុសញ្ញាក្រុងឡាអេ ស្ដីពីការការពារកុមារ និង សហប្រតិបត្តិការ ទាក់ទងនឹងសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចេញលិខិតបញ្ជាក់អនុលោមតាមមាត្រា ២៣ នៃអនុសញ្ញានេះ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំពិធីប្រគល់កុមារ និង លិខិតបញ្ជាក់ស្ដីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការរៀបចំ និង ផ្ដល់នូវលិខិតឆ្លងដែន ទិដ្ឋាការ និង ឯកសារចាំបាច់នានា ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួល ត្រូវអមដំណើរដោយអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធានាថាការផ្ទេរកុមារទៅកាន់ប្រទេសទទួល ប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរដល់សេចក្ដីត្រូវការនានារបស់កុមារ ។

**មាត្រា ៤៥.–**

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្ដាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីផ្ដល់ ឬ សម្របសម្រួលសេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារចិញ្ចឹម និង គ្រួសារបង្កើតតាមការចាំបាច់ ។

ក្រោយពីកុមារត្រូវបានទទួលការអនុញ្ញាតឱ្យធ្វើជាកូន ឪពុកម្ដាយចិញ្ចឹមត្រូវផ្ដល់របាយការណ៍អំពីស្ថានភាពវិវឌ្ឍន៍របស់កុមារមករដ្ឋបាលសុំកូនអន្តរប្រទេសជារៀងរាល់ ៦ (ប្រាំមួយ) ខែម្ដង ក្នុងរយៈពេល ៣ (បី) ឆ្នាំ បន្ទាប់មកត្រូវផ្ដល់របាយការណ៍ ១ ឆ្នាំម្ដង រហូតដល់កុមារមានអាយុ ១៨ ឆ្នាំ ។

ឪពុកម្តាយចិញ្ចឹមត្រូវផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ឬ ប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប ។

**មាត្រា ៤៦.-**

រដ្ឋបាលសុំកូនអន្តរប្រទេស និង សាលាដំបូងរាជធានីភ្នំពេញ ត្រូវរក្សាទុកសំណុំឯកសារសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ឆ្នាំ គិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះចូលជាស្ថាពរ ។

សំណុំឯកសារ និង កំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ទោះជារក្សាទុកនៅតុលាការ រដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និង អ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាទុកជាការសម្ងាត់ ។ ក៏ប៉ុន្តែសំណុំឯកសារនិងកំណត់ហេតុ ឬ ព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំឯកសារ និង កំណត់ហេតុទាំងនោះអាចនឹងត្រូវបញ្ចេញទៅតាមការស្នើសុំ ឬ ការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច នៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានតម្រូវការទាក់ទងនឹងករណី ឬ នីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅ ឬ កាលៈទេសៈពិសេសដទៃទៀត ។

ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំក្រោយពីដីកាសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ ។ កូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អំពីផលវិបាកនៃការដឹងអត្តសញ្ញាណរបស់ខ្លួន អាចត្រូវបានអនុញ្ញាតឱ្យមើលសំណុំលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីការមើលនេះជាឧត្តមប្រយោជន៍របស់កូនសុំ ។ កូនសុំដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និង កំណត់ហេតុទាក់ទងនឹងអត្តសញ្ញាណខ្លួន ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា កូនសុំទទួលបានការពិគ្រោះយោបល់សមស្របមុននឹងមើលព័ត៌មានដែលមាននៅក្នុងសំណុំលិខិតរបស់ខ្លួន ។

## ជំពូកទី ៨

## ការផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារ

**មាត្រា ៤៧.-**

មានតែទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ស្របតាមមាត្រាជាបន្តបន្ទាប់ដូចខាងក្រោមប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

ចំនួនទីភ្នាក់ងារមកពីប្រទេសទទួលនីមួយៗ ដែលអនុញ្ញាតឱ្យផ្តល់សេវានៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវកំណត់ដោយកិច្ចព្រមព្រៀងរួមគ្នាមួយរវាងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និង អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល ។

**មាត្រា ៤៨.-**

ដើម្បីសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារត្រូវមានលក្ខណសម្បត្តិដូចតទៅ :

១- មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ។

២- មានទិសដៅមិនស្វែងរកផលចំណេញ និង បានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ ។

៣- មានអ្នកដឹកនាំនិងមានបុគ្គលិកដែលមានសមត្ថភាពប្រកបដោយគុណធម៌ និង សីលធម៌ ព្រមទាំងបានទទួលការបណ្តុះបណ្តាល និង មានបទពិសោធន៍ធ្វើការងារក្នុងវិស័យសុំកូនអន្តរប្រទេស ។

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវបានអនុញ្ញាតឱ្យបើក ឬ យកមណ្ឌលកុមារកំព្រា ជាប្រភពដើម្បីផ្គត់ផ្គង់ទារក និង កុមារកំព្រា នៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

**មាត្រា ៤៩.-**

ទីភ្នាក់ងារនីមួយៗត្រូវបានចុះបញ្ជីតាមបទប្បញ្ញត្តិច្បាប់ជាធរមាន របស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត ទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ មុនពេលដាក់ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេស ។ ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវចុះកិច្ចសន្យាស្តីពីប្រតិបត្តិការសុំកូនអន្តរប្រទេស និង បំពេញបែបបទផ្សេងៗទៀត តាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ៥០.-**

ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅព្រះរាជាណាចក្រកម្ពុជា ដែលដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម :

១- ពាក្យសុំការអនុញ្ញាតដោយមានការយល់ព្រម និង ទទួលស្គាល់ពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

២- ឯកសារសង្ខេបអំពីប្រវត្តិ និង សកម្មភាពរបស់ទីភ្នាក់ងារ ។

៣- ច្បាប់ចម្លងដែលមានបញ្ជាក់ត្រឹមត្រូវអំពីការអនុញ្ញាតឱ្យបើកទីភ្នាក់ងារពីប្រទេសទទួលរបស់ខ្លួន ចំពោះទីភ្នាក់ងារអន្តរជាតិ ។

៤- ច្បាប់ចម្លងលិខិតចុះបញ្ជីដែលមានបញ្ជាក់ត្រឹមត្រូវដូចមានចែងក្នុងមាត្រា ៤៩ នៃច្បាប់នេះ ។

៥- លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ ។

៦- ជីវប្រវត្តិសង្ខេបនិងរូបថតរបស់សមាជិកក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រង ។

៧- ជីវប្រវត្តិសង្ខេបរបស់បុគ្គលដែលបានទទួលការអនុញ្ញាតឱ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារចំពោះកិច្ចការសុំកូនអន្តរប្រទេស ។ អ្នកតំណាងទាំងនេះមិនត្រូវឱ្យលើសពីរនាក់ និងមិនមែនជានាយក នាយករង ឬ បុគ្គលិកនៃមណ្ឌលកុមារកំព្រាណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

៨- ឯកសារភស្តុតាងនានាដែលបញ្ជាក់ថាអ្នកតំណាងដូចមានចែងក្នុងចំណុចទី ៧ ខាងលើ គ្មានជាប់ឈ្មោះក្នុងបញ្ជីថ្កោលទោសនៅប្រទេសដើមរបស់ខ្លួន និង នៅប្រទេសចុងក្រោយដែលខ្លួនរស់នៅ ក្នុងករណីប្រទេសនុសញ្ញា ។

៩- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសុំកូនអន្តរប្រទេស រវាងព្រះរាជាណាចក្រកម្ពុជា និង ប្រទេសរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្នុងករណីដែលប្រទេសនោះមិនមែនជារដ្ឋភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសទេ ។

១០- របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មឯករាជ្យ និង កិច្ចព្រមព្រៀងផ្តល់ជំនួយមនុស្សធម៌ ឬ ការជួយឧបត្ថម្ភដល់កុមារកំព្រានានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១១- តម្រូវការផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចយល់ថាចាំបាច់ ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ ដូចមានចែងនៅក្នុងនីតិវិធីទាក់ទងនឹងការផ្តល់ការអនុញ្ញាត ។

ច្បាប់ចម្លងចំនួនមួយច្បាប់នៃពាក្យសុំ និង សំណុំលិខិតសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារ ត្រូវផ្ញើជូនស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួល ដែលទីភ្នាក់ងារធ្វើប្រតិបត្តិការនៅទីនោះ ។

**មាត្រា ៥១.-**

ក្នុងកំឡុងពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅទីភ្នាក់ងារវិញអំពីការសម្រេចជាផ្លូវការរបស់ខ្លួន ។ ក្នុងករណីមានការបដិសេធ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវបញ្ជាក់អំពីមូលហេតុឱ្យ បានច្បាស់លាស់ ។

**មាត្រា ៥២.-**

មានតែអ្នកតំណាងដែលមានឈ្មោះក្នុងសំណុំឯកសារពាក្យសុំការអនុញ្ញាតតែប៉ុណ្ណោះដែលមានសិទ្ធិធ្វើជាអ្នកតំណាងទីភ្នាក់ងារនៅក្នុងដំណើរការសុំកូនអន្តរប្រទេស ។ ក្នុងករណីអ្នកតំណាងដែលបានទទួលការអនុញ្ញាត ត្រូវជំនួសដោយអ្នកផ្សេងនោះ ទីភ្នាក់

32/35 Kol

ងារត្រូវដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការអនុញ្ញាតជាថ្មីឡើងវិញ។

**មាត្រា ៥៣.-**

ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ត្រូវផ្តល់ឱ្យសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ ហើយអាចអនុញ្ញាតឱ្យបន្តទៀតបាន ដោយទីភ្នាក់ងារត្រូវដាក់ពាក្យសុំសាជាថ្មី និងត្រូវបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៤៨ មាត្រា ៤៩ និង មាត្រា ៥០ នៃច្បាប់នេះ ដរាបណាសេវារបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅតែចាំបាច់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**មាត្រា ៥៤.-**

ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាធរមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចព្យួរ ឬ ដកហូតការទទួលស្គាល់ ឬ បដិសេធការទទួលស្គាល់ ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឱ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេស ជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចតទៅ :

១- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ឱ្យឪពុកម្តាយ ឬ ឪពុក ឬ ម្តាយបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើត ដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស ។

២- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុកម្តាយ ឬឪពុក ឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត ។

៣- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីបង្កើតនិងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

៤- អំពើក្លែងបន្លំ ឬ សមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបាន ការយល់ព្រមពីឪពុកម្តាយបង្កើត ឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬ អ្នកអាណាព្យាបាល សម្រាប់អនីតិជនរបស់កុមារ ។

៥- អំពើរៀបចំឱ្យមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដោយការបង្ខិតបង្ខំ ការគំរាមកំហែង ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬ សន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយ ។

៦- ការបញ្ចេញសំណុំឯកសារ និង កំណត់ហេតុទាំងអស់ ឬ មួយផ្នែកទាក់ទង នឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងទទួល បន្ទុកវិស័យសង្គមកិច្ច ឬ តុលាការមានសមត្ថកិច្ច ។

៧- ការបង្គាប់ ឬ ការទទួលដោយផ្ទាល់ ឬ ដោយប្រយោល នូវថ្លៃប្រាក់កាស ទំនិញ ឬ សេវា ដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន ។

៨- ការផ្តល់ប្រាក់កាស ទំនិញ ឬ សេវាទៅឱ្យមន្ត្រី ឬ អ្នកតំណាងណាមួយ នៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្តាលទទួល ខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ឬ មន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យផ្តល់នូវសិទ្ធិជាអាទិ-ភាពនៅក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ ។

៩- ការផ្សាយពាណិជ្ជកម្ម ឬ ការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬ រូបថត របស់កុមារណាមួយដែលជាកម្មវត្ថុសុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយ ឱ្យដាក់ពាក្យសុំកូន ។

១០- ការតែងតាំង ឬ ចាត់តាំងអ្នកតំណាងណាមួយដោយមិនមានការឯកភាព ពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១១- ការចូលរួមក្នុងការរៀបចំការផ្គូផ្គង ឬ ការទាក់ទងគ្នារវាងអ្នកសុំ និង ឪពុកម្តាយបង្កើត ឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារក្នុង គោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ ។

១២- ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នេះ បទដ្ឋានអប្បបរមានៃ ការថែទាំជំនួសចំពោះកុមារ និង បទប្បញ្ញត្តិផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រ កម្ពុជា ។

**មាត្រា ៥៥.–**

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនអនុវត្តតាមកថាខណ្ឌទី ១ មាត្រា ៤៧ ឬ កថាខណ្ឌទី ២ មាត្រា ៤៨ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ការដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ប្រាក់ពិន័យអន្តរការណ៍នេះត្រូវបង់ចូលទៅក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ ។

ក្នុងករណីទីភ្នាក់ងារមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៥៦.–**

បទល្មើសពាក់ពន្ធ័ទៅនឹងច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៥៧.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥៨.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

ពរម.០៩១២.១១៤៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ហត្ថលេខា

អ៊ិត សំហេង

លេខ ១០៥៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៩